ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 24-Apr-2012, 15:16
CMS/CFO: Kauv Keoratanak

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១២**

**ម៉ោង ០៩:០៣ នាទី**

**សវនាការលើកទី៥៤**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោក ដាវ អានសាន

លោក អេនឌ្រូ ចេមស៍ ម៉ាគិនថាយអ៊័រ
*(Andrew James MCINTYRE)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាស្មី

លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន

*(Mr. Michiel PESTMAN)*

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោកស្រី អង់តា ហ្គីសសេ

*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវ៉ាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ម៉ុច សុវណ្ណារី

លោក ហុង គីមសួន

លោកស្រី ជេត វណ្ណលី

លោកស្រី ស៊ីន សុវ៉ាន

លោក វ៉េន ពៅ

លោក បាណាបេ ណេគ្វី*(Mr. Barnabé NEKUIE)*

លោកស្រី អេលីហ្សាប៊ែត រ៉ាបេសាន់ដ្រាតាណា

*(Elisabeth RATBESANDRATANA)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក ច័ន្ទ តារាវស្សី | ខ្មែរ |
| លោក វាំងសង់ វ៉ាយដ៍ ដេស្ពាឯល | បារាំង |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោក លឹម ប៊ុនហេង (មេធាវីប្រឹក្សារបស់សាក្សី) | ខ្មែរ |
| លោក សាឡូត បាន (TCW-586) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក សាឡុត បាន** (TCW-586)
សួរដោយប្រធានអង្គជំនុំ ផ្ដើមពី៖......ទំព័រ០៤
សួរដោយលោក ច័ន្ទ តារាវស្មី ផ្ដើមពី៖ ......ទំព័រ០៧
សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯង ផ្ដើមពី៖......ទំព័រ៤៣

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៣:៤៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅក្នុងកិច្ចដំណើរការសវនាការចាប់ពីថ្ងៃនេះទៅ ហើយអាចពេញមួយសប្តាហ៍នេះ កិច្ចដំណើរការសវនាការរបស់អង្គជំនុំជម្រះសាលាដំបូងនឹងស្តាប់សក្ខីកម្មសាក្សី TCW-586។

ក្រឡាបញ្ជីឡើងរាយការណ៍ អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គល ដែលអង្គជំនុំជម្រះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនាពេលនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន ស្ថានភាពវត្តមាននៅថ្ងៃនេះ ខាងព្រះរាជអាជ្ញាមានវត្តមានគ្រប់ចំនួន។ ខាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានវត្តមាន។ ភាគីខាងជនជាប់ចោទ មេធាវីក្រុមនីមួយៗមានវត្តមានគ្រប់ចំនួនរួមទាំងជនជាប់ចោទផងដែរ។ ដោយឡែកចំពោះសាក្សី TCW-586 មានវត្តមាននៅក្នុងបន្ទប់រង់ចាំ រង់ចាំការកោះហៅរបស់អង្គជំនុំជម្រះ។

សូមអរគុណ។

[០៩:០៥:៣៣]

**ប្រធានអង្គជំនុំ៖**

ក្រឡាបញ្ជីរាយការណ៍ អំពីស្ថានភាពទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធ រវាងសាក្សីជាមួយនឹងភាគីដើមបណ្តឹងរដ្ឋប្បវេណី និង/ឬ ជនជាប់ចោទ ហើយនិងតើគាត់បានធ្វើសម្បថហើយឬនៅ?

**ក្រឡាបញ្ជី៖**

បាទ សូមជម្រាបផងដែរលោកប្រធាន សាក្សីរូបនេះ បានរៀបចំធ្វើសម្បថរួចហើយ កាលពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១២ ស្របតាមវិធាន២៤ អនុវិធាន១ នៃវិធានផ្ទៃក្នុង និងមាត្រា១៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។ សាក្សីរូបនេះបានប្រកាសផងដែរថា ខ្លួនមិនមានចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទ ឬបុគ្គលណាមួយដែលត្រូវបានទទួលស្គាល់ជាដើម

បណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង០០២ នេះទេ។ បាទ សូមអរគុណ។

[០៩:០៦:៣០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណក្រឡាបញ្ជី។ មន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី 586 ចូលមកកាន់ កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

ក្រឡាបញ្ជីសវនាការ តាមរបាយការណ៍របស់មន្ត្រីរដ្ឋបាលតុលាការថា សាក្សីរូបនេះមានមេធាវីប្រឹក្សាគាត់ផង។ តើអ៊ីចឹងពិតមែនដែរទេ?

**ក្រឡាបញ្ជី៖**

បាទ ជម្រាបលោកប្រធាន។ ពិតប្រាកដជាអ៊ីចឹងមែនបាទ គឺគាត់បានស្នើសុំឱ្យមានមេធាវីនៅជាមួយគាត់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ មន្ត្រីរដ្ឋបាលតុលាការអញ្ជើញ សាក្សី ព្រមទាំងមេធាវីប្រឹក្សាមកចូលកាន់កន្លែងផ្តល់សក្ខីកម្ម។

សូមអញ្ជើញលោកមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

[០៩:០៧:៤៣]

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម អង្គសវនាការទាំងមូល។ យើងខ្ញុំមានបំណងជម្រាបជូនអង្គសវនាការ ក៏ដូចជាលោក លោកស្រីចៅក្រមថា ពាក់ព័ន្ធនឹងអន្តរាគមន៍ ក៏ដូចជាការលើកសំណួរពាក់ព័ន្ធនឹងសាក្សីរូបនេះ មេធាវីនាំមុខសូមផ្ទេរសិទ្ធិជូនលោកស្រីមេធាវី ដេត វណ្ណលី លោកស្រីមេធាវី អេលីហ្សាប៊ែត រ៉ាបេសាន់ដ្រាតាណា ដែលជាមេធាវីក្រុមមេធាវីគ្មានព្រំដែនបារាំង។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ អង្គជំនុំជម្រះអនុញ្ញាតតាមការស្នើសុំរបស់មេធាវីមុខតំណាងដើមបណ្តឹងបណ្តឹងរដ្ឋប្បវេណីក្នុងការផ្ទេរសិទ្ធិដេញដោលសាក្សីរូបនេះ ជូនទៅសាក្សីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនេះធ្វើជាតំណាង។

សូមអញ្ជើញលោកមេធាវី ម៉ៃខល កាណាវាស!

[០៩:០៨:៥៦]

**លោក ម៉ៃខល កាណាវាស៖**

បាទ សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម ហើយនិងសាធារណជនទាំងអស់។ នៅថ្ងៃទី០៩ មេសា លោកបានទទួលនូវអ៊ីម៉ែលមួយ ដែលដាក់ជូននូវនីតិវិធីក្នុងការផ្តល់ឯកសារជាមុន ហើយនៅក្នុង*អ៊ីទធីហ្វេស*កុំព្យូរទ័រ។ ប៉ុន្តែក្នុងករណីនោះ យើងមិនបានទទួលឯកសារនេះទេចំពោះសាក្សីរូបនេះ គឺថាយើងចង់បាន២៤ម៉ោងមុនដែលសាក្សីវត្តមាន។ តាមពិតខ្ញុំមិនដឹងថា តើសហព្រះរាជអាជ្ញាដឹងដែរឬទេ ថាខ្លួនបានផ្តល់ឯកសារទេ ឬក៏ជូនទៅក្រឡាបញ្ជីដើម្បីផ្តល់ឲ្យយើងខ្ញុំ គឺថាយើងខ្ញុំមិនអាចបើកមើលបានទេ។ នៅពេលនេះ យើងមិនដឹងថាតើសហព្រះរាជអាជ្ញា នឹងបង្ហាញនូវឯកសារនោះដែរឬទេ ដោយអនុលោមទៅតាមនីតិវិធី។

ខ្ញុំសូមឆ្លៀតពេលនេះ ដើម្បីបញ្ជាក់ជូនតុលាការផងដែរថា នៅពេលដែលសាក្សីបង្ហាញខ្លួននៅថ្ងៃចន្ទ គឺថាយើងមានសារៈប្រយោជន៍ ដើម្បីឲ្យយើងមានបញ្ជីសម្រាប់យើងពិនិត្យមើលនៅថ្ងៃសុក្រ បើមិនដូច្នោះទេ យើងនឹងមិនមានលទ្ធភាពបើកមើលឯកសារទាំងអស់នោះទេ។ ហើយយើងមិនបានឆ្លងប្រព័ន្ធតុលាការ ហើយដើម្បីឲ្យយើងដឹងថានៅថ្ងៃសៅរ៍ ឬថ្ងៃអាទិត្យដើម្បីឲ្យយើងមើលនៅថ្ងៃអាទិត្យក្រោយបាន។ ហើយយើងមិនស្នើថាមិនឲ្យបញ្ជូនបញ្ជីទេ ប៉ុន្តែត្រូវដាក់នៅក្នុងប្រព័ន្ធដែលថា ឲ្យយើងអាចឲ្យយើងបើកមើលបានផង។ ថាតើគាត់មានចេតនានឹងធ្វើអ្វីនៅក្នុងសប្តាហ៍នេះ ថ្ងៃនេះ ឬក៏ថ្ងៃស្អែកនោះ។ បាទសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណមេធាវី។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

[០៩:១០:៥១]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទជាការពិតណាស់ ដូចដែលលោក កាណាវាស បានលើកឡើងហើយ។ យើងបានប្រើបណ្តាញរបស់យើងនៅ កាលពីថ្ងៃសុក្រ ដើម្បីបញ្ចូលឯកសារដែលយើងចង់បង្ហាញ យើងប្រើប្រាស់ហើយយើងក៏បានបញ្ចូលនៅឯកសារមួយចំនួនទៀតនៅក្នុងចុងសប្តាហ៍នេះ ហើយខ្ញុំមិនដឹងដែរថាឯកសារទាំងអស់នេះមិនត្រូវបានជូនដំណឹងនោះទេ។ បើសិនជាចាំបាច់នោះ យើងអាចធ្វើការថតចម្លង

នៃបញ្ចើឯកសារនេះ ហើយនិងបញ្ជូនឲ្យភាគីទាំងអស់។ បាទសូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

លោកអាចបញ្ជាក់បានទេថា លោកបានបញ្ជូនឯកសារតាមមធ្យោបាយអី? ហើយឥឡូវខាងមេធាវីការពារក្តីមិនមានទេ អាចឲ្យអាសយដ្ឋានដែលលោកបញ្ជូនទៅឲ្យភាគីទេ នូវឯកសារដែលលោកអះអាងថា បានបញ្ជូនកាលពីថ្ងៃសុក្រ តាមប្រព័ន្ធអេឡិចត្រូនិក? ហើយថ្ងៃនេះអាចបំពេញបន្ថែមដោយអាចផ្តល់ជាឯកសារ ជាក្រដាស។

[០៩:១២:១០]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

តាំងពីពេលអង្គជំនុំជម្រះមិនឲ្យយើងប្រើតាមសារនេះ យើងបានប្រើ *អ៊ីនធ័រហ្វេស* ហើយយើងបានដាក់ឯកសារទាំងអស់ ដែលយើងចង់ប្រើនោះទៅក្នុង *អ៊ីនធ័រហ្វេស* របស់សហព្រះរាជអាជ្ញា ហើយខ្ញុំគិតថា នីតិវិធី បើតាមនីតិវិធី គឺថាក្រឡាបញ្ចើបញ្ជូនឯកសារទាំងអស់នេះ ទៅឲ្យភាគីទាំងអស់ ក៏ប៉ុន្តែយើងអាចថតចម្លងបាន ហើយបញ្ជូនឲ្យភាគីទាំងអស់ក្នុងពេលឥឡូវនេះ។

**ប្រធានអង្គជំនុំ៖**

បាទដោះស្រាយតាមស្ថានភាពជាក់ស្តែងទៅ ហើយប្រសិនបើតាមប្រព័ន្ធ *អ៊ីនធ័រហ្វេស* ហ្នឹងប្រហែលជាមិនទាន់បានជ្រួតជ្រាបទាំងអស់គ្នា អាចចាប់ផ្តើមជាបណ្តោះអាសន្ននេះ យើងអាចជូនឯកសារជាក្រដាសជូនគាត់។ ហើយជម្រាបភាគីថា ការអនុវត្តនេះ យើងនឹងប្រើប្រាស់តាមប្រព័ន្ធនេះ។

[០៩:១៣:១៤]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** អរុណសួស្តីសាក្សី តើលោកលោកឈ្មោះអ្វី?

**លោក សាឡុត បាន៖**

**ឆ៖** ខ្ញុំបាទ ឈ្មោះ បាន, ឡុត និត្យា, សួរ ហុង, បៀន ផាត, តាម៉ាឡៃ។

**ស៖** លោកប្រើឈ្មោះ បាន ហ្នឹងប្រើត្រកូលអីទៅ?

**ឆ៖** *(មិនឮសំឡេង)*

**ស៖** សាក្សីចាំមានភ្លើងក្រហមនៅក្បាល មីក្រូហ្នឹងសឹមលោកចាប់ផ្តើមនិយាយ ទើបអាច

និយាយឮ ហើយអាចចូលទៅក្នុងប្រព័ន្ធនៃការបកប្រែផងបាទ។

**ធ៖** សាឡុត បាន។

**ស៖** បាទ អរគុណ។ លោក សាឡុត បាន តើលោកមានអាយុប៉ុន្មានឆ្នាំហើយ?

[០៩:១៤:២៤]

**ធ៖** មកដល់ថ្ងៃនេះ អាយុ៦៧ឆ្នាំហើយ។

**ស៖** បាទអរគុណ។ តើលោកមានមុខរបររកស៊ីធ្វើអ្វីដែរសព្វថ្ងៃ?

**ធ៖** ខ្ញុំជាយោធាក្រសួងការពារជាតិ ថ្នាក់ឧត្តមសេនីយ៍ត្រី ចូលនិវត្តន៍ហើយ។

**ស៖** បាទអរគុណ។ តើទីលំនៅរបស់លោកសព្វថ្ងៃនៅទីកន្លែងណាដែរ?

[០៩:១៥:០៥]

**ធ៖** ទីលំនៅសព្វថ្ងៃ នៅម៉ាឡៃ។

**ស៖** បាទ អរគុណ។ តើឪពុកបង្កើតរបស់លោកឈ្មោះអ្វី?

**ធ៖** ឪពុកបង្កើតរបស់ខ្ញុំឈ្មោះ សាឡុត សេង។

**ស៖** អរគុណ។ ចុះម្តាយបង្កើតរបស់លោក?

**ធ៖** ម្តាយបង្កើតរបស់ខ្ញុំឈ្មោះ លឹម ហឹប។

**ស៖** លោកមានកូនប៉ុន្មាននាក់?

**ធ៖** ខ្ញុំមានកូនប្រាំនាក់។

[០៩:១៥:៤៥]

**ស៖** បាទ អរគុណ។ លោក សាឡុត បាន តាមរបាយការណ៍ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះថា តាមសមត្ថភាពដឹងរបស់លោកគឺលោកមិនមានឪពុកម្តាយជាបុព្វញាតិ កូន ឬក៏បច្ឆាញាតិ បងប្អូនប្រុសស្រី បងប្អូនថ្លៃ ប្រពន្ធត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តីនេះទេ ហើយក៏មិនជាប់ញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងបីនាក់ដែរ។ តើជាការត្រឹមត្រូវដែរទេ?

**ធ៖** ជាការត្រឹមត្រូវ។

**ស៖** បាទអរគុណ។ ហើយក្រឡាបញ្ជីបានរាយការណ៍ថាលោកបានធ្វើសម្បថរួចហើយមុននឹងចូលមកផ្តល់សក្ខីកម្មនេះ តើត្រឹមត្រូវទេ?

**ផ៖** បាទ ត្រឹមត្រូវ។

[០៩:១៦:៣៦]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ថ្ងៃនេះលោកបានចូលមកផ្តល់សក្ខីកម្មតាមការកោះហៅរបស់អង្គជំនុំជម្រះសាលាដំបូង ហើយនៅក្នុងរឿងនេះគឺលោកបានស្នើសុំឲ្យមានវត្តមានមេធាវីប្រឹក្សាលោកផងនៅក្នុងការឆ្លើយ។ ហើយថ្ងៃនេះ គឺខាងអង្គជំនុំជម្រះជាមួយនឹងអង្គភាពគាំពារសាក្សីអ្នកជំនាញ បានផ្តល់មេធាវីមួយរូបប្រឹក្សាក្នុងការឆ្លើយរបស់លោក។

ទន្ទឹមនឹងនេះអង្គជំនុំជម្រះសូមជម្រាបជូនអំពីសិទ្ធិ និងករណីយកិច្ចក្នុងនាមលោកជាសាក្សីដូចខាងក្រោមនេះ អំពីសិទ្ធិលោក សាឡុត បាន ក្នុងនាមលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬសុំឲ្យលោកធ្វើអំណះអំណាងណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង គឺសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯងរបស់សាក្សី។ មានន័យថា ដោយសារតែចម្លើយ ឬអំណះអំណាងរបស់លោកនោះនាំឲ្យលោកនឹងត្រូវប្រឈមនឹងការចោទប្រកាន់។ ហើយទន្ទឹមនឹងនេះ លោកក៏មានករណីយកិច្ចក្នុងការនាមសាក្សីត្រូវផ្តល់សក្ខីកម្មក្នុងកិច្ចដំណើរការនីតិវិធីសវនាការចំពោះមុខអង្គជំនុំជម្រះនេះ ដោយត្រូវឆ្លើយតបទៅនឹងសំណួរទាំងឡាយ ដែលភាគី ឬអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែក្នុងករណីសំណួរដែលលោកត្រូវឆ្លើយតបហ្នឹង តម្រូវឲ្យលោកធ្វើអំណះអំណាង ឬក៏ធ្វើអត្ថាធិប្បាយណាមួយច្រើន ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិនៅស្ងៀម-- សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។

[០៩:១៨:២៧]

ហើយក្នុងនាមលោកជាសាក្សី លោកត្រូវតែឆ្លើយតែកាលណាដែលពិត ដែលខ្លួនបានដឹង បានឮ បានឃើញ ធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬក៏ធ្វើការអង្កេតកន្លងមកដោយផ្ទាល់នូវបញ្ហាព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធទៅនឹងសំណួរ។

លោកយល់ទេ?

**លោក សាឡុត បាន៖**

បាទ យល់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយថ្ងៃនេះ គឺលោកមានមេធាវីប្រឹក្សាហើយ ហើយមេធាវីប្រឹក្សា គឺអង្គជំនុំជម្រះសូមរំឭកឡើងវិញថា នៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការនេះ គឺមេធាវីប្រឹក្សា គឺមានភារកិច្ចនៅក្នុងប្រឹក្សាយោបល់ចំពោះសំណួរទាំងឡាយ ឬក៏ការស្នើសុំរបស់ភាគី ឬអង្គជំនុំជម្រះឲ្យសាក្សីធ្វើអំណះអំណាង ឬក៏ឆ្លើយនៅសំណួរណាដែលទំនងជាដាក់ពិរុទ្ធភាពទៅលើខ្លួនសាក្សី។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ នេះជាភារកិច្ចរបស់មេធាវី ហើយប្រសិនបើជួបប្រទះនូវបញ្ហាទំនងជាមានខ្លឹមសារនៃសំណួរ ឬក៏ការសុំធ្វើអំណះអំណាងណាមួយនោះ គឺប្រសិនបើជួបស្ថានភាពដូច្នេះ គឺលោកអាចស្នើសុំដើម្បីពិភាក្សាជាមួយនឹងសាក្សី ដើម្បីសម្រេចចិត្តថា តើត្រូវឆ្លើយ ឬក៏មិនឆ្លើយតបទៅនឹងសំណួរ ឬក៏ការស្នើសុំឲ្យធ្វើអំណះអំណាងនោះ។

ជាកិច្ចបន្តអង្គជំនុំជម្រះសូមជម្រាបថា-- សូមជម្រាបជូនតំណាងសហព្រះរាជអាជ្ញាថា ក្នុងកិច្ចដំណើរការសវនាការពិភាក្សាដេញដោល ស្តាប់សក្ខីកម្មរូបនេះ អង្គជំនុំជម្រះនឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាតាំងសំណួរសដេញដោលចំពោះសាក្សីរូបនេះមុនភាគីឯទៀត។

អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា សូមអញ្ជើញ!

**លោក ច័ន្ទ តារាស្នើ៖**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម សូមគោរពអង្គសវនាការទាំងមូល។ នៅពេលនេះ ក្នុងនាមតំណាងសហព្រះរាជអាជ្ញាសូមអនុញ្ញាត ដើម្បីសួរសំណួរមួយចំនួនជូនលោកសាក្សី។

[០៩:២០:៥៧]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ច័ន្ទ តារាស្នើ៖**

**ស៖** សូមជម្រាបសួរ លោកសាក្សី។ បាទ ខ្ញុំសួរលោកទៅលើសំណួរមួយចំនួនដែលពាក់ព័ន្ធទៅនឹងអ្វីដែលបានកើតមាន អ្វីដែលលោកបានដឹងឮនៅក្នុងអតីតកាល។ ជាដំបូង ខ្ញុំសូមសួរទាក់ទងទៅនឹងប្រវត្តិផ្ទាល់ខ្លួនរបស់លោក។ តើឪពុករបស់លោកត្រូវជាបងប្រុស ឬជាប្អូនប្រុសរបស់លោកសាឡុត ស ដែរឬទេ? ឬក៏មិនមែន?

**លោក សាឡុត បាន៖**

**ឆ៖** ត្រូវជា ឪពុករបស់ខ្ញុំត្រូវជាបងប្រុសបង្កើតរបស់លោកមា សាឡុត ស។

**ស៖** អរគុណ។ ខ្ញុំសូមសួរថា បន្តទៀត តើឪពុករបស់លោកប្រកបមុខរបរអ្វី?

**ឆ៖** ជាកសិករ។

**ស៖** អរគុណ។ ចុះម្តាយរបស់លោកប្រកបមុខរបរអ្វីដែរបាទ?

**ឆ៖** ជាកសិករ។

[០៩:២២:០៥]

**ស៖** បាទអរគុណ។ បើផ្អែកលើចលនាបដិវត្តន៍ ឬក៏បក្សកុម្មុយនីស្តកម្ពុជា តើក្នុងស្ថានភាពនោះ លោកស្ថិតនៅក្នុងវណ្ណភាពណាមួយ?

**ឆ៖** ខ្ញុំស្ថិតនៅក្នុងវណ្ណភាពជាសិស្ស។

**ស៖** ចាប់ផ្តើមពីកើតមានចលនាបដិវត្តន៍ ខ្ញុំចង់ដឹងថា តើក្នុងវណ្ណៈកម្មករ កសិករ សក្តិភូមិ វណ្ណៈមូលធន ឬក៏វណ្ណៈនាយទុន។ តើលោកមានស្ថិតនៅក្នុងវណ្ណៈណាមួយ នៅក្នុងចំណោមវណ្ណៈទាំងអស់នេះដែរឬទេ បាទ?

**ឆ៖** ខ្ញុំស្ថិតនៅក្នុងចំណោមវណ្ណៈកសិករ។

**ស៖** អរគុណ។ តើក្នុងឋានៈជាក្មួយរបស់លោក ប៉ុល ពត។ ចំណុចនេះ តើវាអាចជះឥទ្ធិពលទៅលើការកំណត់វណ្ណៈភាពរបស់លោកដែរឬទេ នៅក្នុងសម័យកាលនោះ?

[០៩:២៣:១៧]

**ឆ៖** ក្នុងសម័យកាលនោះ ប៉ុល ពត មិនជះឥទ្ធិពលវណ្ណភាពមកលើរូបខ្ញុំទេ។

**ស៖** បាទ សូមអរគុណ។ តើនៅក្នុងរបបនោះ ការជាប់សាច់ញាតិរវាងលោកជាមួយនឹងសាច់ញាតិលោក ប៉ុល ពត ក្នុងនាមជាមេដឹកនាំកាលសម័យនោះ។ តើបានជួយការពារអ្វីខ្លះដល់រូបលោកបាទ?

**ឆ៖** ក្នុងសម័យនោះ ខ្ញុំជានីរសារ ដាំបាយ និងធ្វើពេទ្យ។

**ស៖** បាទ សូមអរគុណ។ តើលោកមាន--

**ឆ៖** មិនមែន សូមទោស ពេទ្យហ្នឹងគឺមិនមែនពេទ្យអីមានសញ្ញាប័ត្រអីទេ គ្រាន់តែចេះចាក់ថ្នាំអីបន្តិចបន្តួចទេណាបាទ។ ថាពេទ្យវាដូចជាធំពេក។

**ស៖** ដោយសារតែចំណងសាច់ញាតិរវាងលោកជាមួយនឹងលោក ប៉ុល ពត មានន័យថា បានការពារដល់រូបលោកក្នុងស្ថានភាពបែបណាខ្លះ ក្នុងសម័យនោះ?

**ឆ៖** ខ្ញុំមិនមែនជំនាញខាងការពារទេ មិនបានរៀនទេ ប៉ុន្តែយកសេចក្ដីស្មោះត្រង់ទៅការពារ។

**ស៖** សូមអរគុណ។ ខ្ញុំសូមសួរបន្តថា តើលោកមានបងប្អូនប៉ុន្មាននាក់? ស្រីប៉ុន្មាន? ប្រុសប៉ុន្មាន?

[០៩:២៥:០៣]

**ឆ៖** ខ្ញុំមានបងប្អូនប្រាំបួននាក់។ ស្រីពីរ ប្រុសប្រាំបី។ ក្នុង-- ម្ដាយដើមរបស់ខ្ញុំ ម្ដាយខ្ញុំ ម្ដាយដើមមានបងប្អូនបីនាក់ ខ្ញុំស្ថិតនៅក្នុងម្ដាយដើម ប្រុសបាទ។ ម្ដាយចុងទីពីរ អ៎ ម្ដាយចុងទីមួយ មានកូនម្នាក់ប្រុស។ ម្ដាយចុងទីបី មានកូនប្រាំមួយនាក់ ប្រុសពីរ ស្រីបួន អ៎ នែ៎! ស្រីពីរ ប្រុសបួន។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

លោកតំណាងអយ្យការ សូមលោករៀបចំនូវសំណួរចូលទៅសំណួរសារធាតុ។ សំណួរបឋមពាក់ព័ន្ធជាមួយនឹងអត្តសញ្ញាណរបស់សាក្សី មិនចាំបាច់ស៊ីជម្រៅនោះឡើយ។ ហើយវាមិនមានពាក់ព័ន្ធអ្វីទៅបងប្អូនបង្កើតរបស់គាត់ ដែលមានតម្លៃក្នុងការពិចារណានៅក្នុងកិច្ចដំណើរការរឿងក្ដីនេះទេ។ សូមលោកគិតគូរអំពីការប្រើប្រាស់ពេលវេលា ធ្វើម៉េចឲ្យពេលវេលាហ្នឹងប្រើប្រាស់ទៅមានប្រសិទ្ធភាពចៀសវាងការតាំងសំណួរដែលឥតបានការ។

[០៩:២៦:៤៦]

**លោក ច័ន្ទ តារាស្មី៖**

អរគុណលោកប្រធាន។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** លោកសាក្សី ខ្ញុំសូមសួរបន្តទៀត។ តើលោក សេង លីថេង ហៅថេង ជាអ្នកណាដែរ? ហើយគាត់ត្រូវជាអ្វីនឹងលោក បាទ?

**លោក សាឡុត បាន៖**

**ឆ៖** សេង លីថេង ជាប្អូនបង្កើតរបស់ខ្ញុំ។

**ស៖** តើលោកបានដឹងថា គាត់បានធ្វើអ្វី នៅមុនឆ្នាំ១៩៧៥?

**ឆ៖** មុនឆ្នាំ១៩៧៥ ខ្ញុំឮថា ធ្វើ ចូលទៅធ្វើកងទ័ពយៀកណាម។

**ស៖** អរគុណ។ តើរូបគាត់មានឈ្មោះអ្វីក្រៅពីឈ្មោះ ថេង នេះបាទ?

**ឆ៖** ឈ្មោះ ពន្នី។

**ស៖** បាទ អរគុណ។ តើគាត់ធ្លាប់ធ្វើការនៅមន្ទីរ ក-១ ដែរឬទេ?

**ឆ៖** គាត់ធ្លាប់នៅមន្ទីរ ក-១ ប៉ុន្តែមិនដឹងការងារអី។

**ស៖** បាទ អរគុណ។ តើគាត់ធ្លាប់មានទំនាក់ទំនងជាមួយនឹងលោក ប៉ុល ពត, លោក អៀង សារី, លោក នួន ជា ឬក៏លោក ខៀវ សំផន ដែរឬទេ?

**ឆ៖** គាត់អាចទាក់ទង ក៏ប៉ុន្តែមិនដឹងទាក់ទងរឿងអី។

[០៩:២៨:៥១]

**ស៖** បាទ អរគុណ។ តើនៅក្នុងសម័យខ្មែរនោះ លោកជួបបងប្អូនរបស់លោក ឈ្មោះ ថេង ហ្នឹង ញឹកញាប់ដែរឬទេ?

**ឆ៖** ក្នុងសម័យនោះ មិនបានជួប ថេង នេះញឹកញាប់ទេ។

**ស៖** ខ្ញុំសូមអនុញ្ញាត ថាតើលោកស្គាល់ឈ្មោះ ជួ ឆេង ដែរឬទេ? ជួ ឆេង បាទ?

**ឆ៖** ជួ ឆេង ហ្នឹង ភេទប្រុស ឬភេទស្រី?

**ស៖** ជួ ឆេង ហ្នឹង គឺភេទប្រុស បាទ?

**ឆ៖** អត់ស្គាល់ទេ។

**ស៖** បាទ អរគុណ។ ខ្ញុំសូមអនុញ្ញាតសួរសំណួរបន្តទាក់ទងនឹងការងាររបស់លោក។ តើលោកអាចរៀបរាប់អំពីប្រវត្តិត្រួសៗទាក់ទងទៅនឹងប្រវត្តិការងារ ក៏ដូចជាការសិក្សា។ ជាដំបូង ខ្ញុំសូមចាប់ទាក់ទងនឹងការសិក្សា។ តើការសិក្សារបស់លោកបានរៀនដល់ថ្នាក់ណា កម្រិតណាដែរ បាទ? ហើយមុខជំនាញអ្វី បាទ?

[០៩:៣០:០៥]

**ឆ៖** ការសិក្សារបស់ខ្ញុំ ប្រឡងចូលវិទ្យាល័យធ្លាក់។ ប្រឡងឌីប្លូមក៏ធ្លាក់ មានប៉ុណ្ណឹងបាទ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមសួរសំណួរទាក់ទងនឹងបញ្ហារឿងក្នុងរបបខ្មែរក្រហមហ្នឹង។ តើបានដឹងថា ប៉ុល ពត បានចាកចេញពីកម្ពុជាទៅមន្ទីរ១០០ នៅព្រំដែនវៀតណាមដែរឬទេ នៅក្នុងមេសា ឆ្នាំ១៩៦៣?

**ធ៖** ខ្ញុំអត់បានដឹងទេ។

**ស៖** បាទ តើនៅក្នុងរបបសីហនុ តើលោកមានដែលទទួលរងការរំខាននានាខាងវិស័យយុត្តិធម៌ដែរឬទេ?

**ធ៖** ខ្ញុំជាប់គុកងងឹតដប់ថ្ងៃ សម្តេចតាដោះលែងខ្ញុំ។

**ស៖** តើ ប៉ុល ពត ជាអ្នកដែលបាននាំលោកចូលបដិវត្តន៍ខ្មែរក្រហមដែរឬទេ? តាំងពីឆ្នាំ លោកមានអាយុ១៣ឆ្នាំកាលពីសម័យនោះ?

**ធ៖** ប៉ុល ពត អត់នាំខ្ញុំចូលបដិវត្តន៍ទេ។

**ស៖** បាទ នៅមុនពេលដែលមានចលនាបដិវត្តន៍កើតឡើងក្នុងសម័យនោះ តើលោកកំពុងកាន់មុខតំណែងជាអ្វី ឬក៏គ្មានមុខតំណែងទេក្នុងសម័យនោះ? ហើយនៅទីតាំងណា? នៅកន្លែងណាបាទ?

**ធ៖** ចូលបដិវត្តន៍ មុខតំណែងខ្ញុំជាកងការពារ កន្លែងជាច្រើនខ្ញុំមិនចាំអស់ទេ ចល័តរហូត។

[០៩:៣២:៤០]

**ស៖** បាទ នៅក្នុងឆ្នាំ១៩៦៧ លោកមានមុខរបរអ្វីនៅភ្នំពេញបាទ?

**ធ៖** ៦៧ ខ្ញុំមានមុខរបរច្រើន។ ទីមួយ ធាក់ស៊ីក្លូ។ ទីពីរ កម្មករសំណង់កំប៉ិកកំប៉ុក ប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ នៅពេលដែលលោកបានចាកចេញពីទីក្រុងភ្នំពេញ តើលោកទៅទីណាដែរ?

**ធ៖** ចាកចេញពីទីក្រុងភ្នំពេញ ដោយការចោទប្រកាន់ថា ខ្ញុំក្បត់ជាតិ ដោយខាង លន់ នល់ ចោទប្រកាន់ ចេញពីគុកទៅ ខ្ញុំជម្លៀសរត់ពួននៅភ្នំពេញ។ របររកស៊ីរបស់ខ្ញុំធាក់ស៊ីក្លូ យប់ ពេលយប់ខ្លាចពេលថ្ងៃគេស្គាល់មុខ។ ហើយបន្ទាប់ពីនេះ ខ្ញុំក៏ទៅនៅខេត្តក្រចេះ នៅក្នុងស្រុកស្នួល និងស្រុក នែ៎ គេហៅថា អូរគ្រៀង នៅអូរគ្រៀង បាទក្បាលដំរីក្នុងខេត្តក្រចេះ។

**ស៖** បាទ សូមអរគុណ។ តើនៅខេត្តក្រចេះលោកបានរស់នៅជាប់ជាមួយនឹងលោក ប៉ុល ពត ដែរឬទេនៅគ្រានោះបាទ?

**ធ៖** ខ្ញុំអត់ជាប់នឹង ប៉ុល ពត ទេ។

**ស៖** តើនៅទីនោះលោកបានជួបមេដឹកនាំដទៃទៀតណាខ្លះនៅខេត្តក្រចេះនោះ?

[០៩:៣៥:០០]

**ធ៖** នៅខេត្តក្រចេះ ខ្ញុំបានជួបអ្នកដឹកនាំឈ្មោះ ឌឿន។

**ស៖** បាទ លោក ឌឿន គឺជានរណា?

**ឆ៖** ខ្ញុំអត់ដឹងប្រវត្តិរូបទេ។

**ស៖** តើគាត់មានមុខតំណែងជាអ្វីលោក ឌឿន ពេលនោះ?

**ឆ៖** ខ្ញុំអត់ដឹងទេ។

**ស៖** បាទ តើលោករស់នៅខេត្តក្រចេះដល់ពេលណាដែរ?

**ឆ៖** ខ្ញុំរស់នៅខេត្តក្រចេះ ៦៦, ៦៧ បាទ។

**ស៖** បាទសូមអរគុណ។ តើលោកបានដឹងទេថា មេដឹកនាំមិនបានទៅកាន់រតនគិរីនៅមុនឆ្នាំ ១៩៦៩ មែនដែរឬទេ? មេដឹកនាំសម័យនោះមិនបានទៅកាន់ខេត្តរតនគិរីនៅមុនឆ្នាំ១៩៦៩ តើលោកបានដឹងចំណុចនេះដែរឬទេ បាទ?

**ឆ៖** ខ្ញុំអត់ដឹងទេ។

**ស៖** បាទ សូមអរគុណ។ តើលោកបានជួបមេដឹកនាំដទៃទៀតណាខ្លះនៅពេលដែលលោកនៅខេត្តរតនគិរី?

[០៩:៣៦:២៨]

**ឆ៖** ខ្ញុំជួបឪពុកមាខ្ញុំ សាឡុត ស, សុន សេន លោក សុន សេន, លោក អៀង សារី និង អ្នកស្រី អៀង ធីរិទ្ធ។

**ស៖** បាទសូមអរគុណ។ តើលោកមានបានជួបអ្នកដឹកនាំផ្សេងទៀតក្រៅពីលោកមេដឹកនាំដែលលោកបានបញ្ជាក់អម្បាញ់មិញដែរឬទេ?

**ឆ៖** ក្រៅពីនេះមិនដែលបានជួបទេ។

**ស៖** សូមអរគុណ។ តើលោកបានដឹងទេថា អស់លោកដែលលោកបានជួបហ្នឹង គាត់ជាសមាជិកគណៈមជ្ឈិមបក្ស ឬក៏គណៈអចិន្ត្រៃយ៍បក្សនៅក្នុងនោះ?

**ឆ៖** អត់ដឹងអ្វីទាំងអស់។

**ស៖** សូមអរគុណ។ តើលោក អៀង សារី មានទំនងជាមួយនឹង ប៉ុល ពត យ៉ាងម្តេចនៅសម័យនោះ?

[០៩:៣៧:៥៥]

**ឆ៖** អត់ដឹងទាំងអស់។

**ស៖** បាទ សូមអរគុណ។ នាពាក់កណ្តាលទី-- នាពាក់កណ្តាលនៃទសវត្សរ៍ឆ្នាំ១៩៦០ ៗតើភរិយារបស់លោក ប៉ុល ពត និងលោក អៀង សារី រស់នៅជាមួយគាត់ក្នុងព្រៃម៉ាគីនោះដែរឬទេ? លោកបានដឹងចំណុចនេះដែរឬទេបាទ? ភរិយារបស់លោក ប៉ុល ពត និងភរិយារបស់លោក អៀង សារី តើគាត់រស់នៅជាមួយគ្នាក្នុងព្រៃម៉ាគីនោះដែរឬទេ? នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ៦០?

**ឆ៖** ខ្ញុំដូចជាឃើញនៅជាមួយគ្នាបាទ។

**ស៖** បាទ តើនៅពេលនោះគាត់ប្រើប្រាស់ឈ្មោះអ្វីនៅក្នុងពេលដែលរស់នៅក្នុងព្រៃម៉ាគីនោះ?

**ឆ៖** តាមខ្ញុំចាំដូចជាឈ្មោះ ភា។

**ស៖** ឈ្មោះ ភា គឺឈ្មោះសម្រាប់បុគ្គលណាបាទ?

**ឆ៖** លោកស្រី អៀង ធីរិទ្ធ។

**ស៖** បាទ។ ចុះអ្នកផ្សេងទៀតបាទ មានឈ្មោះក្រៅប្រើប្រាស់នៅក្នុងពេលនោះដែរឬទេ?

**ឆ៖** លោក អៀង សារី ឈ្មោះ វ៉ាន់។

**ស៖** បាទ លោកមានដឹងហេតុផលទេថា តើហេតុអ្វីបានជាគាត់ប្តូរឈ្មោះនៅពេលនោះ?

**ឆ៖** ខ្ញុំអត់ដឹងហេតុផល។

**ស៖** បាទសូមអរគុណ។ តើលោកបានដឹងថាអ្នកទាំងពីរជាសាច់ញាតិនឹងគ្នាទេនៅសម័យនោះ?

[០៩:៤០:០៧]

**ឆ៖** ខ្ញុំដឹងថាជាសាច់ញាតិ។

**ស៖** តើលោកអាចបញ្ជាក់បានទេថា ការគោរព ការស្រឡាញ់ អៀង សារី នៅក្នុងសម័យខ្មែរក្រហមនោះ ដូចគ្នាទៅនឹងការគោរព និងការស្រឡាញ់ចំពោះ ប៉ុល ពត ដូចគ្នា? មានន័យថាការស្រឡាញ់ចំពោះ អៀង សារី និងការគោរពស្រឡាញ់ចំពោះ ប៉ុល ពត មានន័យដូចគ្នានឹងការ-- ក្នុងសម័យខ្មែរក្រហមនោះ។ តើករណីនេះ លោកបានដឹងថាពិតមែនដែរឬទេ?

**ឆ៖** ពិត បាទពិតមែន។

**ស៖** បាទ សូមបន្តសួរលោកតទៅទៀត។ ហេតុដូចម្តេចបានជា ប៉ុល ពត, អៀង សារី, និង សុន សេន បានសម្រេចបោះទីតាំងនៅក្នុងខែរតនគិរី?

**ឆ៖** ខ្ញុំអត់ដឹងហេតុផល។

[០៩:៤១:១២]

**សៈ** បាទ តើពួកគាត់បានទៅរស់នៅក្នុងភូមិឈ្មោះអ្វីនៅក្នុងខេត្តរតនគិរី?

**ឆៈ** ភូមិនោះជាភូមិរបស់ជនជាតិ ខ្ញុំពិបាកចាំ ខ្ញុំភ្លេច។

**សៈ** បាទ តែពេលក្រោយមកទៀត តើលោកមានបានចាំឈ្មោះហ្នឹងទេ? គេមានប្តូរឈ្មោះមកភូមិថ្មីផ្សេងមួយទៀត តើលោកមានបានចាំឈ្មោះថ្មីទៀតទេបាទ?

**ឆៈ** បាទ ខ្ញុំបាទអត់ដឹងទេ ព្រោះខ្ញុំអត់បានគិតដល់។

**សៈ** សូមអរគុណ។ តើពួកគាត់ធ្វើការនៅមន្ទីរណាខ្លះនាសម័យនោះ នៅក្នុងខេត្តរតនគិរី?

**ឆៈ** ខ្ញុំភ្លេចលេខអស់ហើយ។

**សៈ** សូមអរគុណ។ តើលោកមានធ្លាប់ឮគេនិយាយអំពីមន្ទីរ១០០ ដែរឬទេបាទ?

**ឆៈ** ខ្ញុំធ្លាប់ឮ។

**សៈ** តើមន្ទីរ១០០ មានន័យដូចម្តេច លោកអាចបញ្ជាក់បានទេ បាទ?

**ឆៈ** ខ្ញុំអត់ដឹងន័យមន្ទីរ១០០យ៉ាងម៉េចទេ។

**សៈ** សូមអរគុណ។ តើមន្ទីរ-- លោកមានបានឮគេនិយាយមន្ទីរ១០២ ទេបាទ? តើមន្ទីរ១០២ហ្នឹងលោកស្គាល់ទេ ហើយមានន័យដូចម្តេច?

[០៩:៤២:៤៥]

**ឆៈ** ១០២ ខ្ញុំស្គាល់ដែរ មិនមានដឹងន័យយ៉ាងម៉េចទេ។

**សៈ** តើនៅទីនោះលោកបានឃើញលោក នួន ជា ដែរឬទេ?

**ឆៈ** ខ្ញុំឃើញលោក នួន ជា ម្តងដែរ តាមខ្ញុំចាំបាទ។

**សៈ** ឃើញគាត់នៅកន្លែងណាបាទ?

**ឆៈ** ដូចជានៅមន្ទីរ១០០។

**សៈ** តើលោកបានទេ ថាគាត់ទៅទីនោះក្នុងគោលបំណងអ្វី?

**ឆៈ** ខ្ញុំដឹងថាគោលបំណងធ្វើបដិវត្តន៍ ដេញចក្រពត្តិអាមេរិកតែប៉ុណ្ណឹង។

[០៩:៤៣:៤៤]

**សៈ** អរគុណបាទ។ តើលោកបាន លោកអាចបញ្ជាប់បានទេថាតើអ្នកណាជាលេខាមន្ទីរ១០០?

**ឆៈ** ខ្ញុំអត់ដឹង។

**សៈ** ចុះមន្ទីរ១០២ តើនរណាគេជាលេខាមន្ទីរ១០២?

**ឆ៖** ខ្ញុំក៏អត់ដឹង។

**ស៖** សូមអរគុណ។ តើលោកអាចបញ្ជាក់បានទេ ហេតុអ្វីបានគេបង្កើតមន្ទីរ១០០ និង១០២នេះកើតឡើងនៅខេត្តនោះ?

**ឆ៖** ខ្ញុំអត់ដឹងហេតុផល។

**ស៖** សូមអរគុណ។ តើលោកជាសមាជិកបក្សកុម្មុយនីស្តកម្ពុជាដែរឬទេ នាសម័យនោះ?

**ឆ៖** សម័យណាលោក?

**ស៖** សម័យខ្មែរក្រហម កម្ពុជាប្រជាធិបតេយ្យ បាទ?

[០៩:៤៥:០៤]

**ឆ៖** ខ្ញុំជាបក្ខជន។

**ស៖** បាទ បើលោកជាបក្ខជន តើលោកបានចូលសមាជិកបក្សចាប់តាំងពីពេលណាបាទ?

**ឆ៖** ១៩៦៨។

**ស៖** បាទសូមអរគុណ។ ដើម្បីបានចូលជាសមាជិកបក្ស នៅក្នុងសម័យកាលនោះ តើលោកគេតម្រូវឱ្យលោកបំពេញបែបបទយ៉ាងដូចម្តេច?

**ឆ៖** អត់មានបែបបទអីទេ។

**ស៖** បាទសូមអរគុណ។ ហេតុអ្វីបានជាលោកចូលបក្សក្នុងសម័យនោះ ក្នុងបំណងអ្វីសំខាន់បាទ?

[០៩:៤៦:០៩]

**ឆ៖** បំណងចង់រំដោះប្រទេស ឲ្យចាករួចផុតពីពួកចក្រពត្តិនិយមអាមេរិក។

**ស៖** បាទសូមអរគុណ។ ចាប់តាំងពីឆ្នាំ១៩៦៩មក តើបក្សមានបានចូលរួមក្នុងការតស៊ូ ដោយអាវុធប្រឆាំងនឹងអំណាចមជ្ឈិមដែរឬទេ?

**ឆ៖** ខ្ញុំអត់យល់សំណួរ។

**ស៖** ខ្ញុំចង់សួរថាតើចាប់តាំងពីឆ្នាំ១៩៦៩មក បក្សបានធ្វើចលនាតស៊ូដោយអាវុធ អ៊ីចឹងការតស៊ូដោយអាវុធនេះគឺ ធ្វើឡើងក្នុងការប្រឆាំងទៅនឹងនរណា? ហើយក្នុងទ្រង់ទ្រាយយ៉ាងដូចម្តេច?

**ឆ៖** ខ្ញុំ--

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ខ្ញុំសូមជំទាស់សំណួរមួយនេះ។ សូមអភ័យទោស ដោយសារថាខ្ញុំនិយាយភ្លាម។ នៅពេលនេះគឺថា យើងឃើញថា សំណួរនាំមុខជាច្រើនគឺថា ហើយខ្ញុំត្រូវតែជំទាស់ ហើយសូមឱ្យលោកប្រធានណែនាំសហព្រះរាជអាជ្ញាកុំឱ្យសួរសំណួរនាំមុខ ដោយថាគាត់និយាយពីអង្គហេតុជម្រាបទៅសាក្សី ហើយឱ្យអង្គហេតុបញ្ជាក់។ ដូច្នេះ នេះជាលក្ខខណ្ឌដើម្បីឱ្យសហព្រះរាជអាជ្ញាមុននឹងតាំងសំណួរនោះគឺថា ត្រូវពិចារណាចំណុចនេះ។ សូមអរគុណលោកប្រធាន។

[០៩:៤៧:៤៨]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ សេចក្តីជំទាស់របស់លោកមេធាវីមានប្រសិទ្ធភាព។ សាក្សីមិនចាំបាច់ឆ្លើយតបនឹងសំណួរចុងក្រោយ ដែលសួរដោយតំណាងសហព្រះរាជអាជ្ញាទេ ពីព្រោះជាសំណួរនាំមុខ។

**លោក ច័ន្ទ តារាស្មី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមបន្តសំណួរថ្មី។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** នៅពេលដែលលោករស់នៅខេត្តរតនគិរី តើលោកត្រូវបានគេអប់រំ ឬក៏បំពាក់បំប៉នមនោគមន៍វិជ្ជានយោបាយដែរឬទេបាទ?

**លោក សាឡុត បាន៖**

**ឆ៖** ពេលនោះខ្ញុំអត់យល់ទេ មនោគមន៍វិជ្ជា ប៉ុន្តែបានបំពាក់បំប៉ននូវឯកសារ ឯកសារសំខាន់គឺឯកសារ នៃសាមគ្គីជនជាតិក្រោមទង់បដិវត្ត។

**ស៖** បាទឯកសារមួយនេះ បាទមានន័យយ៉ាងដូចម្តេចចំពោះជនជាតិភាគតិចនៅក្នុងតំបន់ ខេត្តរតនគិរី ជាពិសេសតំបន់ភូមិភាគឦសានបាទ?

[០៩:៤៩:៣២]

**ឆ៖** ខ្ញុំយល់ឃើញថា ឯកសារនេះ ជាឯកសារ ដែលមានសារៈសំខាន់ចំពោះខ្ញុំ ក្នុងការចងក្រងសាមគ្គីជនជាតិក្រោមទង់បដិវត្តដើម្បីរំដោះប្រទេស ទីមួយ។ ទីពីរ ឯកសារនេះបានបង្រៀនបងប្អូនជនជាតិភាគតិច ជាជនជាតិដែលក្រីក្រស្រទាប់ក្រោមគេ កុំឱ្យគេជិះក្បាល ហើយក៏ឱ្យមានប្រាជ្ញាកុំឱ្យគេជិះក្បាល ហើយក៏ឱ្យមានសីលធម៌ កុំទៅជិះក្បាលគេដែរ។

**ស៖** បាទ សូមអរគុណលោកសាក្សី។ តើនៅក្នុងពេលដែលមានការបោះពុម្ពឯកសារមួយនេះ ឯកសារមួយនេះវាសរសេរដោយដៃបាទ តាមឯកសារដែលបានបង្ហាញ។ តើលោកអាចបញ្ជាក់បានទេ អំពីពាក្យដែលប្រើប្រាស់ថា "ក្រុមយុទ្ធសាស្ត្រ ក្រុមយុទ្ធវិធី" មានន័យដូចម្ដេចនៅក្នុងឯកសារនោះ?

**ឆ៖** ខ្ញុំមិនអាចអត្ថាធិប្បាយមាត់ទទេបានទេ។ បើចង់ឲ្យខ្ញុំអធិប្បាយទាល់តែមានតាបឡូអីឲ្យខ្ញុំគូសវាស។

**ស៖** បាទ សូមអរគុណ។ តើនៅសម័យនោះ បក្សដាក់គោលនយោបាយយ៉ាងដូចម្ដេចចំពោះជំនឿ ការគោរពជំនឿសាសនារបស់ជនជាតិភាគតិចនៅតំបន់ភូមិភាគឦសាន?

[០៩:៥១:៣១]

**ឆ៖** គោរព និងកែលម្អនូវអ្វីដែលជាចំណុចខ្សោយរបស់បងប្អូនជនជាតិភាគតិច។

**ស៖** តើលោកអាចបញ្ជាក់បាន ប្រាប់បានទេថា តើអ្នកណាជាអ្នកប្រាប់ទៅខាងបងប្អូនជនជាតិភាគតិចឲ្យបោះបង់នូវជំនឿអរូបីចោល?

**ឆ៖** ខ្ញុំយល់ឃើញថា លើលោកនេះគ្មានអីជាអរូបីទេ គឺមានរូបីទាំងអស់។ ប៉ុន្តែយើងមើលមិនឃើញ មិនបានណែនាំទេ។ មានតែពន្យល់ មិនបង្ខំទេបាទ។ ឲ្យយល់អ៊ីចឹង។

**ស៖** សូមអរគុណ។ តើលោក ប៉ុល ពត តើសម័យនោះមានបានប្រើប្រាស់ឯកសារដដែរទៀតសម្រាប់បំពាក់បំប៉នមនោគមន៍វិជ្ជាចំពោះរូបលោក ដូចជា ទាក់ទិននឹងលក្ខន្តិកៈបក្សកុម្មុយនីស្ដកម្ពុជា ឬឯកសារដែលបោះពុម្ពផ្សាយដោយបក្សកុម្មុយនីស្ដកម្ពុជា ដូចជាទង់បដិវត្ត ឬក៏ទង់យុវជន យុវនារីបដិវត្តដែរឬទេបាទ?

[០៩:៥៣:០៤]

**ឆ៖** អាហ្នឹងវាមាននៅតាមសម័យកាល តើលោកចង់សួរសម័យកាលណា?

**ស៖** នៅពេលសម័យដែលលោកនៅក្បែរលោក ប៉ុល ពត នៅក្នុងចលនានៃការតស៊ូបដិវត្តនោះបាទ។

**ឆ៖** ការរៀនឯកសារ គឺតាម--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ។

សូមអញ្ជើញលោកមេធាវីជាតិការពារក្ដីលោក នួន ជា!

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន។ ខ្ញុំស្តាប់ឮច្រើនណាស់ ព្រះរាជអាជ្ញានិយាយមិនមានពេលវេលា និងកាលកំណត់។ អ៊ីចឹងនិយាយពាំត្រណោតរហូត ម្ល៉ោះហើយសូមលោកប្រធានមេត្តាប្រាប់ទៅព្រះរាជអាជ្ញា-- កាលណានិយាយពីរឿងពេលណាម្តង គឺត្រូវឲ្យថ្ងៃខែ ឬយ៉ាងតិចបំផុតមានឆ្នាំដែរ អាហ្នឹងបានវាទៅជាឯកសារពិតប្រាកដ។ ហើយចេះតែសួរពាសវាលពាសកាលអ៊ីចឹងអត់ទេ មិនដឹងជាពេលណាអីពេលណា។ សូមអរគុណ។

[០៩:៥៤:១៩]

**ប្រធានអង្គជំនុំ៖**

អរគុណ។ អំមិញបានសាក្សីគាត់ក៏បានពិបាកក្នុងការឆ្លើយតបដែរ ដោយសារតំណាងសហព្រះរាជអាជ្ញាជាតិតាំងសំណួរហ្នឹងវាអត់ដឹងអំឡុងពេល អំឡុងពេលណាបញ្ជាក់ច្បាស់។ ហើយគាត់បានរំឮកឡើងវិញហើយ ក៏ប៉ុន្តែក៏នៅតែមិនច្បាស់ដែរ។ អំឡុងពេលនៃការតស៊ូព្រៃម៉ាគីអី សូមយល់ឲ្យបានច្បាស់លាស់លើបញ្ហាខ្លឹមសារនៃពាក្យពេចន៍ ដែលគេប្រើនេះ ហើយនៅក្នុងសម័យកាលណាដែលគេប្រើពាក្យពេចន៍ទាំងអស់នេះ នៅក្នុងកិច្ចដំណើរការដែលមាននៅក្នុងឯកសារជាមូលដ្ឋានក្នុងការតាំងសំណួរ។

[០៩:៥៥:០០]

បាទសូមអញ្ជើញ! ហើយសូមអនុវត្តឲ្យបានត្រឹមត្រូវ ហើយឲ្យបានជាក់ច្បាស់ចៀសវាងការសួរទៅ សាក្សីគាត់សួរមកវិញ ព្រោះគាត់មិនដឹងឆ្លើយថាម៉េច ពីព្រោះមិនដឹងសួរអំឡុងពេលណាមួយ? ប្រសិនបើយើងបញ្ជាក់ច្បាស់ទៅ គឺជាការត្រឹមត្រូវ ទីមួយ។ ទីពីរ សូមរៀបចំនូវតាំងសំណួរ ការតាំងសំណួរឲ្យបានត្រឹមត្រូវ ចៀសវាងសំណួរបែបនាំមុខ ចង្អុលបង្ហាញនូវអង្គហេតុរួច ហើយបានសួរបញ្ជាក់សាក្សីដែរឬទេនោះ? មានន័យថា សំណួរនាំមុខហើយ។ ហើយម្យ៉ាងទៀតក៏គប្បីរៀបចំឲ្យបានត្រូវល្អដែរ លើការមនុស្សស្គាល់មនុស្ស ទាល់តែស្គាល់មនុស្សនោះសិន បានធ្លាប់ជួបមនុស្សហ្នឹងដែរឬទេ មិនដែលបានសួរ មិនដែលបានស្គាល់មនុស្សផង ហើយយើងទៅសួរ ស្គាល់មនុស្ស។

ឧទាហរណ៍ សាឡុត ស អ៊ីចឹង ហើយដល់ពេលសាក្សីសួរ សាឡុត ឆ្លើយថា សាឡុត ស ទេ ដល់ពេលចេញប៉ុល ពត វាមិនដឹងថា សាឡុត ស ហ្នឹង ប៉ុល ពត ឬយ៉ាងម៉េច? ហើយអ្នកណាជាអ្នកឆ្លើយថាអ៊ីចឹង? វាអត់ដឹងថាអ្នកណានិយាយថាអ៊ីចឹង ព្រោះថាយើងអត់ទាន់សួរសំណួរហ្នឹងផង ស្រាប់តែអត់បានចេញសាឡុត ស ទៀតទេ ស្រាប់តែចេញ ប៉ុល ពត នៅមណ្ឌលគីរី។

បាទ សូមអញ្ជើញ!

[០៩:៥៦:២២]

**លោក ច័ន្ទ តារាស្មី៖**

បាទ សមអរគុណលោកប្រធាន។ ខ្ញុំសូមអនុញ្ញាតបន្តសួរលោកសាក្សីជាបន្តទៀត។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** តើលោក ប៉ុល ពត បានបង្រៀនលោកទេអំពីកម្មវត្ថុចម្បងនៃការបង្កើតបក្សកុម្មុយនីស្ត កម្ពុជានាសម័យខ្មែរក្រហមនោះបាទ?

**លោក សាឡុត បាន៖**

**ឆ៖** អត់មានពេលទៀតហើយ។ គឺបានបង្រៀនតាមរយៈ តាមរយៈ តាមពេលវេលា។ អ្នកណាយល់ដឹងកម្រិតណា គឺឲ្យឯកសារផ្សេងៗពីគ្នា បាទ តាមថ្នាក់ តាមថ្នាក់យល់ដឹង។

**ស៖** សូមលោកជួយបញ្ជាក់អំពីទិសដៅធំៗរបស់បក្សកុម្មុយនីស្តកម្ពុជា ឬក៏មាគ៌ានយោបាយធំៗ របស់បក្សកុម្មុយនីស្តកម្ពុជា?

**ឆ៖** ខ្ញុំមិនមែនជាអ្នកស្ថាបនិកបក្សទេ ខ្ញុំអត់យល់ អត់ដឹង។

[០៩:៥៧:៥១]

**ស៖** តើនៅក្នុងផ្ទៃក្នុងបក្សកុម្មុយនីស្តកម្ពុជា មេដឹកនាំដទៃទៀតមានឯកភាពទៅលើទិសដៅ ទាំងអស់នោះរបស់បក្សកុម្មុយនីស្តកម្ពុជាដែរឬទេ? ឬក៏មានចំណុចមួយចំនួនត្រូវបានគេយកមក ពិភាក្សាដេញដោល តើចំណុចនោះ លោកអាចចាំបានទេ ថាមានចំណុចអ្វីខ្លះបាទ?

**ឆ៖** ចំពោះរឿងគេ ខ្ញុំមិនដឹងទេ ខ្ញុំដឹងតែពីរឿងផ្ទាល់ខ្លួនខ្ញុំ។

**ស៖** សូមអរគុណ។ តើវិន័យក្នុងបក្សកុម្មុយនីស្តកម្ពុជាបានកំណត់យ៉ាងដូចម្តេចខ្លះ?

**ឆ៖** ខ្ញុំចាំមិនអស់ទេ ប៉ុន្តែខ្ញុំចាំ គឺសីលធម៌១២ប្រការ។

[០៩:៥៨:៥៤]

**ស៖** សូមអរគុណ។ តើអ្នកដែលល្មើសនឹងវិន័យរបស់បក្សកុម្មុយនីស្តកម្ពុជាត្រូវបានគេដាក់ ទណ្ឌកម្មយ៉ាងដូចម្តេចបាទ?

**ឆ៖** ខ្ញុំមិនដឹង ទណ្ឌកម្មអីច្រើនទេ ប៉ុន្តែទណ្ឌកម្ម មិនដឹងជា មិនដឹងទណ្ឌកម្មទេ ប៉ុន្តែខ្ញុំដឹងគឺ រឿងកសាងខ្លួនដោយខ្លួនឯង និងកសាងដោយរួមកសាង។

**ស៖** បាទសូមអរគុណ។ នៅពេលដែលឪពុកមារបស់លោក ប៉ុល ពត បានចាកចេញពីប្រទេសកម្ពុជាទៅកាន់ប្រទេសចិន ដោយឆ្លងកាត់ប្រទេសវៀតណាម នៅក្នុងចន្លោះឆ្នាំ១៩៦៩ ដល់ឆ្នាំ១៩៧០ តើលោកបានទៅជាមួយគាត់ដែរឬទេ?

[១០:០០:០០]

**ឆ៖** ខ្ញុំមិនដឹងគាត់ទៅផង។

**ស៖** តើអ្នកណាជាអ្នកសម្រេចចិត្តអំពីកិច្ចការដែលពាក់ព័ន្ធនឹងការតស៊ូដោយអាវុធ ក្នុងអំឡុងពេលដែលលោក ប៉ុល ពត មិននៅក្នុងប្រទេស?

**ឆ៖** ខ្ញុំអត់បានដឹងទេ។

**ស៖** សូមអរគុណ។ តើនៅពេលណាដែលមន្ទីរគណៈមជ្ឈិមបានផ្លាស់ចេញពីខេត្តរតនគិរី?

**ឆ៖** គឺនៅពេលដែលរដ្ឋប្រហារហើយ។ រដ្ឋប្រហារលន់ នល់ ហើយ។

**ស៖** បាទ សូមអរគុណ។ តើមន្ទីរនេះបានផ្លាស់ទៅទីកន្លែងណាផ្សេងទៀតដែរឬទេ?

**ឆ៖** មន្ទីរនោះផ្លាស់ទៅព្រំដែនកំពង់ធំ កំពង់ចាម ហើយចល័តរហូត។

[១០:០១:៣០]

**ស៖** បាទ ហេតុដូចម្ដេចបានជាមន្ទីរគណៈមជ្ឈិមបានបោះទីតាំងនៅក្បែរស្ទឹងជីនីតនៅក្នុងខេត្តកំពង់ធំ?

**ឆ៖** ខ្ញុំមិនដឹងមូលហេតុអីធំដុំទេ គឺរក្សាការសម្ងាត់។

**ស៖** បាទ សូមអរគុណ។ តើលោកមានតួនាទីជាអ្វីនៅក្នុងពេលដែល ប៉ុល ពត និងមេដឹកនាំដទៃទៀតបានផ្លាស់ទៅរស់នៅក្បែរស្ទឹងជីនិតនោះ?

**ឆ៖** ខ្ញុំជាយុទ្ធជនធម្មតា។

**ស៖** តើលោកអាចបញ្ជាក់បានទេថា តើមេដឹកនាំណាខ្លះដែលនៅទីនោះ នៅស្ទឹងជីនិតនោះ?

**ឆ៖** ខ្ញុំឃើញលោក ប៉ុល ពត, លោក នួន ជា ក្រៅពីនោះ ទៅមកៗ មិនទៀងទាត់។

**ស៖** បាទ តើពួកគាត់ស្នាក់នៅទីកន្លែងតែមួយ ឬក៏ទីកន្លែងផ្សេងគ្នាក្នុងភូមិតែមួយ?

**ឆ៖** គ្មានភូមិទេ គឺនៅព្រៃ។ នៅជិតគ្នា ធ្វើខ្ទមមួយម្នាក់ៗ។

**ស៖** សូមអរគុណ។ តើលោកមានបានឃើញលោក ខៀវ សំផន នៅទីនោះដែរឬទេ?

**ឆ៖** ខ្ញុំចង់បញ្ជាក់ថាពេលណាដែល-- អត់ឮ!

**ប្រធានអង្គជំនុំ៖**

លោកអត់បើកក្បាលមីក្រូផង។

[១០:០៤:០៣]

**សួរដោយលោក ច័ន្ទ តារាស្រី៖**

**ស៖** បាទ ពេលវេលាដែលខ្ញុំសួរអំមិញគឺជាពេលវេលាដដែល ដែលទាក់ទងពេលដែលគាត់ផ្លាស់ទៅទីតាំងក្បែរស្ទឹងជីនិតហ្នឹងបាទ? ក្រោយរដ្ឋប្រហារហ្នឹងបាទ ឆ្នាំ១៩៧០ ក្រោយរដ្ឋប្រហារ លន់ នល់?

**លោក សាឡុត បាន៖**

**ឆ៖** ១៩៧០ ដូចខ្ញុំអត់ឃើញទេ អត់ទាន់ឃើញ។

**ស៖** នៅៗទីតាំងក្បែរស្ទឹងជីនិតហ្នឹង តើលោកអត់បានឃើញលោក ខៀវ សំផន នៅទីនោះទេបាទ?

**ឆ៖** ៧០ ខ្ញុំអត់ឃើញទេ។

**ស៖** សូមសួរ សូមអនុញ្ញាតសួរលោកបន្តទៀត។ តើមន្ទីរគណៈមជ្ឈិមធ្វើការញឹកញាប់ដែរឬទេ?

[១០:០៥:០៦]

**ឆ៖** ធ្វើការរបៀបណា ខ្ញុំមិនសូវយល់ដែរបាទ។ ធ្វើការហ្នឹងវាម្តេចប្អូនហ្នឹងវាធ្វើការរហូតហ្នឹង។

**ស៖** ន័យសំណួរខ្ញុំចង់សួរថា តើមន្ទីរគណៈមជ្ឈិមហ្នឹង បានធ្វើការកោះប្រជុំទាក់ទិននឹងកិច្ចការនយោបាយ មាគ៌ានយោបាយ កិច្ចការបក្ស ញឹកញាប់ដែរឬទេបាទ?

**ឆ៖** បាទ ថាញឹកញាប់ ក៏មិនថាបាន ស្រេចតែតម្រូវការរបស់គណៈដឹកនាំនៅនុ៎ង បាទ។

**ស៖** បាទ តើអ្នកណាខ្លះដែលជាសមាជិកមន្ទីរគណៈមជ្ឈិម និងជាសមាជិកគណៈអចិន្ត្រៃយ៍?

**ឆ៖** ការចាត់តាំង ខ្ញុំមិនលម្អិតទេបាទ។ ខ្ញុំស្គាល់តែមុខ ឯងារជាអីៗហ្នឹង ខ្ញុំមិនបានដឹងទេ។

**លោក ច័ន្ទ តារាស្រី៖**

លោកប្រធាន ខ្ញុំសូម មកដល់ត្រឹមកន្លែងនេះ ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន បើសិនជាលោកប្រធានមិនយល់ទាស់ទេ សូមអនុញ្ញាតដើម្បីបង្ហាញជូនរូបថតបីសន្លឹកនៅលើអេក្រង់កុំព្យូទ័រ។ ហើយខ្ញុំសូមប្រគល់រូបថតនេះដោយផ្ទាល់ ជាឯកសារជូនទៅលោកសាក្សី ដើម្បីពិនិត្យ។ ហើយនិងខ្ញុំនឹងសាកសួរសំណួរមួយចំនួនដែលទាក់ទិននឹងបញ្ហានេះ។ បើសិនជាលោកប្រធានអនុញ្ញាត។

[១០:០៦:៣៦]

**ប្រធានអង្គជំនុំ៖**

លោកបញ្ជាក់ផង រូបថតពីណាមក? រូបថតថ្មី ទើបយកមកដាក់ថ្មី? ឬក៏រូបថតនៅក្នុងសំណុំរឿងស្រាប់ហើយ? ហើយមានអត្តសញ្ញាណសម្គាល់រូបថតនុ៎ងដែរឬទេ?

**លោក ច័ន្ទ តារាស្មី៖**

បាទ លោកប្រធាន ខ្ញុំមានអត្តសញ្ញាណរូបថតនេះ គឺរូបថតមានលេខសម្គាល់ P00416593។ រូបថតមួយទៀត គឺ-- អ៎ សូមទោស E មួយទៀត បាទ E3/136។ សូមបង្ហាញជា E ផង ហើយនិងលេខរូបថតហ្នឹងផង។ សូមបញ្ជាក់ជូនម្តងទៀត E3/136។ P00416593។ រូបថតមួយទៀត D313/1.2.234 P00416590។ រូបថតទីបី គឺ E3/137 P00416592។ បាទ រូបថតបីសន្លឹកនេះ ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដើម្បីបង្ហាញនៅលើអេក្រង់ ហើយសូមបង្ហាញជូនទៅលោកសាក្សីដើម្បីពិនិត្យ ហើយខ្ញុំនឹងសាកសួរសំណួរមួយចំនួនចំពោះគាត់ បាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! អាច បុគ្គលិកជំនួយការដាក់បញ្ចាំងនៅលើអេក្រង់កុំព្យូទ័រ ហើយនិងមន្ត្រីរដ្ឋបាលតុលាការទទួលរូបថតពីតំណាងសហព្រះរាជអាជ្ញាជូនទៅសាក្សីពិនិត្យ។

[១០:០៨:២៦]

*(មន្ត្រីរដ្ឋបាលតុលាការយកឯកសារជូនសាក្សី)*

[១០:១០:៤៨]

**លោក ច័ន្ទ តារាស្មី៖**

បាទ សូមអនុញ្ញាតលោកដើម្បីសាកសួរសាក្សីបាទ។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** លោកសាក្សីលោកបានពិនិត្យរូបថតនេះហើយ ហើយខ្ញុំសូមអនុញ្ញាតសួរសាក្សីថា តើរូបថតនេះលោកបានឃើញ បានដឹងឮថា រូបថតនេះថតនៅកន្លែងណា? ហើយការថតនេះ គឺក្នុងទិដ្ឋភាពអ្វី? បាទសូមបង្ហាញបាទ សូមលោកពិនិត្យមើលរូបថតទីមួយ គឺខ្ញុំសូមឲ្យឆ្លើយរូបថតទីមួយ គឺរូបថតដែលមានអក្សរ E3/136ៗ រូបថតទីមួយបាទ ខ្ញុំសូមសួររូបថតទីមួយនេះសិនបាទ E3/136 P00416593។

**លោក សាឡុត បាន៖**

**ឆ៖** កន្លែងណាខ្ញុំអត់ច្បាស់ទេ ពីព្រោះក្នុងនេះអត់មានសរសេរ ហើយមិនដឹងជាធ្វើអីទៀត ខ្ញុំដឹងតែថា ជយោបក្សកុម្មុយនីស្តដ៏រុងរឿង! តែប៉ុណ្ណឹងបាទ អត់ដឹង។ អត់ដឹងធ្វើអី។

**ស៖** បាទរូបថតនេះ គឺតាមឯកសារ គឺជាឯកសារដែលថតនៅក្នុងមហាសន្និបាតលើកទីបីរបស់បក្សកុម្មុយនីស្តកម្ពុជា ឆ្នាំ១៩៧១។

**ឆ៖** ខ្ញុំអត់បានចាំទេបាទ។

**ស៖** បាទ ក្នុងកម្មវិធីនៃការប្រជុំមហាសន្និបាទនេះ តើលោកបានចូលរួមដែរឬទេ?

**ឆ៖** ខ្ញុំមិនបានចូលរួមទេ ហើយខ្ញុំក៏មិនដឹងថា ធ្វើអីដែរ។

[១០:១៣:១១]

**ស៖** បាទ រូបថតនេះ គឺលោកបានស្គាល់មនុស្សមួយចំនួននៅក្នុងរូបថតនេះដែរឬទេបាទ? លោកអាចមើលឃើញរូបថតនេះ ហើយលោកអាចស្គាល់ថា អ្នកណាខ្លះដែលថតនៅក្នុងទីនេះ? មានលោក ប៉ុល ពត, លោក នួន ជា, លោក អៀង សារី, លោក ខៀវ សំផន លោកស្គាល់ទេបាទ?

**ឆ៖** ក្នុងរូបថតនេះ ខ្ញុំច្បាស់តែមនុស្សណាដែលខ្ញុំធ្លាប់ឃើញជាញឹកញាប់ គឺក្នុងនេះមាន ឪពុកមាខ្ញុំ ប៉ុល ពត។

**ស៖** តើលោក ប៉ុល ពត ឈរនៅត្រង់ចំណុចណា? បាទ សូមលោកបង្ហាញបន្តិចបានទេបាទ?

លោកគ្រាន់តែនិយាយមក ហើយនៅក្នុងជួរណា? នៅចំណុចទីប៉ុន្មាន? ខាងឆ្វេងខាងស្តាំ? ឬក៏ជួរទីមួយទីពីរ? ឬឈរឬអង្គុយបាទ?

[១០:១៤:២៥]

**ឆ៖** ឈរនៅកៀនគេខាងក្រោយខាងស្តាំ។

**ស៖** សូមអរគុណ។ ចុះលោកស្គាល់ពីណាគេទៀត? អ្នកណាទៀតដែលលោកស្គាល់ច្បាស់បាទ?

**ឆ៖** ពីណាទៀតខ្ញុំស្រពេចស្រពិលហើយ ពីព្រោះភ្នែកក៏វាចាស់ផង ហើយក៏រូបនេះវាដូចជាមិនសូវច្បាស់។ ច្បាស់តែរូបរាងរបស់ឪពុកមាខ្ញុំតែប៉ុណ្ណោះ។

**ស៖** បាទ។ ខ្ញុំ ៗសូមសួរលោកថា តើលោកឃើញលោក នួន ជា ថាលោក នួន ជា នៅក្នុងថតនេះមានឃើញគាត់ទេបាទ លោក នួន ជា?

**ឆ៖** ខ្ញុំគ្រាន់តែប្រហែលទេណា ប្រហែល! ប្រហែលបង់កក្រមា។ ប៉ុន្តែអត់ច្បាស់ទេបាទ។

**ស៖** តាម៉ុកទេ? ស្គាល់រូប តាម៉ុក នៅក្នុងថតនេះលោកឃើញច្បាស់ទេបាទ? មានរូប តាម៉ុក ដែរឬទេ?

**ឆ៖** ដូចអត់ច្បាស់ទេបាទ។

**ស៖** បាទ សូមអរគុណ។ សូមអនុញ្ញាតលោក ដើម្បីទៅរូបថតទៅពីរ។ សូមអញ្ជើញលោកមើលរូបថត ដែលមានលេខ D313/1.2.234, P00416590។ បាទ លោកបានពិនិត្យឃើញថា ខ្ញុំសូមសួរលោកថាតើលោកឃើញទិដ្ឋភាពនេះគេកំពុងធ្វើអ្វីបាទ? ហើយថតៗនៅកន្លែងណា? បើលោកចាំថាថតនៅពេលណាបាទ?

**ឆ៖** ខ្ញុំអត់ចាំទេ។ ហើយទីកន្លែងក៏ខ្ញុំមិនដឹងនៅត្រង់ណាដែរ។

[១០:១៦:៥៩]

**ស៖** ចំពោះរូបថតទីបី គឺ E3/137, P00416592។ សូមអញ្ជើញលោកមើលរូបថតនេះថាតើរូបថតនេះគេថតនៅកន្លែងណា? ហើយថតហ្នឹងគឺកំពុងតែមានសកម្មភាពធ្វើអ្វី? ហើយថតនៅពេលណាបាទ? ហើយអ្នកណាខ្លះដែលលោកស្គាល់? ហើយជាអ្នកណា? លោកអាចបញ្ជាក់បានទេបាទ?

**ឆ៖** ទីកន្លែងខ្ញុំមិនដឹងទេ ហើយមិនដឹងធ្វើស្អី រូបថតនេះខ្ញុំច្បាស់តែម្នាក់ទេ គឺឪពុកមារបស់ខ្ញុំ ប៉ុល ពត។

**ស៖** គាត់ឈរ ឬក៏អង្គុយ? ហើយនៅចំណុចណាបាទទីតាំងគាត់?

**ឆ៖** គាត់ឈរនៅកណ្តាល។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំសូមបន្តសំណួរទៅសំណួរផ្សេង។ បាទសូមអរគុណ។ ខ្ញុំសូមសួរលោកថា ចាប់តាំងពីដំណាច់ឆ្នាំ១៩៦០ មករហូតដល់ខែមេសា ឆ្នាំ១៩៧៥ លោករស់នៅជាមួយនឹង ប៉ុល ពត និងមេដឹកនាំដទៃទៀតនៃបក្សកុម្មុយនីស្តកម្ពុជា ដូចជា អៀង សារី ដែរឬទេបាទ?

**ឆ៖** ខ្ញុំរស់នៅជាប់តែមួយលោក ប៉ុល ពត តែប៉ុណ្ណោះ។

[១០:១៨:៤៤]

**ស៖** បាទ ក្នុងឱកាសនៃការរស់នៅជាមួយគាត់ លោក ជាឱកាសមួយដែលអាចធ្វើឱ្យលោកយល់ច្បាស់នូវទស្សនៈរបស់មេដឹកនាំ ទស្សនៈនៃមាគ៌ានយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងគ្រប់

វិស័យពិតប្រាកដដែរឬទេ?

**ឆ៖** ខ្ញុំអត់បានយល់ច្បាស់ទេ។ ប៉ុន្តែខ្ញុំសម្មាទិដ្ឋិ មកដល់ពេលបច្ចុប្បន្នឃើញថាទស្សនៈ ប៉ុល ពត ជាទស្សនៈ ព្រហ្មមិ ពុទ្ធិ អមិរៈកសៈ។

**សៈ** សូមអរគុណ។ នៅ-- តើនៅក្នុង-- នៅមុនឆ្នាំ១៩៧៥ៗ នៅប្រទេសកម្ពុជា អ្នកដឹកនាំសម័យនោះ។ តើចាត់ទុកអ្នកណាជាខ្មាំង? មុនឆ្នាំ១៩៧៥បាទ?

[១០:២០:១០]

**លោក សាឡុត បាន៖**

មុនៗឆ្នាំប៉ុន្មាន?

**លោក លឹម ប៊ុនហេង៖**

៧៥។

**លោក សាឡុត បាន៖**

**ឆ៖** មុនឆ្នាំ៧៥ៗ គឺគាំទ្រនយោបាយអព្យាក្រឹត្យរបស់សម្តេចតា។ ឲ្យតែសម្តេចតា ប្រឆាំងនឹងនរណា គឺគាំទ្រ។

**សួរដោយលោក ច័ន្ទ តារាវស្មី៖**

**សៈ** បាទ នៅក្នុងទស្សនៈនៃមាគ៌ានយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា តើការចាត់ទុកបុគ្គលណាជាខ្មាំង ជាសត្រូវ តើស្ថិតនៅក្នុងការធ្វើចំណាត់ថ្នាក់នៃវណ្ណៈកសិករ និងកម្មករ ឬក៏ពួកគហបតី ឬក៏នាយទុក ឬក៏ពួកម្ចាស់ដី ឬក៏ពួកសក្តិភូមិដែរទេ?

**ឆ៖** នយោបាយជារួម គឺរណសិរ្សស្នេហាជាតិតែប៉ុណ្ណោះ។

[១០:២១:២៣]

**សៈ** តើអ្នកណាខ្លះដែលបក្សកុម្មុយនីស្តកម្ពុជាចាត់ទុកជាមនុស្សស្អាតស្អំ មានចរិតលក្ខណៈសម្គាល់បែបណាខ្លះ?

**ឆ៖** មនុស្សស្អាតស្អំ គឺមានសីលធម៌ ១២ប្រការ។

**សៈ** លោកអាចបញ្ជាក់បានទេ ១២ប្រការហ្នឹង ចង់និយាយថាម៉េច? មានអត្ថន័យយ៉ាងដូចម្តេច? បើសិនជាលោកអាចបញ្ជាក់បាន សូមមេត្តាបញ្ជាក់។

**ឆ៖** ខ្ញុំចាំមិនអស់ទេ ប៉ុន្តែខ្ញុំចាំមួយច្បាស់ ម្ទេសមួយផ្លែមិនត្រូវលួចទេ ត្រូវសុំប្រជាជន។

**ស៖** បាទ លោកអាចបញ្ជាក់បានទេថា តើដើម្បីចូលក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា បុគ្គលដែលគេត្រូវជ្រើសរើសចូលក្នុងជួរបក្សកុម្មុយនីស្តកម្ពុជាត្រូវធ្វើការលត់ដំ ត្រូវធ្វើការហាត់ពត់អត្តចរិត ឬក៏សកម្មភាពអ្វីខ្លះ មុននឹងបញ្ចូលទៅក្នុងបក្សកុម្មុយនីស្តកម្ពុជា?

**ឆ៖** ខ្ញុំមិនអាចអត្ថាធិប្បាយវែងឆ្ងាយទេ ដូចខ្ញុំបានជម្រាបអ៊ីចឹង គឺត្រូវតែឲ្យមានកម្រិតខ្ពស់បំផុត មិនបាន១០០ភាគរយទេ ក្នុងសីលធម៌១២ប្រការ។ ត្រឹមតែហាសិប-ហុកសិបភាគរយ គឺចាត់តាំងថាល្អហើយ។

[១០:២៣:០១]

**ស៖** សូមអរគុណ។ តើមានហេតុផលអ្វីបានជាមានការចងសម្ព័ន្ធភាព ការយល់ព្រមចងសម្ព័ន្ធភាពរវាងបក្សកុម្មុយនីស្តកម្ពុជាជាមួយនឹងសម្តេចនរោត្តម សីហនុ ក្នុងរណសិរ្សរួបរួមជាតិខ្មែរ?

**ឆ៖** ខ្ញុំយល់មិនលម្អិតទេ ដូចខ្ញុំបានជម្រាប គឺសំណូមពររក្សាទឹកដីឲ្យបានគង់វង្សយូរអង្វែង ហើយរក្សានយោបាយអព្យាក្រឹត្យភាពរបស់សម្តេចតា។

**ស៖** បាទ សូមអរគុណ។ តើវណ្ណៈដែលជាខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជាស្ថិតនៅទីណា?

**ឆ៖** វណ្ណៈខ្មាំងរបស់កម្ពុជា តាមខ្ញុំយល់គឺនៅក្នុងវណ្ណៈនោះបំផ្លាញជាតិឯង បំផ្លាញកេរអាកររបស់ជាតិឯង។

**ស៖** សូមអរគុណបាទ។ តើពួកគេហ្នឹងស្ថិតច្រើនវណ្ណៈដែលជាខ្មាំងហ្នឹង ភាគច្រើនត្រូវចាត់ថ្នាក់ថាស្ថិតនៅក្នុងតំបន់ទីក្រុងជាង ឬក៏ស្ថិតនៅក្នុងតំបន់ជនបទជាងបាទ?

[១០:២៤:៥០]

**ឆ៖** ខ្ញុំមិនលម្អិតបានទេ ពីព្រោះជានយោបាយរបស់ខាងលើ។

**ស៖** បាទសូមអរគុណ។ តើមនុស្សនៅក្នុងទីក្រុងភ្នំពេញ ត្រូវបានគេចាត់ទុកថាជាខ្មាំងដែរឬទេ? ឬក៏យ៉ាងហោចណាស់ក៏ត្រូវបានគេចាត់ទុកថា ជាមនុស្សដែលគេមិនត្រូវទុកចិត្តដែរឬទេ?

**ឆ៖** ខ្ញុំមិនឮពាក្យពេចន៍អស់ទាំងនេះចេញពីមាត់អ្នកដឹកនាំខ្ញុំទេ។

**ស៖** បាទ សូមអរគុណ។ តើការគោរពយ៉ាងខ្ជាប់ខ្ជួននូវសាសនាព្រះពុទ្ធ សាសនាអ៊ីស្លាម ឬក៏ជំនឿទៅលើអ្នកតារបស់ខ្លួន មានការប៉ះពាល់ទៅដល់គោលការណ៍របស់បក្សកុម្មុយនីស្តកម្ពុជាដែរឬទេបាទ?

[១០:២៥:៥១]

**ធ៖** ខ្ញុំបានឮតែសាសនាព្រះពុទ្ធជាសាសនារបស់រដ្ឋ។ ឯជំនឿអីផ្សេងៗ អប់រំអ្វីដែលមិនល្អត្រូវជម្រុះ អ្វីដែលល្អយើងយកមក ដើម្បីផលប្រយោជន៍ជាតិទាំងមូល។

**ស៖** សូមអរគុណបាទ។ តើអ្វីទៅជាការដាក់ទោសចំពោះអ្នកដែលបដិសេធមិនព្រមបោះបង់សាសនារបស់ខ្លួនចោល?

**ធ៖** ខ្ញុំមិនដែលឃើញអ្វីដែលលោកបាននិយាយ សួរមកខ្ញុំទេ។

**ស៖** បាទសូមអរគុណ។ តើបុព្វជិតព្រះពុទ្ធសាសនា និងជាពិសេសមេសាសនាដទៃទៀត ត្រូវគេចាត់ទុកជាខ្មាំងដែរឬទេ?

**ធ៖** មិនចាត់ទុកជាខ្មាំងទេ។

**ស៖** សូមអរគុណ។ នៅក្នុងតំបន់រំដោះ មុនឆ្នាំ១៩៧៥ តើបុព្វជិតបានជ្រើសរើសសឹកដោយខ្លួនឯង ជ្រើសរើសការដាក់សម្ពាធទៅលើពួកដែលគេបោះបង់ជំនឿសាសនាដើម្បីផលប្រយោជន៍អ្វីមួយ។ តើនេះគឺជាគោលការណ៍របស់បក្ស ឬក៏មិនមែនបាទ? បង្ខំឲ្យបុព្វជិតសាសនាដទៃហ្នឹង លះបង់ជំនឿរបស់ខ្លួន ឬក៏មិនមែនបាទ?

[១០:២៧:៥១]

**ធ៖** ខ្ញុំសូមធ្វើអត្ថាធិប្បាយ។ សូមអនុញ្ញាតធ្វើអត្ថាធិប្បាយ។ សូមលោកប្រធាន។ បញ្ហានេះគ្មានបង្ខំទេ សភាពការណ៍មានដូចតទៅ៖ ជំនាន់នោះគេហៅថា កប៉ាល់ហោះអាទ្រុងជ្រូក កប៉ាល់ហោះរបស់អេមេរិកាំងច្រើនប្រភេទណាស់។ អាទ្រុងជ្រូកហ្នឹងវាស៊ើបការណ៍អាក្រក់ណាស់ កន្លែងណាអ៊ូអែគឺបាញ់តែម្តង បាញ់រះ ឃើញតែស្បង់ក្រហមៗហ្នឹងបាញ់ស្បង់ហ្នឹង ប៉ោងខោហើយរត់។ ដូច្នេះ លោកសឹកដោយខ្លួនលោក មករួមតស៊ូ ពីព្រោះខ្មាសនារីៗ ដែលគេខំដឹកជញ្ជូន។ សូមមានមតិប៉ុណ្ណឹងបាទ។

**ស៖** បាទ សូមអរគុណ។ ក្នុងឋានៈជាក្រុមសាសនាជាតិពន្ធុ និងវប្បធម៌ តើជនជាតិចាម គឺជាខ្មាំងដែរឬទេ? នៅមុនឆ្នាំ៧៥ហ្នឹង តើបក្សមានចាត់ទុកដូច្នេះដែរឬទេបាទ?

**ធ៖** មិនមានឮអ្នកដឹកនាំនិយាយឲ្យប្រឆាំងនឹងបងប្អូនដែលកាន់សាសនាឥស្លាមទេ។

**ស៖** សូមអរគុណ។ តើពួកទាហាន លន់ នល់ ដែលជាសម្ព័ន្ធមិត្តរបស់ពួកអាមេរិកាំង ត្រូវបានគេចាត់ទុកថាជាខ្មាំងដែរឬទេ?

[១០:២៩:៥១]

**ធ៖** តាមខ្ញុំឮផ្ទាល់ត្រចៀក ចាត់ទុកថា ជារណសិរ្ស អត់ចាត់ទុកជាខ្មាំងទេ។

**ស៖** ចុះមន្ត្រីរដ្ឋការរបស់របប លន់ នល់ តើមានចាត់ទុកគាត់ជាខ្មាំងដែរឬទេ?

**ឆ៖** ខ្ញុំមិនច្បាស់ទេ ក៏ប៉ុន្តែខ្ញុំបានដឹងខ្លះៗថា ត្រូវមើលសម្រិតសម្រាំង។

**ស៖** បាទសូមអរគុណ។ ខ្ញុំសូម--

**ប្រធានអង្គជំនុំ៖**

បាទៗឥឡូវដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទីចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការជួយសម្របសម្រួលដល់កន្លែងសម្រាកសម្រាប់សាក្សី ហើយនិងមេធាវីប្រឹក្សារបស់គាត់ ដើម្បីឱ្យគាត់មានកន្លែងសម្រាកសមរម្យ នៅកន្លែងសម្រាកសម្រាប់សាក្សី ហើយនិងឱ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មវិញនៅម៉ោងដប់មួយខ្វះដប់នាទី។

សូមអញ្ជើញលោកមេធាវី!

[១០:៣១:២៥]

**លោក អាង ឧត្តម៖**

សូមអរគុណលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម។ លោក អៀង សារី ថ្ងៃនេះស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមផ្ទាល់ក្នុងបន្ទប់សវនាការនេះ តែសូមចូលរួមដោយប្រយោលពីបន្ទប់រង់ចាំខាងក្រោមសម្រាប់ថ្ងៃនេះពេញតែម្តង។ សំណើនេះធ្វើឡើងដោយសារ មានបញ្ហាសុខភាព គឺបញ្ហាចង្កេះ ឈឺខ្នង និងជើង។ អាស្រ័យហេតុនេះ សូមលោកប្រធានមេត្តាពិចារណា និងសម្រេច។

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទស្តាប់សំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំតាមរយៈមេធាវីការពារក្តីរបស់គាត់ សូមលះបង់សិទ្ធិមិនចូលរួមតាមដានកិច្ចដំណើរការសវនាការ ដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ ដោយសុំទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍ពីបន្ទប់ឃុំខ្លួនមួយក្រោមបន្ទប់សវនាការនេះ ពេញរយៈពេលថ្ងៃ សម្រាប់សប្តាហ៍ថ្ងៃនេះ-- សវនាការសម្រាប់ថ្ងៃនេះ ដោយមូលហេតុបញ្ហាសុខភាព អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានធ្វើឡើងតាមរយៈមេធាវីរបស់គាត់ ស្នើសុំលះបង់សិទ្ធិមិនចូលរួមក្នុងកិច្ចដំណើរការសវនាការ ដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ទៅបន្តតាមដានកិច្ចដំណើរការសវនាការពី

ចម្ងាយពីបន្ទប់មួយស្ថិតនៅក្រោមបន្ទប់សវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលពេញមួយថ្ងៃនេះ។

[១០:៣២:៤៦]

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តី អៀង សារី ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការផ្ទាល់នៅក្នុងបន្ទប់សវនាការនេះដែលមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ និងបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយសម្រាប់ថ្ងៃនេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការនេះ ដែលមានរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍ សម្រាប់ជនជាប់ចោទតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣៣ នាទី ដល់ម៉ោង ១០:៥៣ នាទី)*

[១០:៥៣:៣៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាជាតិ ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញ!

**លោក ច័ន្ទ តារាស្មី៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមអនុញ្ញាតបន្តសួរសំណួរជូនចំពោះសាក្សីជាបន្តទៀត។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** ខ្ញុំសូមសួរលោកសាក្សីទាក់ទិននឹងរបបសម្ងហភាព។ នៅក្នុងតំបន់រំដោះ នៅចន្លោះខែ

មីនា ឆ្នាំ១៩៧០ និងខែមេសា ឆ្នាំ១៩៧៥ តើមានការដាក់ឲ្យប្រើប្រាស់រូបិយវត្ថុ ហើយនិងមានការបង្កើតទីផ្សារហើយឬនៅ នៅពេលនោះបាទ?

[១០:៥៤:៣៦]

**លោក សាឡូត បាន៖**

**ឆ៖** មុន៧៥ អំមិញ? បាទ មុន៧៥? មុន៧៥ តាមខ្ញុំដឹងខ្លះៗ គឺត្រៀមរៀបចំរូបិយប័ណ្ណសម្រាប់ប្រើប្រាស់ហើយ។

**ស៖** បាទ--

**ឆ៖** ទេ មុនៗ មុនអី?

**ស៖** មុន៧៥ បាទ?

**ឆ៖** មុន៧៥ អត់ទេ។

**ស៖** តើទីផ្សារ ការបង្កើតទីផ្សារដើម្បីលក់ទំនិញអីនៅពេលនោះ ទំនិញសេវាកម្មអី តើមានដែរឬទេ បាទ?

**ឆ៖** ពេលនោះ ខ្ញុំឃើញដូចជា តាមខ្ញុំចាំនៅមានជាធម្មតា។

[១០:៥៥:៣៨]

**ស៖** ចុះការទូ-- បើមានទីផ្សារ ចុះការទូទាត់ថ្លៃទំនិញ ឬក៏សេវាកម្ម តើការទូទាត់ហ្នឹងដែលប្រើអ្វីទៅជាការទូទាត់រវាងការដោះដូរទំនិញ ឬសេវាកម្មនោះបាទ?

**ឆ៖** ខ្ញុំសូមអភ័យទោស ខ្ញុំសូមជម្រាបម្តងទៀត។ មុន៧៥ វាមានរយៈ រយៈកាលណា! បាទ មើល់មុន៧៥ហ្នឹង គឺដើមឡើយ ពី៧០មក ណោះ ៧០,៧១,៧២ ដូចជាការចាយលុយជំនាន់ លន់ នល់ហ្នឹងធម្មតាទេ។ ក្រោយមក ក៏ឈប់ចាយ ហើយបែប ប្រហែល៧៤, ៧៣, ៧៤, ៧៥ហ្នឹងអត់ទេ ឈប់ចាយហើយបាទ។

**ស៖** បាទ សូមអរគុណ។ សូមលោកជួយបញ្ជាក់អំពីស្ថានភាពនៃការប្រើប្រើប្រាស់រូបិយវត្ថុ ឬក៏ទីផ្សារនៅក្នុងតំបន់រំដោះ។ តើនៅក្នុងតំបន់រំដោះហ្នឹងមានទីផ្សារ មានការបង្កើតទីផ្សារ ហើយមានការដោះដូរទំនិញសេវាកម្ម ឬក៏លុបបំបាត់ចោលទីផ្សារ ឬក៏រូបិយវត្ថុនៅក្នុងតំបន់រំដោះបាទ?

**ឆ៖** ដូចខ្ញុំបានជម្រាបអំមិញអ៊ីចឹងបាទ តាមរយៈៗពី៧០មក ៧១, ៧២ គឺចាយ ហើយដល់ដោះដូរអីធម្មតាណាបាទ។ ដល់៧៣, ៧៤, ៧៥ បន្តយរហូតដល់ផ្តាច់អត់ចាយ។

[១០:៥៧:៤៧]

**ស៖** សូមអរគុណ។ តើមានហេតុផលអ្វីបានជាមានការផ្តាច់ លែងឲ្យមានការប្រើប្រាស់រូបិយវត្ថុ?

**ឆ៖** តាមខ្ញុំយល់ អត់បានជាច្បាស់លាស់ទេ ក្រោយមកទៀត ខ្ញុំសម្មាទិដ្ឋិខ្លួនឯង ឃើញថាត្រូវតែអនុវត្តនយោបាយអាចម៍ទៅរ៉ៃយក្ស បាទចប់។

**ស៖** លោកសាក្សី តើនយោបាយដែលលោកមានប្រសាសន៍អម្បាញ់មិញហ្នឹង មានន័យដូចម្តេចបាទ?

**ឆ៖** សូមបញ្ជាក់ថា នេះមិនមែនជានយោបាយរបស់បក្សទេ។ តាមសម្មាទិដ្ឋិរបស់ខ្លួន នយោបាយទៅរ៉ៃយក្ស គឺវាមានរឿងវា។ បើខ្ញុំឲ្យនិយាយរឿងវា ខ្ញុំសូមអភ័យទោសលោកប្រធាន វាវែងឆ្ងាយណាស់។ ប៉ុន្តែខ្ញុំសរុបមក គឺថាត្រូវយកញើសឈាមខ្លួនឯង ទៅរ៉ៃចក្រពត្តិបានឈ្នះ។

**ស៖** សូមអរគុណ។ លោកសាក្សី តើនៅក្នុងតំបន់រំដោះ តើបក្សកុម្មុយនីស្តនៅតែយល់ព្រមទទួលយកកម្មសិទ្ធិឯកជនដែរឬទេ? ឬក៏លុបបំបាត់ចោលបាទ?

[១០:៥៩:៤៣]

**ឆ៖** ខ្ញុំមិនយល់ជាជម្រៅទេ ក៏ប៉ុន្តែដូចខ្ញុំបានជម្រាបអ៊ីចឹង តាមការសម្មាទិដ្ឋិរបស់ខ្ញុំ គឺទាល់តែអនុវត្តនយោបាយពុទ្ធិ ព្រហ្មមិ អមិរៈកសៈ។

**ស៖** លោកសាក្សី តើទស្សនៈដែលលោកយល់ឃើញអម្បាញ់មិញនេះ តើទស្សនៈហ្នឹងមានន័យយ៉ាងដូចម្តេច តើលោកអាចបញ្ជាក់យ៉ាងសង្ខេបបានទេបាទ?

**ឆ៖** គឺថាមនុស្សយើងត្រូវតែរកការពិត ពិតហើយត្រូវប្រាកដ ប្រាកដហើយឲ្យត្រូវប្រាជាទៀត។

**ស៖** សូមអរគុណ។ តើបក្សកុម្មុយនីស្តកម្ពុជាបានលុបបំបាត់របបកម្មសិទ្ធិឯកជនចាប់តាំងពីពេលណាបាទ?

**ឆ៖** តាមខ្ញុំចាំ ការលុបរបបកម្មសិទ្ធិឯកជនមិនមែនជាចំណង់ទេ។ គឺទិសដៅចង់បានការរួបរួមគ្នាឲ្យបានមោះមុត ដើម្បីយកឈ្នះលើសត្រូវ។

**ស៖** ដូច្នេះមានន័យថា លុបបំបាត់របបកម្មសិទ្ធឯកជនចោល ហើយឈានទៅបង្កើតរបបអ្វីវិញបាទ ដែលល្អប្រសើរជាងកម្មសិទ្ធិឯកជនហ្នឹង?

[១១:០១:៤៦]

**ធៈ** ដូចខ្ញុំបានជម្រាបអ៊ីចឹង គឺមិនមែនស្រេចតែចិត្តទេ គឺសភាពការណ៍ជំរុញឲ្យធ្វើដូច្នេះ។

**សៈ** លោកសាក្សី តើសភាពការណ៍ជំរុញឲ្យធ្វើដូច្នេះ លោកចង់មានន័យយ៉ាងដូចម្ដេចបាទ សូមជួយបញ្ជាក់យ៉ាងសង្ខេបបន្តិចបាទ? សូមអរគុណ សូមមេត្តាបញ្ជាក់?

**ធៈ** សភាពការណ៍យ៉ាងដូច្នេះ ដូចខ្ញុំបានជម្រាបហើយ គឺ*(ឮមិនច្បាស់)* យកញើសឈាមយើងតាមព្រះពុទ្ធលោកមានឱវាទថា ខ្លួនឧបត្ថម្ភខ្លួន យើងត្រូវតែធ្វើយ៉ាងនេះ។

**សៈ** អរគុណបាទ។ នៅពេលដែលបក្សកុម្មុយនីស្តកម្ពុជាសម្រេចលុបចោលរបបកម្មសិទ្ធិឯកជន តើបក្សកុម្មុយនីស្តកម្ពុជាសម្រេចបង្កើតរបបអ្វីថ្មីឡើង ជំនួសរបបកម្មសិទ្ធិឯកជនហ្នឹងវិញ?

**ធៈ** ខ្ញុំមិនបានច្បាស់លាស់ទេ ខ្ញុំមិនមែនជាអ្នកស្ថាបនិក ក៏ប៉ុន្តែតាមខ្ញុំដឹងបង្កើតជារបបកម្ពុជាប្រជាធិបតេយ្យ។

**សៈ** បាទ លោកសាក្សីទាក់ទិននឹងកម្មសិទ្ធិ មានកម្មសិទ្ធិឯកជន និងកម្មសិទ្ធិសមូហភាព។ តើរបបកម្មសិទ្ធិឯកជន និងរបបកម្មសិទ្ធិសមូហភាពហ្នឹង បក្សកុម្មុយនីស្តកម្ពុជាបានជ្រើសរើសរបបមួយណាបាទ នៅក្នុងសម័យកាលនៃការកាន់អំណាចរបស់របបកម្ពុជាប្រជាធិបតេយ្យនោះបាទ?

[១១:០៣:២៥]

**ធៈ** ខ្ញុំមិនអ្នកជំនាញខាងហ្នឹងទេ ស្រេចតែខាងលើ។

**សៈ** សូមអរគុណ។ តើលោកមានបានធ្លាប់ឮពាក្យថា "របបសមូហភាព" នៅក្នុងពេលនោះដែរឬទេ?

**ធៈ** ខ្ញុំឮរបបសមូហភាព បើយើងមិនមានសមូហភាពទេ មិនមានសាមគ្គីចងក្រងជាសមូហភាពទេ ធ្វើអីក៏មិនកើតដែរ។

**សៈ** សូមអរគុណ។ តើរបបសមូហភាពមានន័យយ៉ាងដូចម្ដេច?

**ធៈ** របបសមូហភាព គឺប្រជាធិបតេយ្យប្រមូលផ្តុំ។

**សៈ** បាទ សូមអរគុណ។ តើការប្រមូលផ្តុំហ្នឹងក្នុងន័យថា ប្រមូលកម្លាំង ការប្រមូលផ្តុំទ្រព្យសម្បត្តិ ការប្រមូលផ្តុំគំនិត ឬការប្រមូលផ្តុំអ្វីក្រៅពីនេះបាទ?

**ធៈ** ប្រមូលផ្តុំអ្វីក៏ដោយឲ្យតែឈ្នះខ្មាំង គឺប្រមូលទាំងអស់។

[១១:០៤:៣៦]

**ស៖** សូមអរគុណ។ តើការបង្កើតរបបសម្ហភាពកើតឡើងនៅក្នុងឆ្នាំណាពិតប្រាកដ?

**ឆ៖** ខ្ញុំអត់ចាំទេ ខ្ញុំគិតតែពីធ្វើ។

**ស៖** បាទ សូមអរគុណ។ លោកមានបានឮពាក្យ ដែលឮពាក្យដែលគេនិយាយថា ពាក្យថាជា "សហករណ៍" ដែលឮទេបាទ?

**ឆ៖** ពាក្យនេះ ខ្ញុំឮតាំងពីសម័យបុរាណមក ក៏ខ្ញុំបានឮដែរ។ ខ្ញុំធ្លាប់ដឹងមក គឺថាខ្ញុំឮតាំងពីសម័យណាណើមកបាទ។

**ស៖** សូមអរគុណ។ តើពាក្យ "សហករណ៍" នេះ បានបង្កើតនៅក្នុងតំបន់រំដោះ នៅចន្លោះខែមីនា ឆ្នាំ៧០ និងខែមេសា ឆ្នាំ៧៥ ដែរឬទេបាទ?

[១១:០៥:៣១]

**ឆ៖** ភារកិច្ចនេះ ខ្ញុំអត់ចូលប្រឡូកទេ ខ្ញុំអត់បានដឹងទេ។

**ស៖** សូមអរគុណ។ តើលោកមានដែលឮគេនិយាយប្រាប់ថា សហករណ៍ហ្នឹង បង្កើតឡើងដោយនរណា? ហើយសហករណ៍ហ្នឹង បង្កើតឡើងមានប៉ុន្មានប្រភេទ? ប៉ុន្មានទម្រង់បាទ?

**ឆ៖** ខ្ញុំអត់ដឹងទេ។

**ស៖** សូមអរគុណ។ តើអ្នកដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដែលលោកបានស្គាល់ ដែលលោកបានរាប់អាន ក្នុងរយៈពេលនៃឆ្នាំ៧០ ដល់៧៥ ហ្នឹង តើអ្វីទៅជាមូលហេតុដែលបញ្ជាក់អំពីភាពត្រឹមត្រូវនៃការបង្កើតសហករណ៍ ទោះបីជាទ្រង់ទ្រាយតូច មធ្យម និងធំក៏ដោយ?

[១១:០៦:៣១]

**ឆ៖** បាទ អត់យល់ សូមម្តងទៀតបាទ។

**ស៖** ខ្ញុំចង់មានន័យថា ក្នុងនាមលោកស្គាល់ស្និទ្ធស្នាល ឬក៏រាប់អានមានលក្ខណៈស្និទ្ធស្នាលជាមួយនឹងមេដឹកនាំ ដែលលោកបានស្គាល់។ តើលោកបានដឹងទេអំពីគោលបំណងដ៏ចម្បង ដែលទាក់ទិននឹងការបង្កើតសហករណ៍ បើទោះបីជាសហករណ៍នោះ ទ្រង់ទ្រាយតូច ធំ មធ្យម យ៉ាងណាក៏ដោយនៅក្នុងតំបន់រំដោះ ដែលលោកបានស្ថិតនៅនោះបាទ?

**ឆ៖** ខ្ញុំដូចមិន-- ខ្ញុំឆ្លើយអត់បានបាទ ព្រោះខ្ញុំមិនជំនាញខាងហ្នឹងបាទ។

**ស៖** សាក្សី ខ្ញុំសូមឆ្លើយទៅ-- ឆ្លងទៅសំណួរផ្សេងទៀត បាទ។ ខ្ញុំសូមបន្តសួរលោកថា នៅចាប់តាំងពីមុនឆ្នាំ១៩៧៥ មុនឆ្នាំ១៩៧៥ តើលោកបានដឹងឮអំពីការទាក់ទិននឹងការជ្រើសរើសគូស្រករ

ការរៀបអាពាហ៍ពិពាហ៍នៅក្នុងតំបន់រំដោះ ដែលកំណត់ដោយគោលការណ៍របស់បក្សកុម្មុយនីស្តកម្ពុជា ដែរឬទេបាទ?

**ឆ៖** រឿងនេះ ខ្ញុំអត់បានដឹងទេ។ ដឹងតែខ្លួនឯង។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

[១១:០៨:០៨]

**លោក ម៉ៃខល កាណាវាស៖**

ដូចជាយឺតបន្តិចលោកប្រធាន ប៉ុន្តែសំណួរនេះ សហព្រះរាជអាជ្ញានាំមុខសាក្សី។ នេះគឺជាអង្គហេតុ មិនមែនជាភស្តុតាងទេចេញពីសាក្សីរូបនេះ។ ប្រសិនបើលោកចង់ឲ្យសាក្សីក៏បានដឹង គឺថាសូមតុលាការណែនាំឲ្យសហព្រះរាជអាជ្ញាកុំឲ្យនាំមុខសាក្សី ដោយណែនាំអង្គហេតុឲ្យសាក្សីគាត់សន្និដ្ឋាន។ ដូច្នេះ សូមឲ្យតុលាការជម្រាបសហព្រះរាជអាជ្ញា កុំឲ្យប្រើសំណួរនាំមុខនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណការកត់សម្គាល់របស់លោកមេធាវី ម៉ៃខល កាណាវាស លើការតាំងសំណួរបែបនាំមុខនេះ។ អង្គជំនុំជម្រះសូមរំឭកសាជាថ្មីម្ដងទៀត លើបច្ចេកទេសនៅក្នុងការតាំងសំណួរដេញដោល សូមចៀសវាងនូវការតាំងសំណួរឯណាដែលច្បាប់ហាមឃាត់។ ហើយភាគីដូចគ្នា ប្រសិនបើលើកតជំទាស់ សូមលើកឲ្យបានទាន់ពេល ដើម្បីយើងសម្រេចលើបញ្ហានេះ មុនពេលភាគ-- មុនពេលសាក្សីផ្ដល់សក្ខីកម្ម។

**លោក ច័ន្ទ តារាស្មី៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** លោកសាក្សី ខ្ញុំសូមសួរទៅលោកបន្តទៀត។ ទាក់ទិននឹងបញ្ហានៃការរៀបអាពាហ៍ពិពាហ៍ និងការជ្រើសគូស្រករ ខ្ញុំចង់ឲ្យ-- បើសិនជាលោកអាចបញ្ជាក់បាន ថាតើបក្សកុម្មុយនីស្តកម្ពុជាបានសម្រេចដាក់គោលការណ៍ ឬក៏គោលនយោបាយយ៉ាងដូចម្ដេច ទាក់ទិននឹងបញ្ហានេះបាទ?

**លោក សាឡុត បាន៖**

**ឆ៖** ដូចខ្ញុំបានជម្រាបអីចឹង ខ្ញុំអត់ដឹងទេ។ ដឹងតែខ្លួនឯង។

[១១:០៩:៥៤]

**ស៖** សូមអរគុណ។ ខ្ញុំសូមបន្តទៅសំណួរមួយទៀត។ លោកបាននិយាយថា នៅមុនការដណ្តើមកាន់កាប់ទីក្រុងភ្នំពេញ។ ការិយាល័យគណៈកម្មាធិការមជ្ឈិមបានផ្លាស់ប្តូរទីតាំងពីស្ទឹងជីនិតមកកាន់ស្រុកឧដុង្គ ឃុំពាម។ តើនេះជាការពិតដែរឬទេបាទ?

**ឆ៖** ដូចជាមិនមែនជាមន្ទីរមជ្ឈិមទេ គឺគេហៅថា មិនមែនជាមន្ទីរទេ គឺកន្លែងចល័ត។

**ស៖** តើកន្លែងចល័តហ្នឹងបង្កើតឡើងក្នុងគោលបំណងអ្វីដែរបាទ?

**ឆ៖** ស្រាល ស្វាត់ ចល័ត រស់រវើក។

**ស៖** សូមអរគុណ។ នៅខេត្តកំពង់ស្ពឺ ស្រុកឧដុង្គ តើលោកបានស្ថិតនៅក្បែរលោក ប៉ុល ពត ជានិច្ចដែរឬទេ?

[១១:១១:១៨]

**ឆ៖** ខ្ញុំស្ថិតនៅជាមួយលោកជានិច្ច។

**ស៖** តើលោកស្ថិតនៅទីនោះ នៅក្បែរគាត់ដើម្បីអ្វី? ក្នុងគោលបំណងអ្វី?

**ឆ៖** សម្រាប់គាត់ប្រើប្រាស់។

**ស៖** បាទ តើក្នុងពេលនោះលោកមានមុខងារជាអ្វី? តួនាទីជាអ្វីបាទ?

**ឆ៖** ខ្ញុំមានមុខងារជាយុទ្ធជនធម្មតា។

**ស៖** បាទ តើ ប៉ុល ពត បានជ្រើសលោកក្នុងនាមជាសន្តិសុខ ឬក៏មិនមែន? ឬក៏ជាអ្នកណាផ្សេងដែលធ្វើជាសន្តិសុខការពារគាត់នៅពេលនោះ?

**ឆ៖** ទាំងអស់គ្នាត្រូវចេះសន្តិសុខទាំងអស់គ្នា។

**ស៖** អរគុណបាទ។ តើ ប៉ុល ពត, នួន ជា, អៀង សារី ឬក៏ ខៀវ សំផន បានចូលរួមប្រជុំនៅក្នុងស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ នាពេលដែលលោកនៅក្បែរគាត់ហ្នឹង តើលោកបានឃើញការជួបប្រជុំជាញឹកញាប់រវាងលោក ប៉ុល ពត, នួន ជា, អៀង សារី ឬ ខៀវ សំផន ដែរឬទេ?

[១១:១២:៤៥]

**ឆ៖** ការជួបជុំគ្នាបីបួនប្រាំនាក់មិនមានទេ អាចមានការជួបជុំគ្នាម្នាក់ពីរនាក់តែប៉ុណ្ណោះ។

**ស៖** តើលោកអាចបញ្ជាក់បានទេ ថាការជួបប្រជុំគ្នាពីរបីនាក់នោះ? តើក្នុងបំណងអ្វី? ភាគច្រើនការប្រជុំហ្នឹង គឺនិយាយរឿងប្រធានបទអ្វីដែរបាទ?

**ឆ៖** បញ្ហានេះ ខ្ញុំរឹតតែមិនដឹង។

**ស៖** សូមអរគុណ។ តើលោកបានដឹងថា ការពិភាក្សាអំពីការប្រយុទ្ធ ការរៀបចំផែនការវាយលុកចូលទីក្រុងភ្នំពេញ តើលោកបានដឹងទេថា អ្នកណាជាអ្នកដាក់ចេញផែនការនេះ? ហើយការប្រជុំនេះធ្វើឡើងនៅទីកន្លែងណាដែរ?

**ឆ៖** បញ្ហានេះ ក៏រឹតតែមិនដឹង។

[១១:១៣:៤៥]

**ស៖** សូមអរគុណ។ តើប្រធានភូមិភាគ ឬក៏ប្រធានយោធាថ្នាក់តំបន់ ថ្នាក់ស្រុកបានចូលរួមក្នុងការប្រជុំជាមួយនឹងលោក ប៉ុល ពត, នួន ជា, អៀង សារី, ខៀវ សំផន នៅក្នុងទឹកដីស្រុកខដុង្គនោះដែរឬទេបាទ?

**លោក ម៉ៃខល កាណាវាស៖**

សូមជាថ្មីម្តងទៀតលោកប្រធាន មុននឹងសាក្សីឆ្លើយ។

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលឆ្លើយ! បាទៗ សូមអញ្ជើញ! សាក្សីកុំអាលឆ្លើយ ហើយសូមៗអញ្ជើញលោកមេធាវី កាណាវាស!

[១១:១៤:២៤]

**លោក ម៉ៃខល កាណាវាស៖**

ជាថ្មីម្តងទៀតលោកប្រធាន ខ្ញុំមិនជំទាស់ពីមុនទេ គាត់ប្រើពាក្យថា "ប្រជុំជាញឹកញាប់" នេះឥឡូវនេះគាត់ទទូចថា ថាមានការប្រជុំជាមួយ អៀង សារី នៅទីនោះ។ ទីមួយ គាត់ត្រូវសួរសាក្សី ថាតើបើសិនជាមានការប្រជុំ តើអ្នកណាជាអ្នកចូលរួម? មុននឹងស្នើពាក្យនៅក្នុងចម្លើយ ឬក៏ស្នើពាក្យឈ្មោះ ថាលោក អៀង សារី ចូលរួមក្នុងអង្គប្រជុំ។ នេះជាសំណួរនាំមុខ។ ចំណុចនេះ គឺសំខាន់ណាស់ដែលថាសហព្រះរាជអាជ្ញាបានស្នើចម្លើយហ្នឹងពីរដង ហើយគាត់ទៅមួយជំហានម្តង។ ថាតើមានព្រឹត្តិការណ៍ប្រជុំឬទេ? អ្នកណាជាអ្នកចូលរួម? ប៉ុន្តែបើគាត់ស្នើឈ្មោះនៅក្នុងសំណួរហ្នឹង គឺមិនសមរម្យទេលោកប្រធាន។ ខ្ញុំសូមជំទាស់ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទៗ ជំទាស់របស់មេធាវីការពារក្តីលោក អៀង សារី មានប្រសិទ្ធភាព។ សាក្សីមិនបាច់ឆ្លើយ

តបទៅនឹងសំណួរចុងក្រោយដែលសួរឡើងដោយតំណាងសហព្រះរាជអាជ្ញាជាតិអម្បាញ់មិញនេះទេ ពីព្រោះជាសំណួរនាំមុខ។

**លោក ច័ន្ទ តារាស្មី៖**

សូមអរគុណ។ សូមអរគុណលោកប្រធាន។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** សូមសួរសំណួរលោកសាក្សី ជាសំណួរផ្សេងមួយទៀត។ បន្ទាប់ពីការជួបគ្នានៅឃុំពាម នៅឃុំពាមបាទ។ តើមានការផ្លាស់ប្តូរទីតាំងកន្លែងផ្សេងទៀតនៅក្នុងខេត្តកំពុងឆ្នាំង នៅក្នុងខេត្តកំពង់ឆ្នាំងហ្នឹង នៅមុន ឬក៏នៅពេលជម្លៀសមនុស្សចេញពីទីក្រុងភ្នំពេញ? តើថ្នាក់ដឹកនាំណាខ្លះបានជួបប្រជុំគ្នាបន្ទាប់ពីមានការជួបជុំគ្នានៅឃុំពាម? គឺព្រឹត្តិការណ៍នេះកើតឡើងមុនពេល ឬក៏នៅពេលមានជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ? បាទ សូមលោកសាក្សីមេត្តាឆ្លើយបាទ។

[១១:១៦:១១]

**លោក សាឡុត បាន៖**

**ឆ៖** បញ្ហានេះខ្ញុំអត់ចាំទេ។

**ស៖** បាទ សូមអរគុណ។ នៅខណៈពេលមានការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ តើលោកស្ថិតនៅកន្លែងណា? ស្ថិតនៅជាមួយអ្នកណាបាទ?

**ឆ៖** ពេលនោះអត់មានអ្នកដឹកនាំនៅទេ ខ្ញុំនៅម្នាក់ឯង។

**ស៖** តើពេលនោះលោកកំពុងស្ថិតក្នុងធ្វើកិច្ចការអ្វីដែរបាទ ពេលលោកនៅម្នាក់ឯងនោះបាទ?

**ឆ៖** ខ្ញុំយាមខ្ទមអ្នកដឹកនាំ។

**ស៖** សូមអរគុណ។ នៅខណៈពេលដែលមានការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ តើលោកស្ថិតនៅឃុំពាមដដែល ឬក៏បានដូរទីកន្លែងផ្សេងបាទ?

**ឆ៖** ខ្ញុំនៅយាមខ្ទមហ្នឹងដដែល។

**ស៖** បាទ នៅក្នុងទីកន្លែងនោះ តើលោកបានឃើញទិដ្ឋភាពនៃការបន្លាស់ទីរបស់ប្រជាជនដែលត្រូវបានគេជម្លៀសពីភ្នំពេញ ទៅរស់នៅឃុំពាមដែរឬទេ?

**ឆ៖** និយាយថាឃុំ ១ហ្នឹង គឺជា កន្លែងដែលនៅហ្នឹងគឺគ្មានជាឃុំទេ គឺជាព្រៃ។ ដូច្នេះអត់មានឃើញទេប្រជាជននោះ។

**ស៖** លោកអាចបញ្ជាក់បានទេ លោកដែលឮគេនិយាយទេ អំពីស្រុកឈ្មោះស្រុក១២? មានដែលឮគេនិយាយឈ្មោះស្រុក១២ទេបាទ? ស្រុក១២ហ្នឹងមានន័យដូចម្ដេចបាទ?

**ឆ៖** ខ្ញុំឮគេនិយាយ ក៏ប៉ុន្តែមិនដឹងស្រុកអី។

**ស៖** បាទ សូមអរគុណ។ តើលោកអាចបញ្ជាក់បានទេថា លោក អៀង សារី ស្ថិតនៅកន្លែងណា? ស្ថិតនៅទីតាំងណានៅចន្លោះឆ្នាំ១៩៧០ និងឆ្នាំ១៩៧៥?

**ឆ៖** ខ្ញុំអត់បានដឹងគាត់ទៅទីណាទេ។

[១១:១៩:០៨]

**ស៖** អរគុណ។ តើលោកមានបានដឹងទេថា លោក អៀង សារី មានបានចាកចេញទៅប្រទេសក្រៅដែរឬទេ? ទៅបរទេសដែរឬទេបាទ? នៅក្នុងចន្លោះឆ្នាំ៧០ ដល់៧៥?

**ឆ៖** ខ្ញុំមិនដឹងថា ទៅទីណាទេ ទាល់តែគាត់ត្រឡប់មកវិញ បានដឹងថាគាត់មកពីក្រៅ។

**ស៖** តើលោកចាំទេ ថាគាត់អញ្ជើញមកពីក្រៅប្រទេសហ្នឹងនៅពេលណា?

**ឆ៖** ខ្ញុំមិនដឹងច្បាស់ទេ តាមបើតាមខ្ញុំចាំបែបមិនច្បាស់លាស់ថ្ងៃខែទេ បែបរំដោះភ្នំពេញហើយ។

**ស៖** លោកមានបានឃើញ ឬក៏បានដឹងឮថាគាត់មកពីក្រៅប្រទេសហ្នឹង មកពីប្រទេសណា?

**ឆ៖** ខ្ញុំអត់បានដឹងទេ។

**ស៖** បាទ លោកបានដឹងទេថា គាត់មកពីក្រៅពីប្រទេសមកជាមួយនឹងអ្នកណាខ្លះដែលជាអ្នកអមអំណើរជាមួយនឹងគាត់?

**ឆ៖** ខ្ញុំចាំមិនច្បាស់ទេ គឺឈ្មោះ ក៏ប៉ុន្តែខ្ញុំដឹងថាមានបញ្ញាជនខ្លះៗមកជាមួយគាត់។

**ស៖** លោកអាចរៀបរាប់បានខ្លះៗ ឈ្មោះខ្លះទេបាទ បើសិនជាលោកចាំ?

**ឆ៖** ខ្ញុំចាំជាងគេ ដូចជាលោក ឡុង នរិន្ទ ហើយនិងលោក អ៊ិន សុភាព។

**ស៖** បាទ សូមអរគុណ។ តើលោកមានបានដឹងទេថា គាត់ទៅប្រទេសក្រៅហ្នឹងក្នុងបំណងអ្វី?

**ឆ៖** បញ្ហានេះខ្ញុំងងឹតសូន្យហើយ។

[១១:២១:២៣]

**ស៖** បាទ តើលោកមានបានឮគេនិយាយថា គាត់ធ្លាប់ទៅទីក្រុងប៉េងកាំង ប្រទេសចិនដែរឬទេបាទ?

**ឆ៖** ខ្ញុំបានធ្លាប់បានទៅជាមួយគាត់ម្ដង។

**ស៖** លោកទៅនៅពេលណា? ហើយក្នុងបំណងអ្វីបាទ ការងារនោះ?

**ឆ៖** ទៅអង្គការសហប្រជាជាតិ និងរួមជាមួយនឹងប្រទេសមិនចូលបក្សសម្ព័ន្ធ។

**ស៖** បាទ លោកទៅជាមួយនឹងអ្នកណាខ្លះបាទ? គណៈប្រតិភូអមដំណើរកាលនុ៎ង មានបុគ្គលណាខ្លះ? មានអ្នកណាខ្លះបាទ?

**ឆ៖** ខ្ញុំចាំឈ្មោះមិនអស់ទេ។ ដូចជាមានលោក គាត ឈន់ ដូចជាលោក ជួន ប្រាសិទ្ធ, លោក ចាន់ យូរ៉ាន់ និយាយរួមទៅ អ្នកនៅក្រសួងការបរទេស គេទៅតាមលោក អៀង សារី តាមការគាត់អញ្ជើញមុខងារ-- តាមមុខងាររបស់គេ។

[១១:២៣:០១]

**ស៖** បាទ សូមអរគុណ។ តើនៅឆ្នាំណាដែរ លោកចាំទេបាទ។ នៅក្នុងខែណា ឆ្នាំណាដែរបាទ?

**ឆ៖** ខ្ញុំចាំមិនច្បាស់ទេ គ្រាន់ដឹងថានៅរំដោះហើយ បាទ។

**ស៖** បាទ តើលោកមានបានឮគេនិយាយអំពីវត្តមានរបស់លោក អៀង សារី នៅទីក្រុងប៉េកាំងដែរឬទេ?

**ឆ៖** ខ្ញុំអត់បានដឹងទេ បើខ្ញុំដឹងពេលដែលគាត់ទៅហ្នឹងគឺថាការងារអីក៏ខ្ញុំដឹងដែរ ពីព្រោះខ្ញុំដូចជាគ្រាន់តែទៅបានជាគ្នាទេ ព្រោះខ្ញុំអត់ចេះភាសាអីទាំងអស់។ សូមទោស។

**ស៖** សាក្សី ខ្ញុំសូមអនុញ្ញាតសួរបន្តទៀតបាទ។ ទាក់ទិននឹងបញ្ហា ទាក់ទិននឹងបញ្ញាជន ដែលចូលរួមក្នុងចលនាបដិវត្តន៍ តើលោកបានដឹងអំពីគោលមាគ៌ារបស់បក្សទាក់ទិននឹងបញ្ញាជនដែលចូលរួមក្នុងចលនាបដិវត្តន៍ដែរឬទេ នៅក្នុងចន្លោះឆ្នាំ៧០ ដល់ឆ្នាំ១៩៧៥?

[១១:២៤:២៣]

**ឆ៖** ខ្ញុំមិនដឹងលម្អិតទេ ដឹងតែសាមគ្គីគ្នា កសាង និងការពារប្រទេស។

**ស៖** បាទ តើមានការធ្វើការស្រាវ-- ជ្រើសរើស *សេលិច* ជម្រើសបញ្ញាជនយ៉ាងដូចម្ដេចមុននឹងបញ្ចូលពួកគេចូលទៅក្នុងជួរបក្សកុម្មុយនីស្ដកម្ពុជា?

**ឆ៖** ខ្ញុំអត់ចូលជ្រៅក្នុងបញ្ហានេះទេ។

**ស៖** សូមអរគុណ។ ខ្ញុំសូមអនុញ្ញាតឆ្លងទៅសំណួរ ដែលទាក់ទិននឹងការប្រជុំរបស់គណៈមជ្ឈិម-- របស់គណៈកម្មាធិការមជ្ឈិមនៅឆ្នាំ១៩៧៤។ លោកសាក្សី សូមអនុញ្ញាតសួរបាទ។ ខ្ញុំសូមសួរ

ថា តើលោកមានបានដឹងទេ អំពីកិច្ចប្រជុំដែលធ្វើឡើងដោយគណៈកម្មាធិការមជ្ឈិម នៅឆ្នាំ១៩៧៤បាទ?

**ឆ៖** ខ្ញុំរឹតតែមិនដឹង។

[១១:២៥:៥០]

**ស៖** លោកមិនដែលឮគេនិយាយអំពីបញ្ហានេះទេឬ?

**ឆ៖** ខ្ញុំមិនដែលឮទេ។

**ស៖** សូមអរគុណ។ តើលោកបានដឹងថា អៀង សារី ពេលដែលគាត់បានវិលត្រឡប់ពីប្រទេសវិញ តើគាត់បានធ្វើដំណើរទៅទីតាំងកន្លែងណាខ្លះនៅក្នុងតំបន់រំដោះ? តើលោកបានដឹងចំណុចនេះទេនៅពេលដែលគាត់វិលត្រឡប់មកពីបរទេសវិញបាទ?

**ឆ៖** ខ្ញុំអត់បានដឹងទេ ពីព្រោះខ្ញុំមិនជាអ្នកការពារគាត់។

**ស៖** ចុះកិច្ចប្រជុំវិញ តើគាត់មានបានរៀបចំកិច្ចប្រជុំនៅថ្នាក់ណា នៅកន្លែងណា ឬក៏បានចូលរួមប្រជុំនៅតំបន់ណាកន្លែងណាដែរឬទេបាទ លោក អៀង សារី បាទ?

**ឆ៖** រយៈកាលណា ៧៤?

**ស៖** ៧៤ បាទ។

**ឆ៖** អត់ដឹងទេ បាទ។

**ស៖** សូមអរគុណបាទ។ ដោយលោកបានបញ្ជាក់ថា លោកបានស្ថិតនៅជាមួយនឹង ប៉ុល ពត លោក ប៉ុល ពត គឺលោកនៅកៀកគាត់នៅជាប់ជាមួយគាត់។ តើលោកបានដឹងឮអំពីគំនិតសំខាន់ៗ គោលគំនិតចម្បងៗរបស់លោក ប៉ុល ពត ដែលតែងតែនិយាយ ដែលតែងតែពិភាក្សាក្នុងអង្គប្រជុំ ឬតែងតែណែនាំដល់កូនចៅរបស់គាត់ ថ្នាក់ក្រោមៗដែរឬទេ?

[១១:២៧:៣០]

**ឆ៖** កូនចៅថ្នាក់ក្រោមៗមិនលម្អិតទេ ក៏ប៉ុន្តែបើការណែនាំរបស់ខ្ញុំគឺលម្អិត គឺខ្ញុំអាចនិយាយបាន។

**ស៖** សូមអាចបញ្ជាក់បានទេបាទ? សូមអញ្ជើញបាទ។

**ឆ៖** ចំពោះខ្ញុំ?

**ស៖** បាទលោកបាទ សូមអញ្ជើញបាទ!

**ឆ៖** ការណែនាំជាធម្មតាទេ ប៉ុន្តែគាត់មិនមានតួនាទីអីមកណែនាំខ្ញុំការរៀនសូត្រអី ដែលជា

យុទ្ធជនតូចតាចទេ គ្រាន់តែការណែនាំឲ្យថា ការពារឲ្យបាន ការពារអាយុជីវិតគាត់ឲ្យបានតែប៉ុណ្ណោះ។

**ស៖** បាទសូមអរគុណ។ ទាក់ទិននឹងការរៀបចំផែនការវាយលុកចូលទីក្រុងភ្នំពេញ តើថ្នាក់ណាជាអ្នកសម្រេច? ហើយលោកបានដឹងទេថាការសម្រេចយ៉ាងដូចម្ដេចបាទ?

**ឆ៖** ខ្ញុំងងឹតសូន្យហើយរឿងនេះ។

[១១:២៨:៤២]

**ស៖** ចុះក្រោយៗមកលោកមានបានដឹងខ្លះទេ ពីព័ត៌មានបញ្ហានេះ?

**ឆ៖** ក្រោយមកក៏ខ្ញុំមិនដឹង ប៉ុន្តែខ្ញុំឮសួរយោធា គេនិយាយហែៗថា ខ្មាំងគិញបង្កប់របស់ចក្រពត្តិអាមេរិកច្រើនពាន់នាក់ ធ្វើវិទ្ធេទកម្ម និងចារកម្មនៅទីក្រុងភ្នំពេញ។

**ស៖** លោកអាចបញ្ជាក់បានទេថា បក្សកុម្មុយនីស្តកម្ពុជាកំណត់មនុស្សប្រភេទណា ដែលចាត់ទុកថា ជាចារកម្មជាខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលទាក់ទិនជាមួយនឹងអាមេរិកាំង ឬក៏ កា.ហ្សេ.បេ សូវៀត ជាដើម។ល។

**ឆ៖** ខ្ញុំមិនអាចកំណត់បានទេ។

[១១:៣០:០០]

**ស៖** សូមអរគុណ។ តើលោកអាចបញ្ជាក់បានទេទាក់ទងនឹងបញ្ហាប្រជាជន ដែលត្រូវធ្វើការជម្លៀសនោះ? តើលោកឃើញទិដ្ឋភាពប្រជាជន ដែលរងការជម្លៀសពីទីក្រុងភ្នំពេញហ្នឹងស្ថិតក្នុងស្ថានភាពបែបណា?

**ឆ៖** ខ្ញុំនៅឃាមខ្ទម ដល់តែចូលភ្នំពេញឃើញប្រជាជនស្ងាត់បាត់។ ដូច្នេះមិនឃើញទិដ្ឋភាពឲ្យបានជាក់ស្ដែងទេ។

**ស៖** បាទសូមអរគុណ។ នៅចន្លោះឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ ៧០ដល់៧៥ តើលោកបានអមដំណើរលោក ប៉ុល ពត ដែរឬទេបាទ? តើលោកបានការពារស្ថិតនៅក្បែរលោក ប៉ុល ពត ឬក៏អត់ទេបាទ ក្នុងចន្លោះឆ្នាំ៧០ ដល់ ៧៥?

[១១:៣១:១៤]

**ឆ៖** ចន្លោះ៧០ ដល់៧៥ ភាគច្រើនខ្ញុំនៅជាប់។

**ស៖** ក្រៅពីលោក ប៉ុល ពត តើលោកបានស្ថិតនៅក្បែរជាមួយនឹងអ្នកដឹកនាំណាផ្សេងទៀតដែរឬទេ?

**ឆ៖** មានតែលោក អៀង សារី។

**លោក ច័ន្ទ តារាស្មី៖**

បាទលោកប្រធាន ខ្ញុំមានសំណួរបីសំណួរចុងក្រោយ មុននឹងបញ្ចប់ការរបស់ខ្ញុំចំពោះសាក្សីរូបនេះ។ ខ្ញុំសូមអនុញ្ញាត។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** លោកសាក្សី ខ្ញុំសូមសួរបីសំណួរចុងក្រោយ ទាក់ទិននឹងអ្វីដែលខ្ញុំចង់សួរនៅពេលនេះ។ តើ អៀង ធីរិទ្ធ, ខៀវ សំផន, នួន ជា លោកធ្លាប់ធ្វើជាអ្នកការពារ ឬនៅក្បែរគាត់ដែរឬទេបាទ?

**ឆ៖** ចំពោះលោកទាំងបីនាក់នេះ ខ្ញុំមិនដែលការពារផ្ទាល់ទេ។ ការពារជារួមពេលដែលមានការប្រជុំបានការពារ។

**ស៖** សូមអរគុណ។ សំណួរមួយទៀត សូមសួរថា តើលោកធ្លាប់បានឃើញ ឬក៏បានដឹងឮថាថ្នាក់ដឹកនាំដូចជា អៀង សារី, លោក អៀង សារី, លោក នួន ជា, លោកស្រី អៀង ធីរិទ្ធ, លោក ខៀវ សំផន និង ប៉ុល ពត តើអ្នកទាំងអស់ហ្នឹងឧស្សាហ៍ជួបប្រជុំគ្នាជាញឹកញាប់ដែរឬទេ? ឬមួយក៏ការពិភាក្សាគ្នាហ្នឹងច្រើនធ្វើនៅកន្លែងណា? ឬក៏ការជួបប្រជុំគ្នាហ្នឹងធ្វើយ៉ាងដូចម្តេច?

[១១:៣៣:១៤]

**ឆ៖** ការប្រជុំមិនជាញឹកញាប់ទេ ហើយការពិភាក្សាគ្នាក៏ខ្ញុំអត់ដឹងពិភាក្សារឿងអី។ ទីកន្លែងច្រើនពេក ខ្ញុំមិនអាចកំណត់ត្រង់ណាដែលថាប្រជុំញឹកញាប់បានបាទ។

**ស៖** បាទសូមអរគុណ។ ខ្ញុំចង់សួរសំណួរចុងក្រោយមួយទៀត សូមអនុញ្ញាតសួរសំណួរចុងក្រោយមួយទៀតជាសំណួរបញ្ចប់របស់ខ្ញុំ។ តើក្នុងឋានៈលោកជាអ្នកការពារ អ្នកនៅក្បែរលោក ប៉ុល ពត ហើយនិងជួបញឹកញាប់ជាមួយលោក អៀង សារី តើលោកឃើញថាលោក ប៉ុល ពត លោក អៀង សារី ហ្នឹងឧស្សាហ៍ចុះទៅតំបន់រំដោះដែរឬទេ? ហើយបើចុះទៅចុះនៅតំបន់ណា? កន្លែងណា? ហើយនៅពេលនោះ តើគាត់និយាយអ្វីខ្លះ?

[១១:៣៤:១៥]

**ឆ៖** លោក អៀង សារី ខ្ញុំមិនដែលការពារគាត់ទៅជនបទទេ ឯលោក ប៉ុល ពត ខ្ញុំ--។ ឯការទៅជនបទតិចតួចណាស់ ក្រៅពីបែកពីគាត់មក មកជួបបង អៀង សារី។ ដូច្នេះ ជួបជាមួយ ប៉ុល ពត គឺមានតែជាមួយ ប៉ុល ពត ទៅជនបទមានតែការរៀនសូត្រ បើកវគ្គរៀនសូត្រតែប៉ុណ្ណោះ។

**លោក ច័ន្ទ តាវារស្មី៖**

បាទ សូមអរគុណលោកសាក្សីដែលបានឆ្លើយសំណួររបស់ខ្ញុំ ចំពោះសំណួរទាំងអស់ដែលខ្ញុំបានសួរនាព្រឹកនេះ។ សូមអរគុណលោកសាក្សី។ ហើយខ្ញុំសូមបញ្ចប់ការសួរចំពោះលោកនៅពេលនេះ។ ហើយសូមអរគុណលោកប្រធានដែលបានអនុញ្ញាតឲ្យខ្ញុំសួរ ហើយសូមបញ្ចប់ការសួររបស់ខ្ញុំពេលនេះ ហើយខ្ញុំទុកឱកាសជូនសហការីរបស់ខ្ញុំ លោក វាំងសង់ សួរសំណួរបន្តទៀតដែលទាក់ទងទៅនឹងអ្វីនៅសល់បន្ទាប់ពីខ្ញុំសួរនេះ។ បាទ សូមអរគុណលោកប្រធាន។

[១១:៣៥:១៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណតំណាងសហព្រះរាជអាជ្ញាជាតិ។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម។ ជម្រាបសួរលោកសាក្សី ជាដំបូងសូមអរគុណលោកដែលមានវត្តមាននៅទីនេះ ដើម្បីមកនិយាយអំពីសម័យនោះ យើងដឹងថាវាពិបាកណាស់ ពីព្រោះវាកើតឡើងតាំងពីយូរហើយ។ ខ្ញុំសូមអរគុណណាស់ដែលលោកបានឆ្លើយចម្លើយយ៉ាងច្បាស់លាស់ ហើយសូមមេត្តាឲ្យលោកឆ្លើយឲ្យបានច្បាស់ចំពោះសំណួរដែលខ្ញុំនឹងសួរទៅលោក។

[១១:៣៦:០៣]

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ជាដំបូង ខ្ញុំនឹងសួរសំណួរដែលពាក់ព័ន្ធទៅនឹងសម័យខែមេសា ៧៥ ទៅដល់ខែមករា ឆ្នាំ ៧៩ ប៉ុន្តែមុននឹងសួរ ខ្ញុំចង់ត្រឡប់មកសួរសំណួរដើម្បីទទួលការបញ្ជាក់ពីលោក។ យើងដូចជាមិនសូវច្បាស់សោះ ឧទាហរណ៍ដូចសំណួរដំបូងថា តើនៅអាយុប៉ុន្មានដែលលោកបានចាកចេញពីឪពុកម្ដាយរបស់លោកនោះ? ខ្ញុំចង់មានន័យថា ដែលលោកចាកចេញពីខេត្តដែលលោករស់នៅនុ៎ង ហើយតើលោកចេញទៅ លោកទៅណាទៀត?

**លោក សាឡុត បាន៖**

**ឆ៖** ខ្ញុំចាកចេញពីឪពុកម្ដាយប្រហែលជាអាយុប្រាំពីរឆ្នាំ។

[១១:៣៧:០៩]

**ស៖** ហើយបន្ទាប់មកទៀត តើលោកទៅរស់នៅជាមួយអ្នកណាដែរ?

**ឆ៖** ខ្ញុំរស់នៅជាមួយអ៊ំ អ៊ំប្រុសដែលជាបងរបស់លោក ប៉ុល ពត។ បន្ទាប់មកខ្ញុំទៅនៅជាមួយលោកមាម្នាក់ទៀត បានបន្ទាប់មកខ្ញុំទៅនៅជាមួយលោក ប៉ុល ពត។

**ស៖** តើនៅអាយុប៉ុន្មានដែលលោកទៅរស់នៅជាមួយ ប៉ុល ពត?

**ឆ៖** ប្រហែលជាអាយុ១៥, ១៦។

**ស៖** តើលោករស់នៅជាមួយ ប៉ុល ពត ដែលគាត់ជាអ្នកទទួលខុសត្រូវលោកហ្នឹងតាំងពីអាយុ១៥ឆ្នាំ រហូតដល់ពេលក្រោយមកទៀត តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

[១១:៣៨:៣៨]

**ស៖** តើលោកអមដំណើរ ប៉ុល ពត ទៅគ្រប់ទីកន្លែងទៅអស់ចាប់ពីអាយុ១៥ឆ្នាំ ឬក៏មានរយៈពេលដែលថាលោករស់នៅដោយគ្មាន ប៉ុល ពត នោះ?

**ឆ៖** ពិបាកឆ្លើយបន្តិច ប៉ុន្តែខ្ញុំខំឆ្លើយ។ មានរយៈកាល១៥ឆ្នាំហ្នឹង ប៉ុល ពត នៅភ្នំពេញ ខ្ញុំហ្នឹងជាសិស្សសាលា។ ខ្ញុំមិនមែនអមអីទេ គ្រាន់តែមកនៅរៀនស្នាក់នៅ។ ដល់តែជួបគ្នានៅក្នុងព្រៃ ហ្នឹងបានខ្ញុំទៅជាប់ជាមួយលោក ប៉ុល ពត អ៊ីចេះបាទ សូម។

**ស៖** តើលោកអាចបញ្ជាក់បានទេ ថាតើក្នុងប្រហែលជាឆ្នាំណាដែរ ដែលលោកទៅជួប ប៉ុល ពត នៅក្នុងព្រៃ ហើយដែលលោកទៅរស់នៅជាមួយគាត់នោះ?

**ឆ៖** តាមខ្ញុំចាំ នៅឆ្នាំ១៩៦៨, ៦៨, ៦៩ បាទ។

[១១:៤០:០៧]

**ស៖** តើមុនឆ្នាំ ៦៨-៦៩ នេះ តើលោក ប៉ុល ពត នៅភ្នំពេញ ឬ នៅពេលដែល ប៉ុល ពត នៅភ្នំពេញ តើលោកធ្លាប់បានរស់នៅជាមួយ អៀង សារី ទេ?

**ឆ៖** ពេលដែល ប៉ុល ពត បាត់ខ្លួនមិនដឹងទៅឯណា ខ្ញុំក៏ចេញពីផ្ទះដែលខ្ញុំធ្លាប់រស់នៅជាមួយ ប៉ុល ពត នោះខ្ញុំជាពលករសេរី ចេះតែដើររស់នៅតាមផ្ទះមិត្តភក្តិ។

**ស៖** ខ្ញុំចង់ត្រឡប់មកនិយាយពីចំណុចនេះវិញ គឺពាក់ព័ន្ធទៅនឹងអ្វីដែលលោកបានឆ្លើយ។ ជាដំបូងខ្ញុំចង់សួរលោកថា តើមានធ្លាប់ត្រូវ-- លោកត្រូវបានស្តាប់ចម្លើយជាលើកច្រើនសាដោយអ្នកស៊ើបអង្កេត។ តើលោកមានបានឆ្លើយទៅកាន់អ្នកស៊ើបអង្កេតទាំងអស់នោះទេ?

**ឆ៖** ខ្ញុំបានឆ្លើយបាទ។

[១១:៤១:៣៩]

**ស៖** តើលោកអាចបញ្ជាក់បានទេថា តើអ្នកស៊ើបអង្កេតរបស់តុលាការនេះសួរលោកប៉ុន្មានដង? ហើយលោកបានចុះហត្ថលេខា ឬក៏បានផ្តិតមេដៃរបស់លោកហ្នឹងប៉ុន្មានដងដែរទៅលើសេចក្តីប្រកាសទាំងអស់នេះ?

**ឆ៖** សូមទោស! ខ្ញុំមានជំងឺ កិច្ចការដែលទៅសួរខ្ញុំមិនចាំទេ ហើយខ្ញុំមិនសូវរវល់ផងនឹងរឿងនេះ ហើយខ្ញុំបង្ខំចិត្តមកទេនៅទីនេះ។ ដូច្នេះ ខ្ញុំមិនចាំទេ។ មិនដឹងប៉ុន្មានដង ៗទេបាទ។ ឯណាជីវភាពផង ឯណាឈឺថ្កាត់ផង ជុំវិញផ្ទាល់ខ្លួន និងក្រុមគ្រួសារ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

ដើម្បីជាព័ត៌មាននោះខ្ញុំមានជាកំណត់ហេតុប្រាំ។ ខ្ញុំសូមអនុញ្ញាតអង្គជំនុំជម្រះដើម្បីបង្ហាញកំណត់ទីមួយដែលមានលេខកូដ E3/91 ហើយនិង ដូចគ្នាដែរគឺ D91/14។ ដូច្នេះ ខ្ញុំសូមជូនឯកសារនេះទៅដល់ក្រឡាបញ្ជី។

[១១:៤៣:៣៧]

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការយក ទទួលឯកសារពីតំណាងព្រះរាជអាជ្ញាអន្តរជាតិទៅជូនសាក្សីពិនិត្យ!

លោកស្នើសុំឯកសារដាក់នៅលើអេក្រង់កុំព្យូទ័រដែរទេ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ?

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

យើងសុំបង្ហាញត្រឹមតែទំព័រទីមួយទេ ដើម្បីឱ្យគាត់ឃើញឈ្មោះរបស់គាត់ ហើយបន្ទាប់មកទៀត គឺជាភាសាខ្មែរ 00204096, ជាភាសាបារាំង 00503934 គឺទំព័រទី៥, ជាភាសាអង់គ្លេសទំព័រទី៤ នៃឯកសារដដែលនេះ មានលេខ ERN 00223592។

[១១:៤៤:៤៤]

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

**ស៖** លោកសាក្សីខ្ញុំសូមអានឃ្លាមួយចំនួនដែលលោកបាននិយាយនៅពេលនោះ គឺការស្តាប់ចម្លើយនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៧ នៅក្នុងឃុំម៉ាឡៃ។ ហើយលោកបាននិយាយតទៅនេះ "ខ្ញុំរស់នៅជាមួយលោក អៀង សារី ហើយខ្ញុំស្គាល់គាត់តាំងពីអាយុ១៣ឆ្នាំ។ ដោយសារតែខ្ញុំរស់នៅជាមួយនឹងពូ

របស់ខ្ញុំគឺ ប៉ុល ពត ហើយលោក អៀង សារី ក៏រស់នៅក្នុងផ្ទះជាមួយយើងដែរ និងដោយសារតែគាត់រស់នៅជាមួយយើង ដូចជាក្រុមគ្រួសារតែមួយអ៊ីចឹង។ ខ្ញុំតែងតែគោរពនិងស្រឡាញ់គាត់ ដូចជាខ្ញុំគោរពនិងស្រឡាញ់ពូរបស់ខ្ញុំ ប៉ុល ពត ដូច្នេះដែរ"។ តើលោកមានចាំនូវចម្លើយនេះដែរឬទេ? ហើយលោកនៅតែរក្សាចម្លើយនេះដដែល ឬក៏យ៉ាងណា?

**លោក សាឡុត បាន៖**

**ឆ៖** ខ្ញុំរក្សាចម្លើយនេះបាទ។ ប៉ុន្តែសូមទោស ១៣ឆ្នាំ អានេះខ្ញុំពិនិត្យមើលទៅប្រហែលក្នុង១៣ ១៤ឆ្នាំហ្នឹងឯងបាទ។

**ស៖** សូមអរគុណចំពោះការបញ្ជាក់នេះ។ នៅពេលដែលលោកនិយាយថា លោករស់នៅជាមួយ ប៉ុល ពត នៅក្នុងព្រៃតស៊ូ នៅក្រោយពេលរយៈពេលនោះមក តើ អៀង សារី ក៏នៅទីនោះដែរ ឬក៏យ៉ាងណា?

[១១:៤៥:២៤]

**ឆ៖** ដូចខ្ញុំបានជម្រាបអ៊ីចឹង ខ្ញុំឃើញ នៅទីនោះ។

**ស៖** តើលោកអាចប្រាប់បានទេថា តំបន់ ឬក៏ទីតាំងដែល ប៉ុល ពត នៅ ហើយបន្ទាប់មកលោកបានជួបជាមួយ អៀង សារី នៅពេលដែលលោកចាប់ផ្តើមជួបអ្នក-- មេដឹកនាំទាំងពីរដំបូង គឺនៅចន្លោះឆ្នាំ៦៨ និង៦៩។

**ឆ៖** អត់យល់។ បាទ អត់យល់។ បាទ អត់យល់សំណួរបាទ។

**ប្រធានអង្គជំនុំ៖**

បាទ លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ តាំងសំណួរចុងក្រោយអម្បាញ់មិញនេះសាជាថ្មីម្តងទៀត ព្រោះសាក្សីមិនយល់សំណួរលោកទេ អ៊ីចឹងគាត់មិនដឹងឆ្លើយថាយ៉ាងម៉េចទេ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្មាឯល៖**

**ស៖** លោកទើបតែបានជម្រាបជូនអម្បាញ់មិញនេះថា លោកបានទៅជួប ប៉ុល ពត នៅក្នុងព្រៃនៅក្នុងចន្លោះឆ្នាំ៦៨, ៦៩ បើតាមការចាំរបស់លោកនោះ ហើយលោកបានបញ្ជាក់ថាលោកបានឃើញ អៀង សារី នៅទីនោះដែរ។ តើលោកមេដឹកនាំទាំងពីរអ្នកនោះនៅកន្លែងណា នៅពេលនៅក្នុងព្រៃនុំង?

**លោក សាឡុត បាន៖**

**ឆ៖** ដូចបានជម្រាបពីមុនអ៊ីចឹង ឈ្មោះជនជាតិ ហើយគ្មានភូមិ ដូច្នេះខ្ញុំមិនដឹងនៅទីណាទេ។

**ស៖** តើកន្លែងរស់នៅនុំង គឺនៅខេត្តរតនគិរី នៅភូមិភាគឦសាន តើមែន អ៊ីចឹងមែនទេ?

**ឆ៖** បាទ នៅខេត្តរតនគិរី ភូមិភាគឦសាន។

**ស៖** អម្បាញ់មិញនេះ លោកបាននិយាយអំពីការរើទីតាំងរបស់មេដឹកនាំទៅកាន់តំបន់មួយនៅជិតស្ទឹងជីនិត ហើយលោកបានបញ្ជាក់ទៀតថា នៅទីនោះ លោកអត់បានឃើញ ខៀវ សំផន ទេនៅឆ្នាំ៧០ ប៉ុន្តែមុនឆ្នាំ៧០ នោះ គឺឆ្នាំ សូមទោស គឺក្រោយឆ្នាំ៧០ គឺ៧១, ៧២, ៧៣ ឬក៏៧៤ នោះ តើលោកមានឃើញ ខៀវ សំផន ទេ?

[១១:៥០:០៤]

**ឆ៖** ពេលនោះ ខ្ញុំឃើញ។

**ស៖** តើគាត់រស់នៅកន្លែងនោះ ជាមួយមេដឹកនាំផ្សេងទៀត ឬក៏គ្រាន់តែគាត់មកម្តងម្កាលទេ?

**ឆ៖** គាត់មកម្តងម្កាល។ គាត់រស់នៅកន្លែងផ្សេង។

**ស៖** ឥឡូវនេះ ខ្ញុំចង់ត្រឡប់មកកាន់ចំណុចដែលលោកបាននិយាយ គឺនៅឃុំពាម។ នៅទីនោះ គឺថាលោកធ្លាប់បានស្នាក់នៅដែរ។ ហើយលោកបានបញ្ជាក់ថា វាមិនមែនជាមន្ទីររបស់គណៈមជ្ឈិមទេ វាជាមន្ទីរចល័ត។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាងលេ៖**

ខ្ញុំចង់បង្ហាញឯកសារមួយ លោកប្រធាន គឺកំណត់ហេតុស្តាប់ចម្លើយ ដែលមានលេខយោង E3/446 D369/36។ ខ្ញុំសូមបង្ហាញឯកសារនេះ នៅលើអេក្រង់ គឺដែលមានចម្លើយលេខពីរ។ ខ្ញុំមិនមានលេខ ERN ទេ។ ប៉ុន្តែនៅទំព័រពីរ ខ្ញុំគិតថា អាចគ្រប់គ្រាន់ហើយ ភាគីអាចស្គាល់ពីឯកសារនេះ ឯកសារដែលខ្ញុំចង់និយាយនេះហើយ។

[១១:៥១:៤៧]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញ!

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីតំណាងសហព្រះរាជអាជ្ញាអន្តរជាតិជូនទៅសាក្សី ហើយនិងអនុញ្ញាតឲ្យបុគ្គលិកជំនួយការបង្ហាញឯកសារនៅលើអេក្រង់កុំព្យូទ័រ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាងលេ៖**

**ស៖** ខ្ញុំសូមឲ្យលោកអានចម្លើយទីមួយផងដែរ ហើយនិងចម្លើយទីពីរ។ ប្រសិនបើអាច ខ្ញុំនឹង

អាន។ សំណួរទីមួយ បានសួរថា "មុនថ្ងៃទី១៧ មេសា ៧៥ តើលោករស់នៅឯណា? ចម្លើយ៖ មុនថ្ងៃ ១៧ មេសា ៧៥ ខ្ញុំនៅកំពង់ស្ពឺ ស្រុកឧដុង្គ ជាកន្លែងមន្ទីរមជ្ឈិម សម្រាប់បោះជំរំ ដើម្បីវាយចូលក្រុងភ្នំពេញ"។ សំណួរទីពីរ "តើមន្ទីរនោះ មានលេខកូដប៉ុន្មាន? ចម្លើយ៖ ខ្ញុំភ្លេចហើយ។ ពេលនោះ ខ្ញុំនៅភូមិក្រាំងបេង ភូមិក្រាំងខ្មៅ ខេត្តកំពង់ស្ពឺ"។ តើលោកថា គិតថា វាជាមន្ទីរកម្លាំងចល័ត-- កងកម្លាំងចល័ត ឬក៏ជាមន្ទីរមជ្ឈិម? ដូចដែលលោកបានបញ្ជាក់ជូនទៅខាងអ្នកស៊ើបអង្កេតនៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១០នោះ?

[១១:៥៣:៣៨]

**លោក សាឡុត បាន៖**

**ឆ៖** ខ្ញុំថា មន្ទីរ ប៉ុន្តែតាមការពិតទៅ វាជាកន្លែងចល័ត។ ថា មន្ទីរអីចឹងក៏បាន ប៉ុន្តែផ្ទះហ្នឹងតែមួយទេបាទ ហើយទទួលបានអ្នកមកប្រជុំហ្នឹង តែមួយ តែពីរនាក់ទេ វាជាចល័តបាទ។ សូមបញ្ជាក់ប៉ុណ្ណឹងបាទ។

**ស៖** តើអ្នកណាធ្វើការនៅក្នុងផ្ទះនុ៎ង? គឺថាផ្ទះដែលអាចផ្លាស់ប្តូរ ប៉ុន្តែក្នុងតំបន់ដដែលហ្នឹង តើមេដឹកនាំណាដែលធ្វើការនៅក្នុងផ្ទះនុ៎ង?

**ឆ៖** គឺប៉ុល ពត បាទ។

**ស៖** តើមានមេដឹកនាំដែលមកពីតំបន់ ឬក៏ភូមិភាគផ្សេងទៀត មកជួបលោក ប៉ុល ពត ដែរឬទេ?

**ឆ៖** តាមការគាត់អញ្ជើញ ម្នាក់ ឬពីរនាក់តែប៉ុណ្ណោះ។ យូរៗម្តង ខ្ញុំឃើញម្តង យូរៗម្តង។

[១១:៥៥:១១]

**ស៖** តើមាន-- លោកមានដឹងទេថា គេពិភាក្សាអីខ្លះរវាង ប៉ុល ពត ហើយនិងមេដឹកនាំភូមិភាគផ្សេងៗដែលមកជួបគាត់នោះ?

**ឆ៖** បញ្ហានេះ ខ្ញុំមិនដឹងទេ។

**ស៖** នៅក្នុងកំណត់ហេតុស្តាប់ចម្លើយដដែលនេះ ខ្ញុំសូមអានចម្លើយ គឺចម្លើយទីបួន គឺឯកសារកំណត់ហេតុដដែលលេខ D369/36 ឬក៏ឯកសារលេខ E3/446។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមមេត្តាអនុញ្ញាតលោកប្រធានបញ្ចាំងឯកសារនេះ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោកលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** សំណួរទីបួន "ពីរបីនាក់ដែលចូលរួមប្រជុំនោះតើមានអ្នកណាខ្លះ? លោកបានឆ្លើយថា៖ ជួនកាលគាត់ហៅខាងភូមិភាគបូព៌ា ភូមិភាគនិរតីមកប្រជុំ។ ហើយពេលគេទៅវិញ គឺទៅផ្សព្វផ្សាយបន្ត ក្រោយពេលបែកភ្នំពេញហើយ ទើបមានការប្រជុំ និងរៀនសូត្រជាទ្រង់ទ្រាយធំ"។ ហើយចំពោះសំណួរ ទីប្រាំ "តើលោកដឹងអំពីខ្លឹមសារនៅក្នុងការប្រជុំដែលមានការចូលរួមពីរបីនាក់ហ្នឹងដែរឬទេ? លោក បានឆ្លើយថា៖ ខ្ញុំមិនឹងខ្លឹមសារអ្វីទេ។ ប៉ុន្តែគ្រាន់តែដឹងថា ការប្រជុំហ្នឹងគឺនិយាយអំពីការវាយទីក្រុង វាយយ៉ាងម៉េច ហើយក៏មាននិយាយអំពីការគ្រប់គ្រងគ្រាប់រំសេវផងដែរ។

[១១:៥៧:២៤]

សំណួររបស់ខ្ញុំគឺថា តើលោកមានចាំថាលោកបាននិយាយបែបនេះទេ? ហើយលោកនៅតែរក្សា ចម្លើយនេះដដែលឬក៏យ៉ាងណា?

**លោក សាឡុត បាន៖**

**ឆ៖** អានេះគឺថា តាមខ្ញុំស្មានទេ។ ប្រហែលជាអ៊ីចឹងហើយដឹង បានជាសភាពការណ៍វ៉ៃសម្រុក ហើយ មានអារឿងហ្នឹងឯង។ ហើយបើវ៉ៃសម្រុកហើយ គឺគិតគូរពីរឿងគ្រប់គ្រងគ្រាប់រំសេវ បាទ។

**ស៖** តើមានការពិភាក្សាអំពីជោគវាសនារបស់ប្រជាជននៅទីក្រុងភ្នំពេញទេនៅពេលនុ៎ង?

**ឆ៖** អត់បានដឹងទេបាទ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំសូមចូលទៅចំណុចមួយទៀត គឺនៅខែមេសា ៧៥ និងដល់ខែមករា ៧៩ ប៉ុន្តែខ្ញុំគិតថា តើយើងគួរតែឈប់សម្រាកនៅពេលនេះ សម្រាប់ពិសាអាហារថ្ងៃត្រង់ឬក៏យ៉ាងណា លោកប្រធាន?

[១១:៥៨:៤៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន ដោយសារអាចនឹងឈានចូលទៅប្រធានបទមួយថ្មីទៀត ដែលមានសំណួរ ពាក់ព័ន្ធច្រើន ហើយពេលវេលាក៏សមល្មមសម្រាកដើម្បីពិសាថ្ងៃត្រង់ហើយដែរ។ អង្គជំនុំជម្រះសម្រាក

ដើម្បីពិសាថ្ងៃត្រង់ ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកសមរម្យសម្រាប់សាក្សី និងមេធាវីប្រឹក្សារបស់គាត់ ដើម្បីមានកន្លែងសម្រាក ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មវិញនៅរសៀលនេះឲ្យបាននៅម៉ោងមួយសាមសិបនាទី។

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា!

[១១:៥៩:៣៧]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន តាមធម្មតានោះ ខ្ញុំសូមស្នើគាត់សុំបន្តតាមដាននៅបន្ទប់ខាងក្រោម ហើយខ្ញុំមានសំណើសុំនេះនឹងជូនទៅមន្ត្រីតុលាការ ដើម្បីបានការអនុញ្ញាតពីតុលាការបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ អនុញ្ញាតឲ្យអង្គុយចុះ!

បានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ស្នើសុំទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ដោយលះបង់សិទ្ធិក្នុងការចូលរួមផ្ទាល់ក្នុងកិច្ចដំណើរការសវនាការ ដោយសន្យាថាខ្លួននឹងប្រគល់ឲ្យអង្គជំនុំជម្រះនូវលិខិតលះបង់សិទ្ធិមិនចូលរួមសវនាការដោយផ្ទាល់របស់ជនជាប់ចោទ។ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំតាមរយៈមេធាវីការពារក្តីរបស់គាត់សុំទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមបន្ទប់សវនាការនេះ តាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលមួយរសៀលនេះ ដោយគាត់លះបង់សិទ្ធិក្នុងការចូលរួមតាមដានកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

[១២:០០:៥៥]

អង្គជំនុំជម្រះតម្រូវឲ្យមេធាវីការពារក្តីជនជាប់ចោទប្រគល់មកអង្គជំនុំជម្រះភ្លាមនូវលិខិតលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់របស់ជនជាប់ចោទ។ បង្គាប់ឲ្យផ្នែកខាងសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះអាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមបន្ទប់សវនាការនេះ ក្នុងរយៈពេលកិច្ចដំណើរការសវនាការសម្រាប់រសៀលនេះ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅ

កាន់បន្ទប់ខាងក្រោម នៅក្រោមបន្ទប់សវនាការនេះ ដោយទុកឲ្យលោក នួន ជា នៅក្នុងបន្ទប់ឃុំខ្លួន ដែលមានរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចបន្តតាមដានកិច្ចដំណើរការ សវនាការពីចម្ងាយសម្រាប់រសៀលនេះ និងដោយឡែកបង្គាប់ឲ្យនាំខ្លួនលោក ខៀវ សំផន មកកាន់បន្ទប់ សវនាការវិញនៅរសៀលនេះមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០២ នាទី ដល់ម៉ោង ១៣:៣១នាទី)*

[១៣:៣១:១៤]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងសូមផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាអន្តរជាតិដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន អស់លោក លោកស្រីចៅក្រមជាទីគោរព ហើយនិងភាគីទាំងអស់។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ហើយសូមជម្រាបសួរលោកសាក្សី។ កាលពីព្រឹកមិញយើងបានចោទសំណួរទៅលោក ទៅនឹងរយៈពេលដែលមុនពេលដែលដណ្ដើមបានទីក្រុងភ្នំពេញ ហើយព្រឹក-- រសៀលនេះ ហើយនិង ព្រឹកស្អែកយើងនឹងនិយាយអំពីរយៈពេលចន្លោះខែមេសា ឆ្នាំ១៩៧៥ ដល់ខែមករា ១៩៧៩ នេះជាអ្វី ដែលយើងចាប់អារម្មណ៍។

[១៣:៣២:៤៥]

ហើយខ្ញុំសូមថា សួរថា តើលោកអាចប្រមូលអារម្មណ៍ទៅនៅក្នុងបរិបទជាក់លាក់នេះ ហើយ

និងសូមឲ្យលោករំឭកនូវអង្គហេតុទាំងឡាយដែលកើតមាននៅសម័យនោះ។ បាទ ខ្ញុំសូមអរគុណលោកជាមុន។ សំណួររបស់ខ្ញុំនឹងនិយាយអំពីរចនាសម្ព័ន្ធរដ្ឋបាលនៃ/និងប្រព័ន្ធទំនាក់ទំនង ហើយនិងតួនាទីរបស់ជនជាប់ចោទ ហើយនិងគោលនយោបាយផ្សេងៗ។ លោកសាក្សី សំណួរទីមួយរបស់ខ្ញុំ គឺចង់ដឹងថាតើលោកធ្វើការនៅឯណាក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ នៅពេលដែលលោកបានមកដល់ទីក្រុងភ្នំពេញនោះ?

**លោក សាឡុត បាន៖**

**ឆ៖** ក្រោយឆ្នាំ១៩៧៥ ខ្ញុំចូលមកភ្នំពេញ បោសច្រាសអនាម័យនៅទីកន្លែងក្រសួងការបរទេស។ សព្វថ្ងៃនេះគឺទីស្ដីការនាយករដ្ឋមន្ត្រីបាទ។

[១៣:៣៤:២៥]

**ស៖** បន្ទាប់ពីថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ តើលោកមកដល់ទីក្រុងភ្នំពេញនោះរយៈពេលប៉ុន្មានក្រោយថ្ងៃ១៧ មេសា នេះ?

**ឆ៖** រយៈប្រហែលជាមួយខែជាងបន្តិចបន្តួចបាទ មកដល់ក្រុងភ្នំពេញ។

**ស៖** លោកនិយាយថា លោកបានធ្វើការបោសសម្អាតនៅក្រសួងការពារជាតិ។ តើនៅក្នុងបរិវេណនេះតើមានក្រសួងមួយទៀតនៅទីនុំងដែរ ឬក៏យ៉ាងណា?

**ឆ៖** សូមទោសក្រសួងការបរទេស បច្ចុប្បន្នទីស្ដីការនាយករដ្ឋមន្ត្រី។

[១៣:៣៥:៣០]

**ស៖** លោកបានធ្វើការឲ្យក្រសួងការពារជាតិ ឬក៏ក្រសួងការបរទេស? ខ្ញុំយល់មិនច្បាស់ទេ។

**ឆ៖** ភ្នំពេញបោសច្រាស បោសច្រាសហ្នឹងកន្លែងទីស្ដីការនាយករដ្ឋមន្ត្រីសព្វថ្ងៃបច្ចុប្បន្នេះ ជាក្រសួងការបរទេសពីជំនាន់នុំង ជំនាន់សម័យ៧៥ ហ្នឹង។

**ស៖** បាទ សូមអរគុណ។ តើអ្នកណាជាអ្នកសម្រេចចិត្តចាត់តាំង ឲ្យលោកធ្វើការនៅក្រសួងការបរទេសនោះ?

**ឆ៖** គឺលោក ប៉ង់។

**ស៖** ហើយនៅពេលដែលលោកបានធ្វើការបោសច្រាសកន្លែងនោះហើយនោះ តើលោកបានទទួលមុខងារអ្វីដែរនៅក្រសួងការបរទេសនោះ?

**ឆ៖** អត់មានតួនាទីអីទេក្នុងការបោសច្រាសហ្នឹង ជាយុទ្ធជនធម្មតា។

**ស៖** ខ្ញុំយល់។ ប៉ុន្តែបន្ទាប់ពីយើងបានធ្វើការបោសសម្អាតហើយនោះ នៅពេលដែលក្រសួងការបរទេសនោះបានចាប់ផ្តើមបើកទ្វារហើយ តើលោកបានទទួលមុខងារអ្វីដែរ?

[១៣:៣៧:៣៩]

**ឆ៖** មុខងារដែលខ្ញុំទទួលហ្នឹង ដូចជាៗចម្រុះមិនច្បាស់លាស់ជាមុខងារអីទេ បន្ទាប់មកប្រហែលជាតាមខ្ញុំចាំបង អៀង សារី លោកមកពីបរទេសវិញ បានរៀបចំឲ្យខ្ញុំនេះ ទទួលខុសត្រូវខាងផ្នែកការងារសតិអារម្មណ៍របស់បងប្អូន។

**ស៖** ឥឡូវ ខ្ញុំត្រឡប់មកនិយាយពីមុខងាររបស់លោកនៅពេលក្រោយ។ នៅពេលដែលលោក អៀង សារី បានត្រឡប់មកទីក្រុងភ្នំពេញ តើកាលនោះគាត់មានមុខងារអ្វីដែរ នៅពេលដែលគាត់ត្រឡប់មកទីក្រុងភ្នំពេញនោះ?

**ឆ៖** ត្រឡប់មកទីក្រុងភ្នំពេញវិញ ខ្ញុំឃើញថា គាត់ទាក់ទងជាមួយបរទេស។ ដូច្នេះខ្ញុំសន្និដ្ឋានថា គាត់ជាក្រសួង នៅក្នុងក្រសួងការបរទេសនេះហើយ។

**ស៖** ហើយកាលនោះ គាត់កាន់តំណែងអ្វីដែរនៅក្រសួងការបរទេស?

**ឆ៖** ដូចជាឧបនាយករដ្ឋមន្ត្រី ហើយទទួលបន្ទុកខាងកិច្ចការងារបរទេស។

[១៣:៣៩:៤៩]

**ស៖** តើពេលដែលគាត់មកដល់ទីក្រុងភ្នំពេញភ្លាម គាត់កាន់តំណែងហ្នឹងភ្លាម ឬក៏យ៉ាងម៉េច?

**ឆ៖** គាត់មិនទាន់កាន់តំណែងភ្លាមទេ ទាល់តែបោសជ្រះអីស្រោតបាត អ្ហ្ហ! យូរណាស់ប្រហែលពីរបីខែឯណោះ បានរៀបចំជាក្រសួង ជាក្រសួងហ្នឹងមិនទាន់រៀបរយអីទេ។

**ស៖** កាលពីព្រឹកមិញ លោកបានលើកឡើងអំពីឈ្មោះ សារិន ឆាក ខ្ញុំគិតថាលោកស្គាល់គាត់ហើយ តើលោកដឹងថា សារិន ឆាក នោះកាន់មុខតំណែងអ្វីដែរនៅសម័យនោះ? គឺថាមុនពេលដណ្តើមបានទីក្រុងភ្នំពេញ ហើយនិងក្រោយពេលដណ្តើមបានទីក្រុងភ្នំពេញមួយភ្លែតមកនោះ?

**ឆ៖** ខ្ញុំអត់ច្បាស់ទេ បញ្ហានេះបាទ។ ខាងបច្ចេកទេសក្រសួងការបរទេស ខ្ញុំគិតគូរតែអំពីរឿងជីវភាពបងប្អូន និងធ្វើការងារសតិអារម្មណ៍បងប្អូនតែប៉ុណ្ណោះ។

**ស៖** តើការិយាល័យនៃក្រសួងការបរទេសនោះ នៅកន្លែងដដែលតាំងពីដើមមករហូតដល់ឆ្នាំ ១៩៧៩ ឬក៏មានការផ្លាស់ប្តូរទៅកន្លែង?

[១៣:៤១:៣៦]

**ឆ៖** អត់មានការផ្លាស់ប្តូរទីកន្លែងទេ។

**អ្នកបកប្រែ៖**

សូមលោកប្រធានឲ្យសាក្សីកុំអាលឆ្លើយសិន ចាំឲ្យបកប្រែសំណួរចប់ចាំឲ្យគាត់ឆ្លើយ។ អ៊ីចឹងខាងបកប្រែបកអត់ទេ។

**លោក វ៉ាំងសង់ វ៉ាយឌ័ ដេស្នាឯល៖**

លោកប្រធាន ខ្ញុំអត់ស្តាប់ឮការបកប្រែទេ។

**ប្រធានអង្គជំនុំ៖**

លោកតាំងសំណួរអម្បាញ់មិញនេះសាជាថ្មីម្តងទៀត ហើយសូមធ្វើដូចអ្វីដែលបានធ្វើតាំងពីព្រឹកមក គឺសូមលោកតំណាងសហព្រះរាជអាជ្ញាក៏បង្អង់បន្តិច ហើយនិងសាក្សីដូចគ្នាបង្អង់បន្តិចរង់ចាំមានភ្លើងក្រហមនៅក្បាលមីក្រូសូមចាប់ផ្តើមនិយាយ ដើម្បីឲ្យគម្លាតគ្នានេះ នាំឲ្យការបកប្រែហ្នឹងបានចប់សព្វគ្រប់សិន។

[១៣:៤២:៣៣]

**សួរដោយលោក វ៉ាំងសង់ វ៉ាយឌ័ ដេស្នាឯល៖**

**ស៖** បាទ ខ្ញុំចោទសំណួរឡើងវិញ តើក្រសួងការបរទេសនោះស្ថិតនៅកន្លែងដដែលតាំងពីឆ្នាំ ១៩៧៥ ដល់១៩៧៩ ឬក៏មានការផ្លាស់ប្តូរទីកន្លែង?

**លោក សាឡុត បាន៖**

**ឆ៖** អត់មានការផ្លាស់ប្តូរទីកន្លែងទេ។

**ស៖** បាទសូមអរគុណ។ បាទលោកបានប្រាប់ខ្ញុំថា លោក អៀង សារី ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកការបរទេស តើលោកដឹងថាគាត់ជាសមាជិកនៃគណៈមជ្ឈិមដែរឬទេ?

**ឆ៖** ខ្ញុំអត់ដឹងច្បាស់លាស់ទេ ឮតែគេថា។

**ស៖** តើលោក អៀង សារី ជាសមាជិកនៃគណៈអចិន្ត្រៃយ៍ដែរឬទេ បើតាមលោកដឹងនោះ?

[១៣:៤៣:៤៧]

**ឆ៖** ខ្ញុំអត់បានចូលរួមទេ។ ដូច្នេះ ខ្ញុំអត់ដឹងច្បាស់ទេ។

**លោក វ៉ាំងសង់ វ៉ាយឌ័ ដេស្នាឯល៖**

សូមអរគុណ។ កាលពីព្រឹកមិញហ្នឹង ខ្ញុំបានផ្តល់ឯកសារទៅដល់សាក្សី គឺឯកសារ E3/446

ដែលជាឯកសារ D369/36 ហើយសូមតុលាការអនុញ្ញាតឲ្យយើងខ្ញុំបង្ហាញឯកសារ ដែលមានចម្លើយរបស់សាក្សី។ បើសិនជាខ្ញុំមិនច្រឡំទេ គឺថាចម្លើយនៅបន្ទាត់លេខ៣៧ នៃឯកសារនេះ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត ហើយមន្ត្រីរដ្ឋបាលពិនិត្យមើលឯកសារជាមួយសាក្សីដើម្បីចង្អុលបង្ហាញគាត់ឲ្យចំចំណុចដែលតំណាងសហព្រះរាជអាជ្ញាប៉ុនប៉ងក្នុងការសួរដេញដោល។

[១៣:៤៥:៣២]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** នៅសំណួរលេខ៣៦។ ឆ្លើយតបទៅនឹងសំណួរនេះ លោកនិយាយថា “អត់ទេគាត់មិនមែនជាសមាជិកអចិន្ត្រៃយ៍ទេ។ សមាជិកអចិន្ត្រៃយ៍មានតែពីរបីនាក់ទេ ដូចជា ប៉ុល ពត, នួន ជា, អៀង សារី និង តាម៉ុក”។ បាទ សំណួរខ្ញុំដូចតទៅនេះ។ នៅពេលនោះ ថានៅឆ្នាំ២០10 លោកបាននិយាយទៅអ្នកស៊ើបអង្កេតថា អៀង សារី ជាសមាជិកនៃគណៈអចិន្ត្រៃយ៍ ហើយថ្ងៃនេះ លោកប្រាប់ថាលោកមិនសូវចាំទេ។ តើវគ្គនេះធ្វើឲ្យលោកនឹកឃើញរឿងកាលពីសម័យនោះដែរឬទេ?

**លោក សាឡុត បាន៖**

**ឆ៖** បាទ ខ្ញុំនិយាយថា ខ្ញុំប្រជុំ ខ្ញុំមិនបានប្រជុំទេ ខ្ញុំមិនដឹងច្បាស់ទេ។ ដូច្នេះ បញ្ហាអចិន្ត្រៃយ៍ពីរបីនាក់នេះ គឺខ្ញុំឮសួរគេនិយាយ ហើយទៅដំណើរការទស្សនកិច្ចអីផ្សេងៗ បានខ្ញុំដឹងថា អ៎ូ! បង អៀង សារី ជាឧបនាយករដ្ឋមន្ត្រីក្រសួងការបរទេស ឯប្រកាសឲ្យខ្ញុំដឹង អត់បានដឹងទេ។ ការនិយាយដូច្នេះ បាទ។

[១៣:៤៧:១៦]

**ស៖** នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ជាទូទៅនៅក្នុងស្ថាប័នរដ្ឋអំណាចផ្សេងៗ តើបុគ្គលដែលជាសមាជិកនៃស្ថាប័នទាំងអស់នោះអាចធ្វើសេចក្តីសម្រេចដោយម្នាក់ឯង ឬក៏ត្រូវតែធ្វើសេចក្តីសម្រេចជាសមូហភាព?

**ឆ៖** ខ្ញុំអត់ច្បាស់ទេបាទ។ ប៉ុន្តែជាគោលការណ៍ គឺសម្រេចដោយសមូហភាព។

**ស៖** ឧទាហរណ៍ថា ប៉ុល ពត អាចធ្វើសេចក្តីសម្រេចតែម្នាក់ឯងបានដែរឬទេ នៅក្នុងគណៈមជ្ឈិម ឬក៏គណៈអចិន្ត្រៃយ៍នោះ?

**ឆ៖** --

**ប្រធានអង្គជំនុំ៖**

សូមៗកុំអាលឆ្លើយ! កុំអាលទាន់ឆ្លើយសាក្សី! ចាំអង្គជំនុំជម្រះស្តាប់ការសេចក្តីជំទាស់របស់មេធាវីការពារក្តីលោក អៀង សារី ជាមុនសិន។

សូមអញ្ជើញលោកមេធាវី!

[១៣:៤៨:៣៣]

**លោក ម៉ៃខល កាណាវាស៖**

ទីមួយ នេះគឺសំណួរបែបនេះមានចរិតលក្ខណៈនាំមុខហើយ ខ្វះមូលដ្ឋានត្រឹមត្រូវ។ គាត់ត្រូវតែសួរថា តើសាក្សីជាសមាជិក ឬក៏ចូលរួមប្រជុំជាមួយគណៈអចិន្ត្រៃយ៍ដែរ ឬក៏យ៉ាងណា? ឬក៏ថាយ៉ាងហោចណាស់ សួរថាតើគាត់បានដឹងកិច្ចប្រជុំទីមួយរបស់គណៈអចិន្ត្រៃយ៍យ៉ាងម៉េច? ដូចការចោទសួរបែបនេះ គឺមិនមានមូលដ្ឋាន ប្រហែលជាពូរបស់គាត់បានប្រាប់ទៅគាត់ ឬក៏គាត់មានទំនាក់ទំនងជាមួយអ្នកណា?

ដូច្នេះ ខ្ញុំគិតឃើញថា មិនគួរណាសួររបៀបឲ្យសាក្សីឆ្លើយស្មានៗនោះទេ។ សូមអរគុណលោកប្រធាន។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន គឺថាយើងខ្ញុំមានមូលដ្ឋានលើសំណួរនេះ ពីព្រោះថានៅចំពោះមុខចៅក្រមស៊ើបអង្កេតសំណួរមួយចំនួនបានចោទសួរទៅសាក្សី ហើយដោយសារគាត់ស្គាល់ ប៉ុល ពត ពីព្រោះ ប៉ុល ពត ជាពូរបស់គាត់ ហើយគាត់ជាសមាជិកនៃគណៈអចិន្ត្រៃយ៍។

[១៣:៤៩:៤០]

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន សាក្សី-- សហព្រះរាជអាជ្ញា គឺថាគាត់មិនយល់ការជំទាស់របស់ខ្ញុំ។ នៅក្នុងចម្លើយដែលសហចៅក្រមស៊ើបអង្កេតបានសម្ភាសគាត់នេះ នេះមិនមែនជាមូលដ្ឋានទេ មូលដ្ឋានគឺត្រូវយកមកផ្តើមមូលដ្ឋាននៅទីនេះនៅក្នុងបន្ទប់សវនាការ ដោយនិយាយទាក់ទងទៅនឹងគោលការណ៍នៃហេដ្ឋារចនាសម្ព័ន្ធរបស់ស្ថាប័ន។ បើសិនណាជាយកមូលដ្ឋាននៅក្នុងឯកសារ ចាំបាច់មកចោទសួរសាក្សីធ្វើអ្វី? ម៉េចក៏មិនគ្រាន់តែសូមឲ្យសាក្សីគាត់ពិនិត្យមើលឯកសារទៅ ហើយចប់សព្វគ្រប់ឲ្យគាត់ទៅផ្ទះវិញទៅ។ ដូច្នេះ ខ្ញុំគិតឃើញថា ត្រូវតែមូលដ្ឋានគ្រឹះដើម្បីតាំងសំណួរ តាំងសំណួរទៅកាន់សាក្សី

រូបនេះ។

នេះជារបៀបមួយដែលខ្ញុំៗយល់ឃើញថា ជាគោលការណ៍នៃការសួរដេញដោលផ្ទាល់មាត់នៅក្នុងបន្ទប់សវនាការ។ ខ្ញុំមិនមានជំទាស់ថា មិនអាចយកចម្លើយរបស់សាក្សីពីមុនៗរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតមកប្រើប្រាស់នោះទេ ខ្ញុំមិនបានថាអ៊ីចឹងទេ។ ដោយសារថា-- ដូច្នេះហើយខ្ញុំយល់ឃើញថា នៅក្នុងរបាយការណ៍ខ្លះ គឺវាមានមូលដ្ឋានរបស់វា អ៊ីចឹងយើងយកមូលដ្ឋានយកមកធ្វើជាការតាំងសំណួរ។ អ៊ីចឹងហើយជាខ្ញុំជំទាស់ទៅនឹងសំណួរបែបនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ មានអីត តបទៅនឹងសេចក្តីជំទាស់របស់មេធាវីអន្តរជាតិការពារក្តីលោក អៀង សារី ដែលបានជំទាស់អម្បាញ់មិញដែរទេ?

[១៣:៥១:២៨]

**លោក វាំងសង់ វ៉ាយដ៏ ដេស្មាឯល៖**

បាទលោកប្រធាន ឥឡូវខ្ញុំត្រឡប់មកនិយាយអំពីបញ្ហានេះវិញ។ សាក្សីគាត់បាននិយាយថា គាត់ស្គាល់ ប៉ុល ពត ហើយដែលគាត់ដឹងថា ប៉ុល ពត ជាសមាជិកគណៈអចិន្ត្រៃយ៍។ ហើយពីគោលការណ៍នៃការសម្រេចនៅក្នុងស្ថាប័នកម្ពុជាប្រជាធិបតេយ្យហ្នឹង គឺថាមានជាលក្ខណៈសមូហភាព។ ដោយសារ ប៉ុល ពត ជាឮរបស់សាក្សី ខ្ញុំសួរគាត់ថាតើ ប៉ុល ពត មានសិទ្ធិសម្រេច-- ធ្វើសេចក្តីសម្រេចម្នាក់ឯងបានដែរឬទេ? ខ្ញុំគិតថានេះជាទំនាក់ទំនងរវាងសំណួរខ្ញុំ ហើយអ្វីដែលសាក្សីបានលើកឡើង។

[១៣:៥២:០៧]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៥៣:៣៧]

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់របស់មេធាវី ម៉ៃខល កាណាវាស ដែលជាមេធាវីការពារក្តីលោក អៀង សារី ជំទាស់នឹងការតាំងសំណួរចុងក្រោយអម្បាញ់មិញនេះ ដោយតំណាងសហព្រះរាជអាជ្ញាអន្តរជាតិគ្មានប្រសិទ្ធភាព។ អង្គជំនុំជម្រះត្រូវការស្តាប់នូវចម្លើយនេះ។

សាក្សីអាចឆ្លើយតបទៅនឹងសំណួរ ដែលតំណាងសហព្រះរាជអាជ្ញាសួរចុងក្រោយអម្បាញ់មិញនេះ។

ទំនងជាសាក្សីភ្លេចសំណួរហើយ សូមតំណាងសហព្រះរាជអាជ្ញាអន្តរជាតិតាំងសំណួរចុង ក្រោយដែលលោកសួរទៅសាក្សីនេះសាជាថ្មីម្តងទៀត ដើម្បីឲ្យគាត់ស្តាប់បាន ស្តាប់យល់ ហើយដើម្បី អាចមានលទ្ធភាពក្នុងការឆ្លើយតបទៅនឹងសំណួរបាន។

[១៣:៥៤:៣៣]

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** បាទ សំណួរគឺថា តើ ប៉ុល ពត អាចធ្វើសេចក្តីតែម្នាក់ឯងនៅក្នុងគណៈមជ្ឈិម ឬក៏គណៈ អចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

**លោក សាឡុត បាន៖**

**ឆ៖** ផ្ទៃក្នុងរបស់អចិន្ត្រៃយ៍ ឬគណៈមជ្ឈិមខ្ញុំអត់បានយល់ដឹងច្បាស់លាស់ទេ។

**ស៖** អម្បាញ់មិញនេះលោកបាននិយាយថា នួន ជា ជាសមាជិកគណៈអចិន្ត្រៃយ៍។ តើតួនាទី របស់គាត់ជាក់លាក់នុ៎ងជាអ្វី?

**ឆ៖** ខ្ញុំអត់ដឹងតួនាទីជាក់លាក់ទេ។

[១៣:៥៥:៥៣]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារថ្មីទៅសាក្សី គឺជាកំណត់ហេតុស្តាប់ចម្លើយរបស់ សាក្សីចុះថ្ងៃទី-- ដែលជាឯកសារ E3/413 ហើយនិងឯកសារ D233/2 គឺជាកំណត់ហេតុស្តាប់ចម្លើយ នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩ លេខទំព័រ១ទី៦ ជាភាសាអង់គ្លេស 00361013 ហើយនិង ERN ជា ភាសាបារាំងគឺ 00405455 ហើយនិង ខ្ញុំផ្តល់លេខ ERN ជាភាសាខ្មែរបន្ថែមទៀតនេះ បើសិនជា អង្គជំនុំជម្រះអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ អាចដាក់បញ្ចាំងលើអេក្រង់កុំព្យូទ័រ ហើយនិងមន្ត្រីរដ្ឋបាលតុលាការ ទទួលឯកសារពីតំណាងសហព្រះរាជអាជ្ញាយកទៅជូនសាក្សីពិនិត្យ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ លេខ ERN ភាសាខ្មែរគឺ 00357530១។

[១៣:៥៨:២៣]

**សួរដោយលោក វ៉ាំងសង់ វ៉ាយជ៍ ដេស្នាឯល៖**

**ស៖** បាទ នេះគឺជាសំណួរវែងដែលចោទទៅសាក្សីដែលទាក់ទងទៅលោក គាត ឈន់ ហើយ និង ជួន ប្រាសិទ្ធិ។ ហើយនៅក្នុងចម្លើយរបស់គាត់នេះ សាក្សីលើកឡើងយ៉ាងដូច្នេះ គាត់និយាយអំពីឧបទ្ទវហេតុជាមួយ ហ៊ូ យន់ ហើយគាត់បានលើកឡើងថា នេះបានន័យថា ប៉ុល ពត មិនអាចធ្វើសេចក្តីសម្រេចដោយខ្លួនឯងទេ បើតាមខ្ញុំដឹងហ្នឹងគឺថា ពូ ប៉ុល ពត ជាអ្នកទទួលខាងនយោបាយ ហើយបង នួន ជា ទទួលបន្ទុកខាងការរៀបរយរដ្ឋបាល--

[១៣:៥៩:០២]

ហើយប្រហែលជាមានបញ្ហាបកប្រែបន្តិចជាភាសាអង់គ្លេសនោះ អត់មាននិយាយខាងផ្នែកការចាត់តាំង ចាត់ចែងខាងរដ្ឋបាលទេ ក៏ប៉ុន្តែខាងការតែងតាំងកម្មាភិបាលទៅវិញ។

តើលោកអាចបញ្ជាក់អំពីតួនាទីរបស់លោក នួន ជា ទាក់ទងនឹងការចាត់តាំងកម្មាភិបាលដែរឬទេ?

**លោក សាឡុត បាន៖**

**ឆ៖** បាទ បញ្ហានេះគឺខ្ញុំមិនច្បាស់លាស់ទេ។

[១៤:០០:០០]

**ស៖** តើលោករក្សាចម្លើយរបស់លោក ឬក៏លោកបដិសេធនូវចម្លើយរបស់លោក?

**ឆ៖** ខ្ញុំមិនបដិសេធចម្លើយខ្ញុំទេ។

**ស៖** តើលោករក្សាចម្លើយរបស់លោក ឬក៏យ៉ាងណា?

**ឆ៖** ខ្ញុំរក្សាចម្លើយរបស់ខ្ញុំបាទ។

**ស៖** បើសិនជាលោក នួន ជា ជាអ្នកទទួលខុសត្រូវខាងការចាត់តាំងកម្មាភិបាលនៅក្នុងបក្ស តើគាត់ជាអ្នកចាត់តាំងកម្មាភិបាលដែលទទួលបន្ទុកខាងសន្តិសុខដែរឬទេ?

**ឆ៖** ខ្ញុំអត់បាន--

**ប្រធានអង្គជំនុំ៖**

កុំអាល់ទាន់ឆ្លើយនឹងសំណួរ សាក្សី បង្អង់បន្តិចសិន ចាំស្តាប់អង្គជំនុំជម្រះសម្រេចលើការជំទាស់របស់មេធាវីការពារក្តី នួន ជា។ សូមអញ្ជើញលោកមេធាវី!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ សាក្សីបានបញ្ជាក់ថា គាត់អាចទទួលស្គាល់នូវចម្លើយរបស់គាត់ គាត់មិនបាននិយាយថា កូនក្ដីរបស់ខ្ញុំទទួលបន្ទុកចំពោះមនុស្សទាំងអស់នៅក្នុងបក្សនោះទេ។

[១៤:០១:៤៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអាចតាំងសំណួរចុងក្រោយ ចំពោះសាក្សីសាជាថ្មីម្ដងទៀតបាទ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** សំណួរគឺថា តើលោករក្សាចម្លើយរបស់លោក ទាក់ទងទៅនឹងការតែងតាំងកម្មាភិបាល ដោយលោក នួន ជា ឬក៏-- ហើយឬក៏ នួន ជា ដដែលហ្នឹង គាត់ជាអ្នកតែងតាំងកម្មាភិបាល ទទួលបន្ទុកខាងសន្តិសុខផងដែរ តើអ៊ីចឹងមែនទេ?

**លោក សាឡុត បាន៖**

**ឆ៖** ខ្ញុំដឹងថា លោក នួន ជា ទទួលខុសត្រូវខាងចាត់តាំង។ ឯចាត់តាំងអីៗ ខ្ញុំអត់ដឹងទេ។

**ស៖** បាទ សូមអរគុណ។ តើលោកបានជួប ប៉ុល ពត, នួន ជា ជាញឹកញាប់ និងលោក អៀង សារី, លោក ខៀវ សំផន, សុន សេន ឬក៏អ្នកថ្នាក់ដឹកនាំផ្សេងទៀត ឃើញគាត់ប្រជុំជាមួយគ្នានៅក្នុងចន្លោះខែមេសា ឆ្នាំ១៩៧៥ និងខែមករា ឆ្នាំ១៩៧៩ ដែរឬទេ?

[១៤:០៣:១២]

**ឆ៖** ខ្ញុំឃើញគាត់ប្រជុំ ប៉ុន្តែមិនដឹងនិយាយរឿងអីទេ។

**ស៖** តើកិច្ចប្រជុំនោះ បានធ្វើឡើងនៅកន្លែងណាដែរ?

**ឆ៖** សូមទោស ពីឆ្នាំណាដល់ឆ្នាំណាបាទ?

**ស៖** បាទ គឺរយៈពេលដដែល គឺថាខែមេសា ឆ្នាំ១៩៧៥ ដល់ ខែមករា ឆ្នាំ១៩៧៩ លោកបាននិយាយថា ពួកគាត់បានប្រជុំជាញឹកញាប់ ហើយខ្ញុំសួរថា តើគាត់ប្រជុំនៅកន្លែងណា?

**ប្រធានអង្គជំនុំ៖**

សូមម្ដងទៀត ដូចជាអាចមានការភ័ន្តច្រឡំ ពីមេសា ឆ្នាំ១៩៧៥ ទៅមករា ឆ្នាំ១៩៧៥។ បានន័យថា បញ្ច្រាសវិញ រាប់នោះ វាលេខបញ្ច្រាស់ វាគួរតែមករា ៧៩ អាហ្នឹង បានជាអំឡុងរយៈនៃការសួរ

ដេញដោលនេះ គឺចន្លោះខែមេសា ១៧ មេសា ៧៥ ទៅ០៦ មករា ៧៩។ សូមបញ្ជាក់ម្តងទៀត ពីព្រោះអ៊ីចឹង អ្នកសាក្សីមិនដឹងឆ្លើយថាម៉េចទេ។ នៅតែ៧៥ ហើយបញ្រ្ចាសវិញ ពីខែបួន ៧៥ មក ខែមួយ ៧៥។

[១៤:០៥:៥៦]

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** បាទអ៊ីចឹង ខ្ញុំគិតថា ខ្ញុំបាននិយាយថាចន្លោះខែមេសា ឆ្នាំ១៩៧៥ ដល់ មករា ឆ្នាំ១៩៧៩ ហើយសំណួរសួរថា តើកិច្ចប្រជុំនៃថ្នាក់ដឹកនាំខ្មែរក្រហមនោះ បានប្រព្រឹត្តឡើងនៅកន្លែងណា?

**ឆ៖** ខ្ញុំដាច់ពី ប៉ុល ពត ហើយ។ ឆ្នាំ១៩៧៥ មក លោកនៅកន្លែងផ្សេង ខ្ញុំនៅឯក្រសួងការបរទេសជាមួយលោក អៀង សារី។ ដូច្នេះ ខ្ញុំមិនឃើញ មិនដែលឃើញគាត់ប្រជុំនៅក្រសួងទេ។ ឯប្រជុំនៅកន្លែងគាត់នោះ ខ្ញុំមិនដឹងទេបាទ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកសាក្សី លោកបានទទួលហើយកាលពីព្រឹកមិញនេះ នៅឯកសារដែលលេខ D369/36។ សូមលោកប្រធាន សូមអនុញ្ញាត-- ខ្ញុំសួរទៅលើចម្លើយលេខ៣២ នៃឯកសារនេះ។ ឯកសារនេះមានលេខ E3/446។ សូមអនុញ្ញាតបញ្ចាំងឯកសារដែលមានលេខចម្លើយទី៣២ ដែលសាក្សីនេះបានផ្តល់ជូនអ្នកស៊ើបអង្កេតនៅក្នុងអំឡុងកិច្ចស៊ើបសួរ។

[១៤:០៧:១៣]

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ខ្ញុំសូមអានសំណួរដែលបានចោទសួរទៅលោក។ សំណួរទី៣២ "តើលោកធ្លាប់ឃើញ ខៀវ សំផន, អៀង សារី, និង នួន ជា ប្រជុំជាមួយគ្នាដែរឬទេ? ចម្លើយ បាទ គាត់ធ្លាប់ប្រជុំ ហើយពេលដែលប្រជុំសម្ងាត់ គឺធ្វើនៅ ក-១ ក្បែរមាត់ទន្លេ មិនមែនប្រជុំនៅក្រសួងការបរទេសទេ"។ លោកសាក្សី តើលោកមាននៅចាំ អំពីកិច្ចប្រជុំទាំងអស់នេះទេ? ហើយស្គាល់មន្ទីរក-១ ដែរទេ?

**ឆ៖** បាទ មន្ទីរក-១ ខ្ញុំស្គាល់ ដោយខ្ញុំបានទៅម្តងម្កាល ប៉ុន្តែខ្ញុំឃើញមានការប្រជុំនៅទីនោះ។ កន្លែងនោះ គឺកន្លែងនៅរួមគ្នា ជំនាន់នុ៎ង នៅរួមគ្នា អ្នកដឹកនាំទាំងអស់។ ប៉ុន្តែខ្ញុំទៅម្តងៗអ៊ីចឹងទៅ ឃើញប្រជុំអ៊ីចឹងទៅ។ ដូច្នេះ ខ្ញុំមិនដឹងថាប្រជុំរឿងអីទេ។

**ស៖** លោកសាក្សីក្នុងក្របខ័ណ្ឌនៃមុខងារ ប្រហែលជាគាត់មិនចូលរួមក្នុងកិច្ចប្រជុំ តើលោក

ដឹងទេ ថាគាត់មានធ្លាប់ចូលនៅក្នុងកិច្ចប្រជុំរបស់គណៈមជ្ឈិមដែរឬទេ?

**ឆ៖** លោក អៀង សារី អ្នេស? សួរបុគ្គលណា?

[១៤:០៩:២៧]

**ស៖** ខ្ញុំនិយាយពីខ្លួនលោកផ្ទាល់។ តើលោកមានដែលបានចូលរួមនៅក្នុងកិច្ចប្រជុំរបស់គណៈមជ្ឈិមរបស់បក្សដែរឬទេ?

**ឆ៖** ខ្ញុំមិនដែលបានចូលប្រជុំទេ។ យុទ្ធជនតូចតាចណាស់។

**ស៖** ហេតុអីបានជាលោកទៅមន្ទីរក-១ លោកអាចពន្យល់បានទេ ហេតុអីបានជាលោកទៅមន្ទីរក-១?

**ឆ៖** ខ្ញុំមិន-- ខ្ញុំទៅមន្ទីរក-១ ពីព្រោះគ្រួសារខ្ញុំនៅដាំបាយនៅទីនោះ។

**ស៖** តើប្រពន្ធរបស់លោកឈ្មោះអីដែរ?

**ឆ៖** ជូ ឆេង។

**ស៖** តើមន្ទីរដែល-- កន្លែងដែលគាត់ធ្វើការហ្នឹងឈ្មោះអីដែរ?

**ឆ៖** ក-១ ហ្នឹង។

**ស៖** សូមអរគុណ។ តើ ខៀវ សំផន មានតួនាទីអ្វីនៅក្នុងបក្ស នៅក្នុងចន្លោះឆ្នាំ៧៥ និង៧៩? ប្រហែលជាគាត់អាចមានតួនាទីច្រើន តើលោកអាចបង្ហាញអំពីតួនាទីផ្សេងៗរបស់គាត់បានដែរឬទេ?

**ឆ៖** ខ្ញុំទទួលស្គាល់នៅក្នុងឯកសារនេះ។ ក្នុងសេចក្តីស្រពេចស្រពិលដែរ។

**ស៖** តើលោកចង់មានន័យថាម៉េច ដែលថាមានដូចរក្សានៅក្នុងចម្លើយនៅក្នុងឯកសារហ្នឹង? សំណួរខ្ញុំគឺថា តើ ខៀវ សំផន មានតួនាទីអ្វីខ្លះ នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា នៅចន្លោះឆ្នាំ៧៥ និង៧៩? តើគាត់មានមុខងារ ឬតំណែងអីច្រើនដែរឬទេ?

[១៤:១២:០៨]

**ឆ៖** ខ្ញុំមិនបានតាមដានរឿងហ្នឹង ច្បាស់លាស់ទេបាទ។ ខ្ញុំដឹងតែរឿងខ្លួនឯងជាសំខាន់។

**ស៖** តើលោកស្គាល់មន្ទីរ៨៧០ ដែរឬទេ លោកសាក្សី?

**ឆ៖** ៨៧០ ខ្ញុំស្គាល់។ មិនយកកន្លែងណាមួយជាកំណត់ទេ ពីព្រោះមានច្រើនកន្លែង ចល័តបាទ។

**ស៖** តើអ្នកណាជាកម្មាភិបាលជាន់ខ្ពស់នៅមន្ទីរ៨៧០នេះ ដែលលោកបាននិយាយថា ជាមន្ទីរ

ចល័តនោះ?

**ឆ៖** កម្មាភិបាលជាន់ខ្ពស់ គឺថ្នាក់មជ្ឈិមហ្នឹងឯង ជាកម្មាភិបាលជាន់ខ្ពស់បាទ។

**ស៖** តើមានទំនាក់ទំនងទេ រវាង ខៀវ សំផន និងការិយាល័យ-- និងមន្ទីរ៨៧០ នេះ?

**ឆ៖** មានទំនាក់ទំនងម្តងម្កាល។

**ស៖** តើលោកអាចបញ្ជាក់បានទេថា ទំនាក់ទំនងរវាង ខៀវ សំផន និងការិយាល័យ-- និងមន្ទីរ ៨៧០ នេះយ៉ាងម៉េចដែរ?

**ឆ៖** និយាយៗរឿងហ្នឹងគឺថា ប្រវត្តិវាវែងឆ្ងាយណាស់បាទ មន្ទីរវាផ្លាស់ប្តូរច្រើន ផ្លាស់ប្តូរច្រើនកន្លែងបាទ ហើយខ្ញុំមិនដឹងកំណត់កន្លែងណា ដែលប្រជុំអី ខ្ញុំវាមិនចាំទេបាទ។ ខ្ញុំអត់ចាំទេបាទ។ ប៉ុន្មានឆ្នាំទៅហើយ បាទសាម សែសិបឆ្នាំជាងទៅហើយបាទ។

[១៤:១៥:០០]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

ខ្ញុំចង់ត្រឡប់មកនិយាយអំពីឯកសារដដែល ដែលលោកមាននៅក្នុងដៃហើយ គឺលេខឯកសារ D369/36 គឺនៅចម្លើយ៣៩ ដែលលោកបានឆ្លើយនៅចំពោះមុខអ្នកស៊ើបអង្កេត។ ខ្ញុំសូមអានចម្លើយនេះដើម្បីឲ្យលោកចងចាំឡើងវិញ ហើយនិងសួរថាតើលោកនៅរក្សាចម្លើយ ឬយ៉ាងណា។ ហើយសូមសេចក្តីអនុញ្ញាតពីលោកប្រធាន ដើម្បីបង្ហាញឯកាសរនេះនៅអេក្រង់។ សូមអរគុណ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

**ស៖** សំណួរដែលសួរនោះ សួរថា "តើលោក ខៀវ សំផន មានតួនាទីអ្វីនៅក្នុងមន្ទីរ៨៧០? ហើយលោកបានឆ្លើយនៅចម្លើយទី៣៩ ថា តាមខ្ញុំដឹងគាត់ជាសមាជិកមជ្ឈិមបក្ស ប៉ុន្តែចូលអចិន្ត្រៃយ៍ពេលណានោះខ្ញុំមិនដឹងទេ។ គាត់ទទួលបន្ទុកការងាររណសិរ្ស ការប្រមូលកម្លាំង គ្រាន់តែឃើញមកជួបធ្វើការងារខ្ញុំសន្និដ្ឋានថា ខៀវ សំផន ជាប្រធានមន្ទីរ៨៧០ ទទួលបន្ទុកចាត់ចែងសម្ភារៈ ក្រោយពី ស៊ឿ វ៉ាស៊ី ហៅ ឌឿន ត្រូវបានចាប់ខ្លួន"។ ហើយនៅក្នុងចម្លើយដដែលនោះ នៅឃ្លាចុងក្រោយ "ដល់យូរៗទៅគាត់ឡើងជាប្រធានរដ្ឋ បានមកនៅក្នុងមន្ទីរមជ្ឈិមតែម្តង"។

លោកសាក្សី តើលោកមាននៅចងចាំទេ អំពីឃ្លានេះ? តើលោកអាចពន្យល់ឲ្យបានលើសហ្នឹងទេ អំពីតួនាទីរបស់ ខៀវ សំផន នៅក្នុងមន្ទីរ៨៧០ និងនៅក្នុងជួរបក្សនោះ?

[១៤:១៧:២២]

**ឆ៖** ចម្លើយក្នុងឯកសារខ្ញុំទទួល ព្រមយល់ស្របបាទ។ ឯឲ្យខ្ញុំធ្វើអធិប្បាយខ្ញុំភ្លេចភ្លាំងអស់ហើយបាទ ពីព្រោះខ្ញុំឆ្លើយនៅក្នុងនោះ ខ្ញុំសន្និដ្ឋានៗ ពាក្យដែលខ្ញុំសន្និដ្ឋានថាដែរ បាទភ្លេចអស់ហើយ។

**ស៖** តើលោកអាចជម្រាបយើងបានទេថា នៅពេលណាដែរ ដែល សឿ វ៉ាស៊ី ហៅ ឌឿន ត្រូវបានចាប់ខ្លួន ហើយចាប់ខ្លួនពីបទអីដែរ?

**ឆ៖** ខ្ញុំបាទអត់ដឹងទេ បាទ។

**ស៖** តើលោកបានឃើញ ខៀវ សំផន មកម្តងម្កាលនៅមន្ទីរ-- នៅក្រសួងការបរទេសដែរឬទេ?

[១៤:១៨:៥៤]

**ឆ៖** ដូចជាឃើញមកម្តងម្កាលដែរ ប៉ុន្តែនិយាយអំពីរឿងសំបុត្រកប៉ាល់ហោះអីផ្សេងៗបាទ។

**ស៖** តើជារឿងតែមួយហ្នឹងទេដែលគាត់ចាប់អារម្មណ៍ ឬក៏គាត់មកសម្រាប់រឿងអីផ្សេងទៀត?

**ឆ៖** ខ្ញុំអត់មានចាប់អារម្មណ៍អីផ្សេងទេ រឿងបច្ចេកទេសអីសម្រាប់ទៅឆ្លងកាត់ទៅបរទេសតែប៉ុណ្ណោះ។ មិនមែនមានជាការប្រជុំទេ។

**ស៖** នៅពេលដែល ខៀវ សំផន មកក្រសួងការបរទេស តើគឺគាត់មកនៅក្នុងអំឡុងពេលដែល អៀង សារី មក ឬក៏មកនៅពេលដែល អៀង សារី អវត្តមាន?

**ឆ៖** ចាំអត់បាន បាទ។

[១៤:២០:២៤]

**ស៖** ឥឡូវនេះ ខ្ញុំសូមត្រឡប់មកនិយាយអំពីរចនាសម្ព័ន្ធផ្ទៃក្នុងរបស់ក្រសួងការបរទេស ដើម្បីឲ្យយើងច្បាស់លាស់អំពីរចនាសម្ព័ន្ធនេះ។ ខ្ញុំចង់ដឹងអំពីមុខងារពិតប្រាកដរបស់លោកនៅក្នុងក្រសួង។ ក្រោយពេលក្រសួងការបរទេសបានដំណើរការយ៉ាងពេញទំហឹងមក តើលោកមានមុខងារអីខ្លះនៅក្នុងក្រសួងការបរទេសនេះ?

**ឆ៖** ខ្ញុំអត់មានចេះភាសាបរទេសទេ។ ប៉ុន្តែខាងលើដាក់ខ្ញុំឲ្យនៅក្នុងក្រសួងការបរទេស ខ្ញុំមិនយល់ស្របដែរ ក៏ប៉ុន្តែខាងលើ ពិសេសខាងបង អៀង សារី ថាជួយការងារខ្ញុំផង ជួយជាដៃ ជាជើងជាតួនាទីអគ្គលេខាធិការក្រសួងការបរទេស។ ខ្ញុំក៏មិនសូវយល់ដែលអគ្គលេខាធិការហ្នឹងអីៗ ខ្ញុំមិនសូវយល់ទេ ព្រោះកសិករសេរីនោះ ប្រាប់ថាអត់អីទេ គ្រាន់តែមើលការខុសត្រូវធ្វើឲ្យបងប្អូនមានឯកភាពគ្នា។ នេះជាការងាររបស់ខ្ញុំសំខាន់។

[១៤:២២:០៥]

**ស៖** នៅពេលដែលលោកបានក្លាយជាអគ្គលេខាធិការក្រសួងការបរទេស តើលោកមានអាយុប៉ុន្មាន?

**ឆ៖** ប្រហែលជាសាមជាង សាមសិបជាងបាទ។

**ស៖** អាយុសាមជាង ឬក៏លើសពីសាមជាង?

**ឆ៖** មើលខ្ញុំកើតឆ្នាំមួយពាន់ សូមលោកជួយធ្វើលេខផង ឆ្នាំ១៩៤៧ហ្នឹងបាទ។

**ស៖** ប្រសិនបើលោកកើតនៅឆ្នាំ១៩៤៧ នោះលោកមានអាយុប្រហែលជា២៨ឆ្នាំ។ ដើម្បីបំភ្លឺអំពីចំណុចនេះ នៅក្នុងគ្រប់កំណត់ហេតុស្តាប់ចម្លើយរបស់លោកនោះ គឺថ្ងៃកំណើតរបស់លោកគឺឆ្នាំ៥១ ថ្ងៃទី០៩ ធ្នូ ឆ្នាំ៥១ អ៊ីចឹងមានន័យថាអត់ត្រឹមត្រូវទេ មែនទេ ពីព្រោះលោកថា លោកកើតនៅឆ្នាំ៤៧នោះ?

**ឆ៖** អត់ អត់ពួបកប្រែៗ។

[១៤:២៤:០៧]

**ស៖** ខ្ញុំនឹងនិយាយសំណួរឡើងវិញ។ ប្រសិនបើលោកកើតនៅឆ្នាំ១៩៤៧ នៅឆ្នាំ៧៥ លោកមានអាយុប្រហែលជា២៨ឆ្នាំ ប៉ុន្តែខ្ញុំចង់សួរបញ្ជាក់លោកឲ្យបានច្បាស់ ពីព្រោះថានៅក្នុងកំណត់ហេតុស្តាប់ចម្លើយទាំងប្រាំរបស់លោកនោះ នៅពេលដែលលោកឆ្លើយជូនអ្នកស៊ើបអង្កេតនៅម៉ាឡៃនោះ គឺគេសរសេរថាកើតថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៥១ អ៊ីចឹងតើលោកកើតនៅឆ្នាំណា? ៥១ ឬក៏៤៧?

**ឆ៖** និយាយពីប្រវត្តិរូបហ្នឹង គឺថាកាលខ្ញុំធ្វើ ចូលធ្វើទាហានហ្នឹងគឺថាបន្ថយអាយុ បាទ។ អាយុមែនទែនហ្នឹងគឺថា កើតនៅឆ្នាំ១៩៤៧ បាទ។

[១៤:២៥:១៤]

**ស៖** សូមអរគុណ។ អម្បាញ់មិញនេះ លោកបាននិយាយថា លោកត្រូវបានគេតែងតាំងអគ្គលេខាធិការ ហើយលោកនិយាយថា អៀង សារី ជាអ្នកតែងតាំងលោក ហើយគាត់ស្នើសុំឲ្យលោកជួយគាត់។ តើនេះវាជាភស្តុតាងនៃសេចក្តីទុកចិត្តឬ នៅពេលលោកបានធ្វើការបីឆ្នាំ ឬក៏លើសពីនេះនៅក្រសួងការបរទេសនោះ? លោកតែងតែទទួលបាននូវសេចក្តីទុកចិត្តអំពីលោក អៀង សារី មែនទេ?

**ឆ៖** បាទ ប្រហែលអ៊ីចឹងមែន។

**ស៖** មុនពេលឈប់សម្រាក ខ្ញុំចង់សួរសំណួរទូលំទូលាយបន្តិច។ ពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធរបស់ក្រសួងការបរទេស លោកជាអគ្គលេខាធិការ។ តើលោកអាចពន្យល់ជូនយើងទាំងអស់គ្នាបានទេ

ថាមានអង្គភាពអ្វីខ្លះ ឬក៏មន្ទីរ ឬក៏ការិយាល័យ ឬក៏នាយកដ្ឋានអ្វីខ្លះដែលមាននៅក្នុងក្រសួងការបរទេស? សូមឲ្យលោក-- ដើម្បីងាយស្រួលនោះ សូមឲ្យលោករៀបរាប់អំពី ចាប់ពីមេដឹកនាំ សមាជិក គណៈកម្មការផ្សេង ឬក៏មាននាយកដ្ឋាន មានការិយាល័យ មានអង្គភាព។ សូមឲ្យលោករៀបរាប់ពីលើ ពីធំមកតូច។

**ឆ៖** ក្រសួងការបរទេស ផ្នែក មានពីរផ្នែកធំ។ មួយខាង ការបរទេស ដែលចេះភាសាផ្សេងៗច្រើនតែបញ្ញាជន។ ពីរ គឺគិតគូរអំពីរឿងសេដ្ឋកិច្ច ជីវភាពរបស់ក្រសួង និងការងារសតិអារម្មណ៍របស់ក្រសួង។ ការងារសតិអារម្មណ៍នេះ គឺការងារសតិអារម្មណ៍ខាងបង្កបង្កើនផលទេ។ ត្រង់នេះខ្ញុំទទួលខុសត្រូវ។ រចនាសម្ព័ន្ធខាងផ្នែក ខាងការបរទេស ផ្នែកខាងបញ្ញាជនអីដែលទាក់ទងទៅនឹងបរទេស គឺមិនមែនខ្ញុំទទួលខុសត្រូវទេ ខ្ញុំមិនអាចរៀបរាប់បានទេ។ ឯខាងខ្ញុំទទួលខុសត្រូវមានតែផ្នែកដាំដុះ ធ្វើស្រែ ហើយនិងដោះស្រាយសតិអារម្មណ៍របស់បងប្អូនដែលជាកសិករមករួមធ្វើការងារក្នុងក្រសួង។

[១៤:២៨:១១]

**ស៖** អរគុណ។ ប្រសិនបើយើងអាចបែងចែកឲ្យច្បាស់រវាងក្រសួងការបរទេស ដែលលោកបានរៀបរាប់អម្បាញ់មិញនេះ ហើយនិងអង្គភាពផ្សេងៗដែលនៅចំណុះឲ្យក្រសួងការបរទេស ក៏ប៉ុន្តែដែលស្ថិតនៅក្រៅក្រសួង មិនមែនស្ថិតនៅក្នុងទីស្តីការក្រសួងទេ។ សូមចាប់ផ្តើមពីមន្ទីរ តើលោកអាចបញ្ជាក់បានទេ ថាមានគណៈកម្មាធិការគ្រប់គ្រងមន្ទីរប-១ ដែរឬទេ?

**ឆ៖** គណៈគ្រប់គ្រងមន្ទីរប-១ ខ្ញុំគិតគូរខាងផ្នែកដាំដុះ ឈ្មោះអគ្គលេខាធិការមែន ក៏ប៉ុន្តែគិតគូរតែខាងផ្នែកជីវភាពទេ។ ឯផ្នែកបច្ចេកទេសខាងក្រសួង គឺបង អៀង សារី។ ឯការដាំដុះ គឺដាំនៅក្រោយហ្នឹង ដីទំនេរហ្នឹង ដាំដុះនៅត្រង់ហ្នឹងផង ដាំដុះប៉ុណ្ណឹងឯង ហើយផ្តល់ពីកន្លែងភស្តុភារមក បាទ។

**ស៖** សូមអរគុណ។ ប៉ុន្តែលោកដូចជាមិនឆ្លើយទៅនឹងសំណួររបស់ខ្ញុំទេ។ តើមានជាគណៈកម្មាធិការដែរឬទេ? ហើយបើសិនជាមានមែននោះ តើគណៈកម្មាធិការនោះមានសមាសភាពអ្វីខ្លះ?

[១៤:៣០:៥៩]

**ឆ៖** គណៈកម្មាធិការ គឺមានផ្នែកខាងបង អៀង សារី ខ្ញុំមិនយល់ច្រើនទេ។ ឯផ្នែកខាងខ្ញុំមាន ខ្ញុំ មានលោក ជៀម បាទ ពីរនាក់។ ពីណាទៀតទេ ខ្ញុំភ្លេចហើយបាទ ទាំងអស់វាមានបីនាក់បាទ។ ដូចជានារី សួរ សែ ក៏មិនដឹងអីបាទ។ បាទ សូមទោស ខ្ញុំភ្លេចហើយបាទ។

**ស៖** ទោះបីជាមិន-- លោកមិនមែនជាអ្នកទទួលខុសត្រូវផ្នែកខាងបញ្ញាជននៃក្រសួងក៏ដោយ

តើលោកអាចបញ្ជាក់បានទេថា អ្នកណាដែលធ្វើការនៅក្នុងមន្ទីរនយោបាយស្ថិតនៅក្រោម អៀង សារី នោះ? តើលោកអាចផ្តល់ឈ្មោះបានទេ ហើយនិងមុខងាររបស់គាត់ប្រសិនបើលោកស្គាល់នោះ?

**ឆ៖** ក្រសួងការបរទេសចាត់តាំងជាច្រើនផ្នែកណាស់។ ហើយបច្ចេកទេសនោះ ខ្ញុំភ្លាប់វាមិនបាន មានអ្នកទទួលខុសត្រូវខាងអាស៊ីអឺ អឺរ៉ុបអឺណាណីផ្សេង ខ្ញុំមិន-- ការងារហ្នឹងខ្ញុំមិនចូលចិត្ត ខ្ញុំមិនមិនចង់ដឹងមិនចង់ឮបាទ។ ដូច្នេះខ្ញុំឃើញពេលខ្លះប្រជុំជាមួយនឹងគណៈនេះទៅ គណៈនោះទៅ មានបងគាត ឈន់ មានបងឈ្មោះ សួង ស៊ីគឿង មានឈ្មោះ សួរ សែ ខ្ញុំរៀបរាប់មិនអស់ទេបាទ។ ខ្ញុំរៀបរាប់មិនបានក្បោះក្បាយទេបាទ ខាងបច្ចេកទេសក្រសួងហ្នឹងបាទ។

[១៤:៣២:៣៣]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណច្រើន។ លោកប្រធាន ខ្ញុំគិតថាឥឡូវនេះម៉ោងពីរកន្លះជាងហើយ តើលោកប្រធានគិតថា វាជាពេលសមស្របសម្រាប់ការឈប់សម្រាកនៅពេលនេះ ឬក៏យ៉ាងណា? ខ្ញុំគិថាជាពេលសមរម្យហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ម៉ោងបួនសែសិប ហ៎ ម៉ោងពីរសែសិបនាទីទើបសម្រាក។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** មុននឹងត្រឡប់មកនិយាយឲ្យបានច្បាស់អំពីអង្គភាព ឬក៏នាយកដ្ឋានផ្សេងៗដែលលោកជាអ្នកទទួលខុសត្រូវនោះ។ ពាក់ព័ន្ធទៅនឹងអង្គភាពដែលស្ថិតនៅក្រៅក្រសួងការបរទេសផ្ទាល់នោះ គឺនៅក្រោមទីរប-១។ តើលោកអាចរៀបរាប់អំពីអង្គភាពទាំងអស់នេះបានទេ ហើយអាចជម្រាបបានទេថា មន្ទីរទាំងអស់នេះ នៅក្រៅក្រសួង ប៉ុន្តែចំណុះឲ្យក្រសួងដូចជា ខាងផ្នែកបង្កបង្កើនផល ឬក៏មានសកម្មភាពអីផ្សេងៗនោះ?

[១៤:៣៣:៥៦]

**លោក សាឡុត បាន៖**

**ឆ៖** នាយកដ្ឋានដូចជាគ្មានពាក្យនៅក្នុងនុំងទេ បាទ អត់មានទេ អត់មានក្រៅជានាយកដ្ឋានអី

ទេបាទ គឺនៅក្របខ័ណ្ឌតែក្នុងក្រសួងតែមួយ។ ផ្នែកបរទេសទាក់ទងនឹងក្រៅប្រទេស គឺនៅក្នុងក្រសួងហ្នឹង។ ផ្នែកជីវភាពមានការសម្អាតផ្ទះ ទីក្រុង ផ្ទះភ្ញៀវ អីៗហ្នឹង បាទ។ ឯក្រៅពីហ្នឹងបង្កបង្កើនផលបន្តិចបន្តួចនៅក្រោយក្រសួងហ្នឹងតែម្តង បាទ។ ផ្ទះណា មានកន្លែងដាំដុះៗ ត្រង់នុំងទៅ។ របៀបរស់នៅជាកសិករ ក្រសួងមែនក្រសួងការបរទេសមែន ប៉ុន្តែពាក់កណ្តាលសម័យ ពាក់កណ្តាលបុរាណ។ នេះខ្ញុំពិបាកពន្យល់ណាស់បាទ។

[១៤:៣៥:០០]

**ស៖** សូមអរគុណ។ លោកនិយាយអំពីផ្ទះទទួលភ្ញៀវ។ តើផ្ទះភ្ញៀវនេះ មានឈ្មោះពិតប្រាកដទេ? ហើយតើផ្ទះនេះ-- ទាំងនេះហ្នឹង ស្ថិតនៅឯណា?

**ឆ៖** ឲ្យតែកន្លែងណាឃើញផ្ទះស្អាត គឺបោសច្រាសមុនគេបាទ។ ដូចថា បរិវេណណា ទីកន្លែងណាដែលមានរបៀបថាទទួលភ្ញៀវបានសមរម្យ គឺបោសច្រាសមុនគេហើយ។ ដូចជា គេហៅ ក-១ ដែល វេស៊ីដង់ចាស់ហ្នឹង គេហៅ ក-១ បាទ។ អាហ្នឹងធំៗ ខ្ញុំចាំបានប៉ុណ្ណឹងទេ ហើយលេខ ដាក់តែលេខទេ ផ្ទះលេខ១ ផ្ទះលេខ២ អីអ៊ីចឹង។ ផ្ទះលេខ២ គឺនៅសណ្ឋាគាររ៉ូយ៉ាលអី។ រ៉ូយ៉ាលពីដើម ក្បែរវត្តភ្នំនេះ។ ផ្ទះលេខ៣, ៤ អីអ៊ីចឹងទៅបាទ ដាក់ជាលេខ។

**ស៖** តើមានផ្ទះភ្ញៀវនៅខេត្តដែរឬទេ ក្រៅពីភ្នំពេញនោះ?

**ឆ៖** ផ្ទះភ្ញៀវនៅខេត្ត ទាក់ទងតាមខេត្ត ឲ្យគេបោសសម្អាតបាទ។ ហើយកន្លែងណាសំខាន់ ដូចជាទីក្រុងកែប គឺមានផ្នែកខាងខ្ញុំនេះ ឲ្យទៅរៀបចំបាទ។

**ស៖** ចំពោះអង្គភាពបង្កបង្កើនផលវិញ តើអង្គភាពនេះ ឈ្មោះអ្វីឲ្យប្រាកដ? ហើយស្ថិតនៅឯណា ខ្ញុំនិយាយអំពីអង្គភាពបង្កបង្កើនផលដែលនៅចំណុះឲ្យក្រសួងការបរទេស?

[១៤:៣៧:២១]

**ឆ៖** ពីមុនមក នៅក្រោយក្រសួងការបរទេស មានដីធំ ទីធ្លាធំ។ បន្ទាប់មកដូចជា ផ្ទះលេខ១នៅមាត់ទន្លេ ផ្ទះវេស៊ីដង់ពីដើមនោះ។ ពីមុខហ្នឹងមានទីធ្លាដាំប៉េងប៉ោះ ដាំអីបន្តិចបន្តួច។ ក្រោយមកទៀត ឆ្នាំ៧៤ អំនែ ៧៥, ៧៦, ៧៧ បានទៅច្រាំងចំរេះ។ ប្រហែល៧៧។ ៧៧, ៧៨ អីមិនដឹង។ បាទ ៧៧, ៧៨ ហ្នឹង បាទទៅច្រាំងចំរេះ។ ធ្វើស្រូវ ធ្វើស្រែ។

**ស៖** តើលោកមានធ្លាប់ឮគេនិយាយអំពីមន្ទីរបឹងត្របែកដែរឬទេ? តើបឹងត្របែក ស្ថិតនៅក្នុងអង្គភាពបង្កបង្កើនផល ក្រោយចំណុះក្រសួងការបរទេសដែរឬទេ?

**ឆ៖** បឹងត្របែកមិនមែនជាក្របខ័ណ្ឌក្រសួងការបរទេសទេ។ បង្កបង្កើនផលអីរបស់ក្រសួងការបរទេសមិនមែនដែរ។ ស្ថិតនៅក្រោយរបស់លោក ប៉ង់។

**ស៖** អ្វីដែលលោកបាននិយាយប្រាប់យើងនេះ ថាគឺថាមានន័យថា បឹងត្របែកនេះ មិនធ្លាប់ស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រសួងការបរទេសទេ មែនទេ?

**ឆ៖** ខ្ញុំអំមិញនិយាយថា បឹងត្របែកពីមុន មិនមែនស្ថិតនៅក្នុងក្រសួងការបរទេសទេ ប្រហែលជា៧៣, ៧៤ បាននៅក្នុងក្រសួងការបរទេស។

[១៤:៣៩:៤៨]

**ប្រធានអង្គជំនុំ៖**

សាក្សីដូចជាអាចភ័ន្តច្រឡំទេ រឿងកាលបរិច្ឆេទ៧៣, ៧៤ អាចៗនឹកឡើងវិញមើល៎ តើពេលបិរច្ឆេទហ្នឹង វាជាក់លាក់ហ្នឹង ត្រូវឆ្នាំណា?

**លោក សាឡុត បាន៖**

*(និយាយមិនបើកមីក្រូហ្វូន)*

**ប្រធានអង្គជំនុំ៖**

ចាំៗៗមានភ្លើងក្បាលមីក្រូ សឹមនិយាយបាទ។

**លោក សាឡុត បាន៖**

៧៥។ ៧៦ នៅភូមិភាគ៣០៤។ ៧៧ អីហ្នឹង បានការបរទេសទៅគ្រប់គ្រងបាទ។ ខ្ញុំវាភ្លេចឆ្នាំភ្លេចខែអស់ហើយ។

[១៤:៤០:៤៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន។ ឥឡូវនេះ ដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ បង្គាប់ឲ្យមន្ត្រីរដ្ឋបាលសម្របសម្រួលផ្តល់កន្លែងសម្រាកសមរម្យសម្រាប់សាក្សី ហើយនិងមេធាវីប្រឹក្សារបស់គាត់ នៅបន្ទប់សម្រាប់សាក្សី ហើយឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤១ នាទី ដល់ម៉ោង១៥:០១ នាទី)*

[១៥:០១:១៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងប្រគល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាងលេ៖**

បាទសូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាងលេ៖**

**ស៖** លោកសាក្សី ខ្ញុំសូមឲ្យលោកជួយបំភ្លឺនូវអ្វីដែលលោកបាននិយាយមុនពេលយើងសម្រាកនោះ ព្រោះថាមានការច្របូកច្របល់។ នៅពេលដែលលោកបាននិយាយថា អង្គភាពមួយនៃអង្គភាពផលិត បង្កបង្កើនផល ដូចនៅជាចំណុះដល់កងពល៣០៤។ តើលោកនិយាយអំពីបឹងត្របែក ឬក៏អំពីច្រាំងចំរេះ?

[១៥:០២:២០]

**លោក សាឡុត បាន៖**

**ឆ៖** បាទ ខ្ញុំសូមកែតម្រូវ។ អារម្មណ៍ខ្ញុំអំមិញ ដែលនិយាយមុនហ្នឹងគឺផ្តោតទៅលើច្រាំងចំរេះវិញ។ ឥឡូវខ្ញុំសូមកែតម្រូវមកបឹងត្របែក។ ខ្ញុំមិនគ្រប់គ្រងបឹងត្របែកទេ ពេលដែល ប៉ង់ មិននៅ បងអៀង សារី ឲ្យខ្ញុំទៅជួយមើលការខុសត្រូវបណ្តោះអាសន្ន ប្រហែលជាមិនដល់ពីរអាទិត្យទេ គឺទៅនេះគឺរៀបចំដើម្បីសភាពការណ៍យួនចូលស្រុកមក គឺរៀបចំយ៉ាងណាៗ ដើម្បីជម្លៀសតែប៉ុណ្ណោះបាទ។ អត់មាននៅយូរទេ បាទ។

**ស៖** បាទសូមអរគុណ។ គឺថាយើងនឹងត្រឡប់មកនិយាយអំពីអង្គភាពបង្កបង្កើនផលបឹងត្របែក ហើយច្រាំងចំរេះនេះនៅថ្ងៃស្អែក។ អម្បាញ់មិញលោកបាននិយាយអំពីការដែលថានៅក្រោម

ការគ្រប់គ្រងរបស់គាត់ហ្នឹង ថាមានកិច្ចការផ្ទៃក្នុងរបស់ក្រសួង លោកបានលើកឡើងអំពីខាងសេដ្ឋកិច្ច ខាងភស្តុភារ ខាងផ្ទះភ្ញៀវ និងរោងចក្រ និងអង្គភាពផលិតបង្កបង្កើនផល ហើយលោកក៏បាននិយាយអំពីការទទួលសត្រូវផ្នែកសតិអារម្មណ៍។ នៅក្នុងបរិបទនេះ ជាភាសាបារាំង មិនមានខ្លឹមសារអីប៉ុន្មានទេ។ តើលោកអាចបំភ្លឺពីចំណុចនេះបានដែរឬទេ ថាបញ្ហាសតិអារម្មណ៍នេះ?

[១៥:០៤:១៩]

**ឆ៖** បាទ ក្រសួងដែលខ្ញុំ ផ្នែកដែលខ្ញុំកាន់កាប់ទេហ្នឹង គ្មានរោងចក្រទេបាទ ហ្នឹងទីមួយ។ អត់មានរោងចក្រទេបាទ។ ការងារសតិអារម្មណ៍ គឺធ្វើយ៉ាងណាឲ្យបងប្អូននេះ ទីមួយ រស់នៅឲ្យមានសីលធម៌ ស្នេហាជាតិត្រឹមត្រូវ ចេះការពារជាតិ កសាងជាតិ សីលធម៌ដែលត្រូវបំពាក់ គឺដូចខ្ញុំបានជម្រាបអ៊ីចឹង គឺសីលធម៌១២ប្រការ ក្រៅពីនោះគឺរៀនសូត្រឯកសារអីផ្សេងៗ ដែលទាក់ទងនឹងការកសាងអារម្មណ៍ឲ្យបានស្អាតស្អំ។

**សៈ** តើខ្ញុំអាចសង្ខេបថា ជាការអប់រំនយោបាយ នៃសមាជិក នៃមន្ទីរ នៅក្រសួងការបរទេសនេះដែរឬទេ? តើលោកជាអ្នកទទួលខុសត្រូវផ្នែកហ្នឹងមែនឬទេ?

**ឆ៖** បាទ ខ្ញុំមិនមែនទទួលខុសត្រូវអី ជាសំខាន់ដូចការចាត់តាំងអីបច្ចុប្បន្ននេះទេ គឺគ្រាន់តែថាខ្វះមនុស្សចេះតែដាក់ទៅ ធ្វើម៉េចឲ្យតែដំណើរការបានសិន ឲ្យទៅជាពេញលេញអីជាក្រសួងអីពេញលេញត្រឹមត្រូវតាមឋានានុក្រមអីរបស់ក្រសួងហ្នឹង គឺមិនទាន់ពេញលេញទេបាទ។

[១៥:០៦:៤២]

**សៈ** តើលោកមានទំនួលខុសត្រូវក្នុងការបណ្តុះបណ្តាលកម្មាភិបាល ផ្នែកមនោគមន៍វិជ្ជាដែរឬទេ?

**ឆ៖** ខ្ញុំមិនយល់ពាក្យមនោគមន៍វិជ្ជា។ ខ្ញុំយល់ថា ខ្ញុំបានតែអប់រំខាងអារម្មណ៍ស្នេហាជាតិតែប៉ុណ្ណោះ។ ដូច្នេះ មនោគមន៍វិជ្ជារបស់ខ្ញុំដែលអនុវត្ត គឺធ្វើម៉េចឲ្យបងប្អូនចេះការពារ និងកសាងប្រទេសជាតិតែប៉ុណ្ណោះ។

**សៈ** តើលោកមានទំនួលខុសត្រូវចំពោះបញ្ញាជនដែរឬទេ? តើលោកអាចនិយាយអំពីបញ្ហាបញ្ញាជននេះបានដែរឬទេ? បាទ ខ្ញុំសូមនិយាយអំពីបញ្ញាជន ដែលនៅក្រៅក្រសួងមិនមែននិយាយអំពីបញ្ញាជនដែលនៅក្នុងក្រសួងនោះទេ។

[១៥:០៨:២០]

**ឆ៖** ក្រៅក្រសួង ខ្ញុំមិនបានទទួលខុសត្រូវទេ។ ឯក្នុងក្រសួងបញ្ញាជនក៏ខ្ញុំមិនទទួលខុសត្រូវអីពេញលេញទេ គឺបង អៀង សារី ខាងបញ្ញាជន។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្ទាឯល៖**

លោកប្រធាន ខ្ញុំសូមយោងទៅឯកសារ D91/14 ហើយមានលេខ E3/91 ហើយនិងយោងទៅទំព័រជាភាសាបារាំង ERN 00503933 ជាភាសាបារាំង 00223592 និងជាភាសាខ្មែរ 00204095 រហូតដល់ 96។ ខ្ញុំគិតថា សាក្សីគាត់មានឯកសារហ្នឹងហើយ។ ហើយដើម្បីសម្រួល គឺថានៅទំព័រ៤ និង៥ នៃឯកសារហ្នឹង។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការរៀបចំបង្ហាញគាត់ ដើម្បីឲ្យគាត់ឆាប់បានរកឃើញចំណុចដែលត្រូវដេញដោល។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្ទាឯល៖**

**ស៖** វគ្គហ្នឹងគឺថា ជាចម្លើយដែលស្ថិតនៅក្រោមសំណួរ ដែលនិយាយអំពីបន្ទាប់ពីមាន-- ពីរំដោះភ្នំពេញនៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ពេលណាលោកមកធ្វើការនៅក្រសួងការបរទេស ហើយមានមុខងារអ្វី? ហើយរដ្ឋមន្ត្រីនៅពេលនោះឈ្មោះអ្វី? គឺនៅកណ្តាលកថាខណ្ឌនេះ លោកបានលើកឡើងថា "លោក អៀង សារី ជាអ្នកទទួលខុសត្រូវនៅក្រសួងការបរទេស។ ខ្ញុំជាអគ្គលេខាក្រសួងការបរទេសទទួលខុសត្រូវខាងក្របខ័ណ្ឌកម្មាភិបាល និងបុគ្គលិកនៃក្រសួងការបរទេស។ នៅពេលនោះ ខ្ញុំបានគ្រប់គ្រងក្មេងប្រហែលជា១.០០០នាក់ ដែលជាកូនរបស់កម្មាភិបាលបដិវត្តន៍ ដែលត្រូវបានបញ្ជូនមករៀនបច្ចេកទេសជាមួយគ្នានៅទីនោះ។ ខ្ញុំក៏គ្រប់គ្រងបញ្ញាជនដែលត្រឡប់មកពីប្រទេសបារាំង និងសហរដ្ឋអាមេរិក និងខ្លះទៀតនៅក្នុងស្រុក"។ ចម្លើយរបស់លោកនុំងមានបន្តទៅទៀត ក៏ប៉ុន្តែខ្ញុំមិនអានទាំងស្រុងនោះទេ។

[១៥:១១:៤៧]

ទាក់ទងទៅនឹងទំនួលខុសត្រូវរបស់លោកលើបញ្ញាជនដែលមកពីបរទេស ឬក៏/និងបញ្ញាជនផ្សេងទៀតដែលនៅក្នុងប្រទេសនោះ តើលោករក្សាចម្លើយរបស់លោក ឬក៏លោកចង់បញ្ជាក់បន្ថែមអ្វីផ្សេងពីនេះទៀត?

**លោក សាឡុត បាន៖**

**ឆ៖** បាទ ខ្ញុំចង់បន្ថែមត្រង់ ខ្ញុំគ្រប់គ្រងបញ្ញាជន ដែលវិលត្រឡប់មកពីបរទេស បារាំង និង

សហរដ្ឋអាមេរិក និងខ្លះទៀតក្នុងស្រុក។ ខ្ញុំចង់ជម្រាបថា គ្រប់គ្រងនេះ គ្រប់គ្រងតែក្នុងក្របខ័ណ្ឌក្រសួងទេ។ ខាងក្រៅអត់ទេ បាទ។ ហើយគ្រប់គ្រងនេះទៀត គឺគ្រប់គ្រងតែអំពីបញ្ហាធ្វើម៉េចកុំឲ្យមានការថ្នាំងថ្នាក់រវាងបញ្ញាជន និងកសិករ។ ច្រើនតែកូនកសិករដែលធ្វើពលកម្មអីនុំង កុំឲ្យមានការថ្នាំងថ្នាក់អីជាមួយគ្នា ទាំងជីវភាព ទាំងការរស់នៅបាទ។ ខ្ញុំសូមបញ្ជាក់តែប៉ុណ្ណឹងបន្ថែម។ ក្រៅពីនេះ ខ្ញុំយល់ស្របទាំងអស់។

[១៥:១៣:៣៦]

**ស៖** សូមអរគុណ។ នៅក្នុងចម្លើយដដែលនេះ គឺថាលោកនិយាយអំពីការគ្រប់គងកម្មាភិបាល ហើយនិងបុគ្គលិក តើលោកទទួលខុសត្រូវអំពីការគ្រប់គ្រងបុគ្គលិក ហើយនិងវិន័យរបស់បុគ្គលិកដែរឬទេ?

**ឆ៖** បញ្ហាបុគ្គលិកនៅក្នុងក្រសួងដូចខ្ញុំបានជម្រាបអ៊ីចឹង វាមានពីរផ្នែក។ មួយផ្នែកបញ្ញាជន។ មួយទៀត ផ្នែកមកពីខាងកសិករ។ ទទួលខុសត្រូវក្នុងផ្នែកបញ្ញាជន គឺភាគច្រើនបំផុត គឺបង អៀង សារី។ ឯខ្ញុំគ្រាន់តែសម្របសម្រួលធ្វើម៉េចកុំឲ្យមានទំនាស់គ្នារវាងបញ្ញាជន និងកសិករតែប៉ុណ្ណោះ។

**ស៖** តើអ្នកណាជាអ្នកទទួលបន្ទុកក្នុងការរៀបចំទស្សនកិច្ចរបស់គណៈប្រតិភូបរទេស? តើជាផ្នែករបស់លោក ឬក៏ជាផ្នែកបញ្ញាជន?

**ឆ៖** បាទ គឺផ្នែកបញ្ញាជន។

**ស៖** ចុះផ្នែកសន្តិសុខនោះយ៉ាងម៉េចដែរ?

**ឆ៖** ផ្នែកសន្តិសុខក៏ខ្ញុំរួមចំណែកក្នុងនោះដែរ។

[១៥:១៥:៣៨]

**ស៖** តើអនុប្រធានរបស់លោកហ្នឹងមានមុខងារសំខាន់ៗអ្វីដែរ ដូចលោក ជាម ដែលលោកបានលើកឡើងអម្បាញ់មិញនេះ?

**ឆ៖** មុខងារសំខាន់របស់លោក ជាម គឺផ្នែកសន្តិសុខ និងខាងបង្កបង្កើនផល បោសសម្អាតផ្ទះសម្បែងរបស់ភ្ញៀវ។

**ស៖** បាទ លោកបានលើកឡើងអម្បាញ់មិញថា លោកគ្រាន់តែមានតួនាទីជាអ្នកសម្របសម្រួលការងារតែប៉ុណ្ណោះ ហើយ អៀង សារី ជាមេធំ។ អ៊ីចឹងបានន័យថា គាត់មានទំនួលខុសត្រូវជាទូទៅ នូវអ្វីដែលកើតឡើងមានឡើង ឬក៏ធ្វើឡើងនៅក្រសួងការបរទេស តើអ៊ីចឹងមែនដែរឬទេ?

**ឆ៖** បាទ អ៊ីចឹងមែន។

**ស៖** ដូច្នេះក្នុងការអនុវត្តមុខងាររបស់លោក នៅពេលដែលលោកធ្វើអ្វីមួយក្នុងឋានៈលោកជាអគ្គលេខានៃក្រសួងនេះ គឺធ្វើ-- លោកធ្វើឡើងដោយគោរពឋានានុក្រម គឺដោយមានការអនុញ្ញាតអំពី អៀង សារី។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ មានការអនុញ្ញាតពីលោក អៀង សារី។ ក៏ប៉ុន្តែ បើលោក ប៉ង់ មកគឺលោក ប៉ង់ នេះមានឋានៈមិនអាចប្រាប់លោក អៀង សារី ក៏បានដែរ។

[១៥:១៧:៤៧]

**ស៖** តើលោក ប៉ង់ មានតួនាទីជាអ្វី?

**ឆ៖** តាមខ្ញុំដឹង ពីព្រោះអ្វីៗមិនដែលមានប្រកាសថាឋានៈអីៗទេលោក ប៉ង់ ប៉ុន្តែតាមខ្ញុំដឹងប្រហែលជាមន្ទីរ ប្រធានមន្ទីរ៨៧០។

**ស៖** លោកបានបញ្ជាក់កាលពីអម្បាញ់មិញនូវចម្លើយរបស់លោកដែលថា ពេលដែល សឿ វ៉ាស៊ី ហៅ ឌឿន ហ្នឹងស្លាប់ទៅ ខៀវ សំផន បានក្លាយជាប្រធានមន្ទីរ៨៧០។ តើ-- ឥឡូវនេះលោកថា ប៉ង់ ជាប្រធានការិយាល័យ មន្ទីរ៨៧០នេះដែរ។ តើលោកអាចពន្យល់អំពីភាពខុសគ្នានៃមុខងាររបស់មនុស្សទាំងពីររូបនេះទេ?

**ឆ៖** ខ្ញុំមិនអាចដឹងច្បាស់លាស់ដែរ គឺធ្លាប់តែចេញចូលៗ ខ្ញុំក៏ថាអាចប្រធានមន្ទីរ៨៧០ ហើយលោក ឌឿន ហ្នឹងក៏ខ្ញុំមិនច្បាស់លាស់ប៉ុន្មានដែរទេ។ គ្រាន់តែថាគាត់តាមការសន្និដ្ឋានដែរ ព្រោះមិនដែលប្រកាស មិនដែលប្រកាសថាបុគ្គលទាំងពីរនាក់នេះធ្វើអីៗ។

[១៥:១៩:៣៨]

**ស៖** ហើយនៅក្នុងការអនុវត្តមុខងាររបស់លោក នៅក្រសួងដដែល តាមគោលការណ៍ដែលគេអនុវត្តនៅសម័យនោះ តើលោកត្រូវរាយការណ៍ទៅអ្នកណាអំពីសកម្មភាពដែលការិយាល័យរបស់លោក ឬក៏លេខាធិការដ្ឋានរបស់លោកបានធ្វើនោះ?

**ឆ៖** គឺខ្ញុំរាយការណ៍ទៅលោក អៀង សារី។

**ស៖** ចុះផ្នែកសន្តិសុខនោះ លោករាយការណ៍ទៅលោក អៀង សារី ដែរ ឬក៏លោករាយការណ៍ទៅ ប៉ង់?

**ឆ៖** ផ្នែកសន្តិសុខក៏រាយការណ៍ទៅលោក អៀង សារី ដែរ?

**ស៖** តើលោកដឹងទេថា បានជួប អៀង សារី នៅក្រសួងការបរទេស?

**ឆ៖** បាទអត់យល់សំណួរបាទ។

[១៥:២១:០០]

**ស៖** បាទអម្បាញ់មិញលោកបាននិយាយអំពី ការដែលថា ប៉ង់ មានអំណាចនៅក្នុងក្រសួងនោះ ក៏ប៉ុន្តែ ប៉ង់ មិនមែននៅក្នុងក្រសួងការបរទេសហ្នឹងទេ។ តើនីតិវិធីជាធម្មតានៅពេលដែលយើងទៅក្រសួងមួយ គឺថាមិនមែនទៅដើម្បីនិយាយជាមួយរដ្ឋមន្ត្រីទេ គឺថា ប៉ង់ ទៅជួប អៀង សារី? តើមិនដឹងអ៊ីចឹងទេឬ នីតិវិធីកាលសម័យនោះ?

**ឆ៖** បាទនីតិវិធីកាលសម័យនោះ ប៉ង់ ទទួលខុសត្រូវ-- ប្រហែលជាទទួលខុសត្រូវសន្តិសុខចំពោះមុខ៨៧០។ ដូច្នេះ ប៉ង់ មានអំណាចមកទាក់ទងអ្វីនៅក្រសួងបាន-- ក្រសួងការបរទេសហ្នឹងបាន។

**ស៖** សំណួរខ្ញុំចង់ដឹងថា តើ ប៉ង់ បានផ្សារភ្ជាប់ទំនាក់ទំនងការងារជាមួយ អៀង សារី ដែរឬអត់ នៅពេលដែលគាត់មកក្រសួងការបរទេសនោះ? គឺថានៅពេលដែល អៀង សារី គាត់នៅក្រសួងនោះ គាត់មិនមែនចេញទៅក្រៅនោះទេ?

[១៥:២២:៣០]

**ឆ៖** ពេល អៀង សារី ទៅក្រៅ បាន ប៉ង់ មក។ ពេលបង អៀង សារី មិននៅ ប៉ង់ មិនមកទេ។

**ស៖** បាទ ខ្ញុំសូមត្រឡប់មកនិយាយអំពីរបាយការណ៍ដែលលោកបានរាយការណ៍ទៅ អៀង សារី។ តើលោកធ្វើរាយការណ៍ជាលាយលក្ខណ៍អក្សរ ឬក៏លោករាយការណ៍ដោយផ្ទាល់មាត់?

**ឆ៖** ជាធម្មតារាយការណ៍ផ្ទាល់មាត់។

**ស៖** តើលោកធ្វើការប្រជុំជាមួយលោក អៀង សារី ជាញឹកញាប់ដែរឬទេ នៅក្នុងអំឡុងពេលដែលលោកជាអគ្គលេខាធិការនៅក្រសួងការបរទេសនោះ?

**ឆ៖** បាទ ប្រជុំញឹកញាប់។

[១៥:២៣:៤៥]

**ស៖** តើលោកអាចជម្រាបយើងបានទេ ថាលោកជួបគាត់រាល់ថ្ងៃ ឬក៏ពីរ ឬបីដងមួយសប្តាហ៍ ឬក៏ពីរបីដងក្នុងមួយខែ?

**ឆ៖** បាទ ផ្ទះនៅជាប់នឹងក្រសួងការបរទេស គឺរាល់ថ្ងៃ។ ពេលណាគាត់មកធ្វើ-- មកក្រសួងការបរទេស គឺជួបរាល់ថ្ងៃ។

**ស៖** តើនេះជាការប្រជុំសម្រាប់តែមនុស្សពីរនាក់ទេ ឬក៏លោកបានចូលរួមប្រជុំនៅគណៈកម្មាធិការនៃក្រសួងនេះ? ហើយបើសិនមានកិច្ចប្រជុំបែបនេះនោះ តើវាញឹកញាប់បែបណាដែរ?

**ឆ៖** តែៗពីរនាក់ក៏បានជួបគ្នា ហើយជារួមក៏បានជួបគ្នា។

[១៥:២៥:០៤]

**ស៖** នៅពេលដែលលោកប្រជុំជាមួយអ្នកផ្សេងទៀត គឺថាប្រធានមន្ទីរជាដើម បើគេប្រាប់ខ្ញុំថាយើងត្រូវប្រើពាក្យថា "មន្ទីរ" ជាភាសាខ្មែរ។ នៅពេលដែលប្រជុំជាមួយប្រធានមន្ទីរ តើអ្នកណារាយការណ៍ទៅថ្នាក់លើពេលដែលមានកិច្ចប្រជុំបែបនេះ?

**ឆ៖** មន្ទីរ ប្រធានមន្ទីរផ្នែកខាងបង្កបង្កើនផល ផ្នែកខាង-- គេហៅថា ផ្នែកខាងកសិករ ខ្ញុំនិយាយអ៊ីចេះទៅចុះ ផ្នែកខាងកសិករ គឺខ្ញុំរាយការណ៍ ឬលោក ជាម រាយការណ៍។ ឯផ្នែកខាងបញ្ញាជនមានផ្នែកផ្សេងគេរាយការណ៍ ព្រោះខ្ញុំមិនយល់ពីរឿងការងាររបស់បញ្ញាជនទេ។

**ស៖** បាទ ខ្ញុំយល់ព្រមថាលោកមិនមែនអ្នកទទួលបន្ទុកខាងបញ្ហាទាំងអស់ទេ ក៏ប៉ុន្តែលោកមានវត្តមាននៅក្នុងកិច្ចប្រជុំទាំងអស់នេះ អ៊ីចឹងលោកឃើញគេធ្វើរបាយការណ៍។ តើលោកអាចជម្រាបបានដែរទេថា តើអ្នកណាជាអ្នកធ្វើ អ្នករាយការណ៍ទាក់ទងនឹងកម្មាភិបាលនៅក្នុងក្រសួងការបរទេសនេះ?

[១៥:២៦:៣២]

**ឆ៖** ឃើញសេចក្ដីរាយការណ៍ គឺតាមផ្នែកចាត់តាំងរបស់ក្រសួងមួយៗ អ្នកខ្លះទៅផ្នែកនេះទៅរាយការណ៍ទៅ ផ្នែកមួយទៀតរាយការណ៍ទៅ។ ហើយខ្ញុំមិនដឹងជាបច្ចេកទេស សេចក្ដីរាយការណ៍ហ្នឹងយ៉ាងណាៗ ខ្ញុំមិនដឹងទេ ផ្នែកខាងបញ្ញាជន។

**ស៖** តើ អៀង សារី មានតួនាទីជាអ្វីនៅក្នុងកិច្ចប្រជុំជាក់លាក់នេះ? តើគាត់និយាយអ្វីទេ? ហើយបើគាត់និយាយៗអ្វីខ្លះ?

**ឆ៖** ខ្ញុំចាំមិនអស់ទេ និយាយពីរឿងការងារជាក់ស្ដែងចំពោះមុខ បាទបច្ចេកទេសមួយៗ។

**ស៖** តើគាត់ធ្លាប់ធ្វើការបង្គាប់បញ្ជា ឬក៏កំណត់ទិសដៅណាមួយនៅក្នុងកិច្ចប្រជុំបែបនេះដែរឬទេ?

[១៥:២៨:០១]

**ឆ៖** ពាក្យថា "បង្គាប់បញ្ជា" ដូចមិនមានទេបាទ។

**ស៖** តើគាត់ប្រើកិច្ចប្រជុំទាំងអស់នេះ ដើម្បីផ្តល់ព័ត៌មានជូនដំណឹងដល់លោកអំពីគោលជំហររបស់បក្ស ឬក៏គោលជំហរគណៈអចិន្ត្រៃយ៍ពាក់ព័ន្ធទៅនឹងបញ្ហាមួយចំនួន។ តើគាត់មានបានផ្តល់ដំណឹងអំពីសេចក្តីសម្រេចរបស់បក្សនៅក្នុងផ្នែកណាមួយដែរឬទេ?

**ឆ៖** ដូចជាមិនធ្លាប់មានបាទ។

**ស៖** តើលោក អៀង សារី ធ្វើជាគណៈអធិបតីនៃការធ្វើស្វ័យទិតៀនឡើងវិញនៃ-- នៅក្រសួងការបរទេសដែរឬទេ? បាទ សូមទោស ធ្វើជីវទស្សន៍? តើការជីវទស្សន៍នេះមានន័យយ៉ាងម៉េច? ហើយពេលដែលលោក អៀង សារី ធ្វើប្រជុំជីវទស្សន៍នេះ តើគាត់បានធ្វើយ៉ាងម៉េចខ្លះ?

[១៥:៣០:០០]

**ឆ៖** គេហៅថា ធ្វើជីវទស្សន៍នេះ គឺកសាងខ្លួន។ ទីមួយ កសាងខ្លួន ដោយខ្លួនឯង មើលខ្លួនឯងតើមានខុសត្រូវយ៉ាងម៉េចខ្លះ? ឲ្យខ្លួនឯងហ្នឹង គិតគូរដោយខ្លួនឯង។ ទីពីរ គឺសមូហភាព សរុប កសាង ហើយទីបី បង អៀង សារី សរុប គុណសម្បត្តិ និងគុណវិបត្តិរបស់បុគ្គលនោះ។

**ស៖** តើ អៀង សារី មានវត្តមានរហូតនៅក្នុងកិច្ចប្រជុំបែបនេះ ហើយគាត់ជាគណៈអធិបតីរហូត ឬក៏យ៉ាងម៉េច?

**ឆ៖** ប្រជុំធំៗបានមាន។ គេហៅថា ប្រជុំដកពិសោធន៍ប្រចាំឆ្នាំ ប្រចាំត្រីមាស។ ឯប្រជុំប្រចាំខែ តាមផ្នែកមួយៗ។ ប្រជុំប្រចាំអាទិត្យ ក្រុមមួយៗ។

**ស៖** បាទ សូមអរគុណ។ នៅក្នុងកិច្ចប្រជុំជីវទស្សន៍ នៅដែលពេល អៀង សារី គាត់មានវត្តមាននេះ តើគេនិយាយអំពីសត្រូវដែរឬទេ? គឺថាសត្រូវពីក្រៅ ហើយនិងសត្រូវខាងក្នុង?

**ឆ៖** ជាធម្មតាគឺមាន។

**ស៖** ហេតុអីបានយើង-- គេនិយាយអំពីខ្មាំង? តើមានការគំរាមកំហែង ឬក៏មានខ្មាំងនៅក្នុងក្រសួងការបរទេស ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំដូចជាពិបាកឆ្លើយដែរ លោកសួរយ៉ាងដូច្នេះ ខ្ញុំពិបាកឆ្លើយបាទ។ ខ្ញុំសូមអត់ឆ្លើយទេបាទ។ វាអត់យល់ អត់ជម្រៅដែលចង់សួរ។

[១៥:៣៣:១៤]

**ស៖** ឥឡូវ ខ្ញុំសូមសួរបន្តទៀត ហេតុអ្វីបានជាយើងត្រូវនិយាយអំពីខ្មាំង ព្រោះថាលោកបានឆ្លើយអម្បាញ់មិញហើយថា នៅក្នុងការប្រជុំជីវទស្សន៍នេះ គេមាននិយាយអំពីខ្មាំង។ តើហេតុអីក៏មានសារៈសំខាន់ក្នុងការនិយាយពីខ្មាំងនៅក្រសួងនោះ? តើដោយហេតុថា ប្រហែលជាមានខ្មាំងដែលលាក់ខ្លួននៅក្នុងការបរទេស ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ សំណួរនេះ វាចូលទៅក្នុងទស្សនវិជ្ជាជ្រៅណាស់បាទ។ ខ្ញុំមិនអាចពន្យល់បានទេ ប៉ុន្តែខ្ញុំសរុបជូន មនុស្សយើងម្នាក់ៗ ខ្លួនខ្ញុំផ្ទាល់ គឺមានទស្សនៈខាងព្រហ្មមួយ។ ទីពីរ ទស្សនៈខាងប្រេតមួយ។ ទីបី មានទស្សនៈខាងបិសាច។ នេះ ទស្សនវិជ្ជា បាទ ខ្ញុំជម្រាបខាងទស្សនវិជ្ជាវិញបាទ។ ខ្ញុំយល់អ៊ីចឹង។

[១៥:៣៤:៤៩]

**ស៖** ចំពោះលោក តើគោលបំណងនៃការប្រជុំធ្វើជីវទស្សន៍នេះជាអ្វី ហើយនិងកិច្ចប្រជុំដែលលើកធ្វើការទិតៀន ហើយស្វ័យទិតៀនបដិវត្តន៍នេះ?

**ឆ៖** សូមទោសលោកសួរបំណង? បំណងអ៊ីចឹង?

**ស៖** បាទអ៊ីចឹង-- នុំងហើយ ថាហេតុអីបានជា ថាចំពោះបក្សហ្នឹងមានសារៈសំខាន់ក្នុងការធ្វើកិច្ចប្រជុំទាំងអស់នេះ?

**ឆ៖** មានសារៈសំខាន់ក្នុងការប្រជុំទាំងអស់នេះ ដូចខ្ញុំបានជម្រាបអំមិញអ៊ីចឹង។ ក្នុងខ្លួនខ្ញុំ គឺជាប់នូវពាក្យថា "ព្រហ្ម"។ ព្រហ្ម នេះបានន័យថាយ៉ាងម៉េច? ព្រហ្ម នេះបានន័យថា តើអ្នកធ្វើផ្ទះដំបូលមានព្រំឬទេ? មនុស្សយើង ត្រូវតែធ្វើដំបូន្មានព្រះព្រហ្ម។ ដូចច្បាប់ព្រហ្មទណ្ឌ ច្បាប់ព្រហ្មទណ្ឌ តាមខ្ញុំយល់ គឺថាបើអ្នកឯកធ្វើខុសច្បាប់ព្រហ្ម គឺអ្នកឯងត្រូវមានទោស។ តើច្បាប់ព្រហ្មមានអ្វីជាគោល? ច្បាប់ព្រហ្ម គឺមានទឹក ដី ខ្យល់ ភ្លើង។ បើអ្នកឯងធ្វើខូចអាហ្នឹង គឺអ្នកឯងត្រូវមានទោស គឺថាខូចបរិស្ថាន។ ខ្ញុំជានគរកាយមួយ ខ្ញុំពន្យល់ តាមទស្សនវិជ្ជារបស់ខ្ញុំដែលយល់អ៊ីចឹង បានខ្ញុំចូលចិត្តធ្វើជីវទស្សនៈបដិវត្តន៍។

[១៥:៣៧:១១]

សូមមានយោបល់បន្តិចទៀតបាទ។ បើមិនធ្វើអ៊ីចឹងទេ មិនឈ្នះទេ មិនគ្រប់គ្រងខ្លួនឯងបានទេ។ បើគ្រប់គ្រងខ្លួនឯងមិនបាន ទៅគ្រប់គ្រងប្រទេសជាតិម្តេចបាន។ សូមចប់បាទ។

**ស៖** តើកិច្ចប្រជុំទាំងអស់នេះ គេអាច-- នៅក្នុងកិច្ចប្រជុំទាំងអស់ហ្នឹង គេអាចរិះគន់អ្នកផ្សេង ដែលយោងទៅតាមសីលធម៌ទាំង១២ប្រការ ដែលលោកបាននិយាយ ហើយតើគេត្រូវបង្ហាញអំពីចំណុចខ្សោយ ឬក៏កំហុសដែលគេបានប្រព្រឹត្តដែរឬទេនៅក្នុងកិច្ចប្រជុំបែបហ្នឹង?

**ឆ៖** បាទ គេបង្ហាញ បើអ្នកឯងចូលទៅខាងប្រេត ឬក៏ចូលទៅខាងបិសាច នោះអ្នកនឹងកែទៅ។ បើអ្នកមិនកែទេ អ្នកអន្តរាយខ្លួនឯង ហើយក៏អន្តរាយដល់ប្រទេសជាតិដែរ។

**ស៖** ប្រសិនបើអ្នកដែលស្ថិតនៅខាងបិសាច ដូចដែលលោកនិយាយនោះ ប៉ុន្តែគេមិនមាន មិនផ្លាស់ប្តូរនោះ ហើយនៅក្នុងកិច្ចប្រជុំរិះគន់ ឬទិតៀន ឬក៏ស្វ័យទិតៀននោះ ម្នាក់ បុគ្គលហ្នឹងគឺថាប្រព្រឹត្តអំពើដដែលៗ ហើយគេលើកអំពីកំហុសរបស់គាត់ដដែលៗ។ តើមានផលវិបាកយ៉ាងណាចំពោះបុគ្គលរូបនោះ ប្រសិនបើគាត់នៅតែចចេស នៅតែប្រព្រឹត្តអំពើដដែលៗនោះ?

[១៥:៣៨:៥៩]

**ឆ៖** គឺមិនដែលថាគេមិនកែទេ គឺគេកែ។ កែជាបណ្តើរៗៗ មិនដែលភរថា យី ខ្ញុំមិនខុសទេ បើសមូហភាពជួយហើយ គឺថាត្រូវតែទទួល។

**ស៖** តើមានអ្នកណាដែលមិនយល់ ហើយមិនមានមិនកែទេ តើលោកមានឧទាហរណ៍ទេ ថាមានអ្នកដែលមិនគោរពតាមវិន័យ ហើយប្រហែលជាត្រូវបានដកចេញ ឬក៏ដាក់ទណ្ឌកម្មនៅក្នុងក្រសួងការបរទេស?

[១៥:៤០:០០]

**ឆ៖** នៅក្នុងក្រសួងខ្ញុំ មិនដែលដាក់វិន័យអីទេ។ ឯវិន័យ ចង់ថាវិន័យៗយ៉ាងម៉េច លោកចង់ថាវិន័យយ៉ាងម៉េច? វិន័យហ្នឹង ដូចជា អី? ដាក់ទណ្ឌកម្មអីៗអ៊ីចឹងអ្វី? ឬមួយយកទៅសម្លាប់អីអ៊ីចឹងលោកថាឲ្យច្បាស់ទៅបាទ។

**ស៖** ខ្ញុំចង់និយាយអំពីទណ្ឌកម្មខាងវិន័យ តើមានការដាក់ទណ្ឌកម្មខាងវិន័យទេ? ហើយទីពីរប្រសិនបើបុគ្គលម្នាក់ចចេសប្រព្រឹត្តកំហុសដដែល តើគាត់អាចបាត់បង់មុខតំណែងរបស់គាត់ ឬក៏ផ្លាស់ទៅណាផ្សេង ឬក៏ចាប់ខ្លួន។ តើមានអ៊ីចឹង?

**ឆ៖** អ៊ីចឹងទៅ ខ្ញុំស្រណុកស្តាប់បាទ។ ក្នុងក្រសួងការបរទេស គ្មានវិន័យចាប់ខ្លួនទេ មានត្រឹមតែផ្លាស់តំណែងឲ្យទៅកន្លែង ដូចជា ផ្ទះលេខ១ ធ្លាប់ផ្ទះលេខ២ អីធ្វើអាក្រក់ពីផ្ទះលេខ២ ឲ្យទៅផ្ទះលេខ១ អីអ៊ីចឹងទៅ ទៅធ្វើការងារអីដែល បើខុសអីៗទៅកុំឲ្យខុសវាធំ។ មានតែប៉ុណ្ណឹងទេក្នុងក្រសួង

អត់ដែលយកទៅឯណាចាប់ទៅណាទេ។

[១៥:៤១:៣៧]

**ស៖** សូមអរគុណ។ នៅពេលដែលលោក អៀង សារី ធ្វើទស្សនកិច្ច គាត់តែងតែធ្វើដំណើរពីព្រោះគាត់ថាជា រដ្ឋមន្ត្រីក្រសួងការបរទេស។ តើអ្នកណាជាអ្នកដឹកនាំកិច្ចប្រជុំរបស់ក្រសួងការបរទេស នៅក្នុងទីស្ដីការក្រសួងនៅពេលអវត្តមាន អៀង សារី នោះ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី!

**លោក លឹម ប៊ុនហេង៖**

សូមអរគុណលោកប្រធាន។ សំណួរដែលសហព្រះរាជអាជ្ញាអន្តរជាតិ បានលើកឡើងនេះគឺមានការប៉ុនប៉ងសួរទៅលើលោក អៀង សារី ម្ដងហើយ ប៉ុន្តែបែរជាបង្វែរសំណួរនេះមកលើសាក្សី ហាក់បីដូចជាមានសំណួរនេះមានពិរុទ្ធភាពដល់សាក្សី នាំឲ្យគេយល់ច្រឡំថា សាក្សីជាបុគ្គលទទួលខុសត្រូវខ្ពស់បំផុតនៅក្នុងក្រសួងការបរទេស។ សូមឲ្យអង្គជំនុំជម្រះពិចារណាអំពីសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងខ្លួនឯងរបស់សាក្សី។

**ប្រធានអង្គជំនុំ៖**

លោកស្ដាប់ហើយពិភាក្សាជាមួយនឹងសាក្សីសិនណ៎ា កុំឲ្យ-- ពិភាក្សាជាមួយនឹងសាក្សីណ៎ាថាតើសំណួរនេះវាគួរតែឆ្លើយដែរឬទេ។ នែ៎លោកមិនអាចមកឆ្លើយ ឬមិនឆ្លើយជំនួសសាក្សីទេ គ្រាន់តែប្រឹក្សាពិភាក្សាពន្យល់មើលថា តើហេតុផលអ៊ីចឹងវាត្រូវជា សំណួរហ្នឹង គេអាចមានខ្លឹមសារនាំឲ្យឆ្លើយហ្នឹងយ៉ាងដូចម្ដេច ថាតើលោកអាចឆ្លើយបានទេនៅសំណួរហ្នឹង ឬក៏មិនឆ្លើយទេ។ សាក្សីទេដែលជាអ្នកសម្រេច លោកគ្រាន់តែខ្សឹបពិភាក្សាផ្ទៃក្នុង តែពីរនាក់ហ្នឹងបានហើយជាការសម្ងាត់។

[១៥:៤៣:១៧]

**លោក លឹម ប៊ុនហេង៖**

...អាស្រ័យហេតុនេះ សូមការអនុញ្ញាតពីលោកប្រធាន ដើម្បីមានពេលវេលាពិគ្រោះជាមួយសាក្សី។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញបាទ!

*(សាក្សីពិភាក្សាជាមួយមេធាវី)*

[១៥:៤៤:៥៤]

ឲ្យសាក្សីណ៎ា សាក្សីនិយាយថាម៉េចទៅលោកសាក្សី?

**លោក សាឡុត បាន៖**

បាទ សំណួរអំមិញនេះ សូមសួរម្ដងទៀតបាទ ខ្ញុំសូមសួរ-- ខ្ញុំសូមឲ្យសំណួរឡើងវិញបាទ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណច្រើន។ ហើយអ៊ីចេះសាក្សីស្ដាប់ខ្លួនលោក១ ស្ដាប់ខ្លួនឯងផ្ទាល់ទៅ ហើយប្រសិនបើលោកយល់ថា សំណួរដែលគេសួរមកលោកហ្នឹង នឹងនាំឲ្យចម្លើយលោកហ្នឹង នឹងអាចទម្លាក់កំហុសមកលើខ្លួនឯងពាក់ព័ន្ធនឹងបទល្មើសនានា ឬក៏វិនាសកម្មផ្សេង១ដែលកើតមានឡើងដោយសារសំណួរថាតើលោកប្រព្រឹត្តអំពើហ្នឹងដែរ? ឧទាហរណ៍អ៊ីចឹង។ អាហ្នឹងគឺលោកផ្អាកសិន លោក ពិភាក្សាជាមួយនឹងប្រឹក្សា ម្ចាស់ការ លោកប្រឹក្សាជាមួយនឹងខាងមេធាវីរបស់លោក ថាបញ្ហាផ្លូវច្បាប់ហ្នឹងវាយ៉ាងម៉េចដែរ? ដើម្បីលោកសម្រេចចិត្តថា លោកត្រូវឆ្លើយ ឬក៏សូមមិនឆ្លើយតបទេ ដោយសារវាជាសំណួរដែលឲ្យលទ្ធផលនៃការចម្លើយ ឬអំណះអំណាងរបស់លោកហ្នឹងអាចប្រឆាំងនឹងខ្លួនឯង។ មិនមែនឲ្យមេធាវីម្ចាស់ការមកទប់នូវសំណួរមិនឲ្យសួរនោះទេ។

[១៥:៤៦:១៩]

យល់ទេ? ដើម្បីឲ្យវាប្រឹក្សាគ្នា មុននឹងឆ្លើយនៅក្នុងករណីមួយចំនួនទេ អាចមួយចប់ហ្នឹងមិនមានក៏មានដែរ។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា សូមតាំងសំណួរសាជាថ្មីទៀត ព្រោះសាក្សីដូចទំនងជាភ្លេចនូវការតាំងសំណួររបស់លោកហើយ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ខ្ញុំបានសួរអម្បាញ់មិញនេះ ថានៅពេល អៀង សារី អវត្តមានគឺគាត់កំពុងជាប់ទៅបំពេញទស្សនកិច្ច តើអ្នកណាជាអ្នកដឹកនាំកិច្ចប្រជុំនៅក្នុងក្រសួងការបរទេស?

**លោក សាឡុត បាន៖**

**ឆ៖** កិច្ចប្រជុំនៅក្រសួងការបរទេស តាមផ្នែក តែមិនទទួលខុសត្រូវសម្រេចអីទេ។

[១៥:៤៧:២៦]

**ស៖** ចំពោះកិច្ចប្រជុំធំៗ តើមានកិច្ចប្រជុំធំៗទេ នៅពេលអវត្តមាន អៀង សារី នោះ? ឧទាហរណ៍ដូចថា មានកិច្ចប្រជុំធំៗដែលមានប្រមូលផ្តុំប្រធានមន្ទីរផ្សេងៗមកចូលរួមនោះ តើមានទេ?

**ឆ៖** មិនមានទេបាទ។ មិនមានទេ។

**ស៖** ហេតុអីបានជាមិនមានកិច្ចប្រជុំបែបហ្នឹង? តើគេត្រូវចាំលោក អៀង សារី ត្រឡប់មកវិញ ដើម្បីរៀបចំកិច្ចប្រជុំធំៗ ឬក៏យ៉ាងម៉េច?

**ឆ៖** បានន័យថា កិច្ចប្រជុំមាន ប៉ុន្តែប្រជុំតូចៗ តាមក្រុម តាមពួក តែប៉ុណ្ណោះ។

**ស៖** នៅពេលដែលមានបញ្ហាធំចោទឡើង តើក្រសួងការបរទេសមានទទួលជំនួយពីកម្មាភិបាលគណៈមជ្ឈិមដែរឬទេ នៅពេលដែល អៀង សារី អវត្តមាននោះ?

**ឆ៖** អត់មានទេ។ ហើយដូចជាមិនឃើញមានបញ្ហាអីធំៗ។

[១៥:៤៩:១០]

**ស៖** តើអាចធ្លាប់កើតមានទេថា អៀង សារី ហើយនិងលោកចេញដំណើរទៅរួមគ្នា។ លោកបាននិយាយថា មានការទៅប្រទេសចិន និងទៅមហាសន្និបាតអង្គការសហប្រជាជាតិ នៅក្នុងករណីដែលលោកអវត្តមាន ហើយនិងលោក អៀង សារី អវត្តមាននោះ តើអ្នកណាដឹកនាំក្រសួងការបរទេស?

**ឆ៖** ខ្ញុំភ្លេចហើយបាទ។ ខ្ញុំភ្លេចហើយ។

**ស៖** លោកសាក្សី តើលោកអាចជម្រាបយើងបានទេ ថាអ្នកណាជាអ្នកទទួលខុសត្រូវនៃគណៈកម្មាធិការទំនាក់ទំនងជាមួយមិត្តរបស់កម្ពុជាប្រជាធិបតេយ្យនៅលើពិភពលោក អ្នកណាជាអ្នកទទួលខុសត្រូវគណៈកម្មាធិការនេះនៅក្នុងក្រសួងការបរទេស?

**ឆ៖** អត់យល់សំណួរ។ ខ្ញុំអត់យល់សំណួរបាទ។

**ស៖** ខ្ញុំចង់ដឹងថា តើមានគណៈកម្មាធិការមួយនៅក្នុងក្រសួងការបរទេសដែលទទួលបន្ទុកជាពិសេសក្នុងការកែលម្អទំនាក់ទំនងជាមួយនឹងប្រទេសជាមិត្ត ជាមួយបរទេសដែលមាននៅលើពិភពលោក តើមានដែរឬទេ? ខ្ញុំចង់ដឹងថា តើអ្នកណាជាប្រធានគណៈកម្មាធិការនេះ?

**ឆ៖** ខ្ញុំអត់បានដឹងទេ។

[១៥:៥១:១១]

**សៈ** នៅសល់១០នាទីទៀត ខ្ញុំសូមជជែកពិភាក្សាអំពីបញ្ហាមួយទៀត គឺជាការជ្រើសរើសបុគ្គលិកដែលមិនមែនជាបញ្ញាជននៅក្នុងក្រសួងការបរទេស។ តើលោកអាចបញ្ជាក់បានទេថា តើមានសមាមាត្របែបណាចំពោះសមាជិកនៃបុគ្គលិកក្រសួងការបរទេស ដែលចេញមកពីវណ្ណៈកសិករ ឬកម្មករធៀបទៅនឹងបញ្ញាជននោះ តើមានភាគរយប៉ុន្មានដែរ?

**ឆៈ** ក្រសួងការបរទេសមិនរើសបុគ្គលិកដោយខ្លួនឯងទេ គឺខាងលោក ប៉ង់ គេរើសយកមកឲ្យ។

**សៈ** តើមានបុគ្គលិកក្រសួងការបរទេសដែលមកពីវណ្ណៈកសិករ កម្មករ ឬក៏មានបញ្ញាជនច្រើនដែលធ្វើការនៅក្រសួងការបរទេស។ តើមានក្រុមណាដែលច្រើនជាងនោះ ខាងវណ្ណៈកសិករ កម្មករ ឬក៏បញ្ញាជន?

[១៥:៥២:៤៨]

**ឆៈ** គឺវណ្ណៈកសិករច្រើន។

**សៈ** តើយើងអាចនិយាយថា វណ្ណៈកសិករ កម្មករហ្នឹង ដែលរើសដោយ ប៉ង់ ហ្នឹងគឺជាអ្នកដែលមានវណ្ណៈភាពស្អាតស្អំ តើអ៊ីចឹងមែនទេ?

**ឆៈ** បាទ អ៊ីចឹងមែន។

**សៈ** តើមានន័យថាម៉េចដែរ ដែលថាជីវទស្សនៈស្អាតស្អំនោះ? អ្នកដែលមានអតីតកាលស្អាតស្អំ ឬក៏មានវណ្ណៈភាពស្អាតស្អំ តើក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ពាក្យនេះមានន័យថាយ៉ាងម៉េច?

**ឆៈ** គឺមកពីប្រភពដែលក្រីក្រ។

[១៥:៥៤:០៩]

**សៈ** តើមានអ្នកដែលថាប្រវត្តិរូបហ្នឹងមិនស្អាតស្អំទេនៅក្រសួងការបរទេសនោះ ឬក៏យើងជ្រើសរើសយកតែអ្នកដែលចេញមកពីវណ្ណភាពស្អាតស្អំ?

**ឆៈ** ពិបាកឆ្លើយណាស់ ដូចជាវាវិលវល់ពេក បាទខ្ញុំពិបាកឆ្លើយ។ សុំអត់ឆ្លើយទេបាទ ដូចវិលវល់ពេក។

**សៈ** តើលោកមានការលំបាកក្នុងការឆ្លើយ ឬក៏លោកមិនចង់ឆ្លើយ?

**ឆៈ** ខ្ញុំមានការលំបាកនឹងឆ្លើយបាទ ពីព្រោះខ្ញុំបាននិយាយអស់ហើយ វណ្ណៈកសិករ ហើយគេជ្រើសរើសមកឲ្យខ្ញុំ។ ខ្ញុំយល់ឃើញថា ដល់គេជ្រើសរើសមកហ្នឹង គេសម្រិតសម្រាំងរួចហើយ ខ្ញុំចង់

និយាយអ៊ីចឹង។ ដូច្នេះ វាពិបាកដែរ បច្ចេកទេសហ្នឹង វាមកពីក្រោមៗ ឲ្យមកថាហ្នឹងស្អាតហើយ យកទៅ យកប្រើទៅ។ អាហ្នឹងបើនិយាយជាសាមញ្ញៗអ៊ីចឹង វាស្រណុកស្តាប់ដែរបាទ។ ប៉ុន្តែបើនិយាយបត់បែនតាមបច្ចេកទេសសម័យ ខ្ញុំស្តាប់មិនសូវបានដែរបាទ។

[១៥:៥៦:០៧]

**ស៖** ខ្ញុំចង់យោងទៅលើ-- និងចម្លើយពីរដែលសាក្សីបានផ្តល់នៅឆ្នាំ២០១០ នៅក្នុងឯកសារ E3/446 D369/36 គឺនៅចម្លើយ២១ និងចម្លើយ៧០។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអនុញ្ញាតលោកប្រធាន ដើម្បីបង្ហាញឯកសារនេះនៅលើអេក្រង់ ហើយសូមឲ្យសាក្សីអាននូវអ្វីដែលខ្លួនបានឆ្លើយនៅចំពោះមុខអ្នកស៊ើបអង្កេតរបស់ អ.វ.ត.ក។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១៥:៥៧:១៣]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** ឯកសារនេះបានបង្ហាញហើយ។ នៅក្នុងចម្លើយទី២១ លោកបាននិយាយថា "ខ្ញុំបានជម្រាបហើយនៅ ប-១ គេមានរក្សាទុកមនុស្សដែលមានប្រវត្តិរូបមិនច្បាស់ ហើយពេលដែលគេស៊ើបហើយ គេនឹងបញ្ជូនចេញទៅ"។ ហើយនៅចម្លើយទី៧០ ខ្ញុំសូមអានសំណួរ ដើម្បីឲ្យកាន់តែច្បាស់។ មានសំណួរសួរថា "មានឯកសារមួយបាននិយាយថា មានខ្មាំងនៅក្នុងការិយាល័យ បើខ្មាំងរឹងទទឹងក្រសួងនឹងបញ្ជូនទៅមន្ទីរសន្តិសុខ ដើម្បីឲ្យបង្ក្រាប"។ ហើយស៊ើបអង្កេតសួរលោកថា "តើលោកយល់យ៉ាងណាចំពោះការអះអាងនេះ? លោកបានឆ្លើយថា អត់មានទេ នៅក្នុងក្រសួងគឺគេរើសយកអ្នកដែលមានប្រវត្តិរូបស្អាតស្អំ"។ ចម្លើយទាំងពីរហាក់បីដូចជាផ្ទុយគ្នាបន្តិច ដូច្នេះខ្ញុំសូមឲ្យលោកបំភ្លឺ។ ខ្ញុំចង់ដឹងថាតើលោកនៅតែរក្សាដដែលចំពោះចម្លើយនេះ? ជាពិសេសគឺចំពោះចម្លើយ២១ លោកនៅតែរក្សាដដែល? គឺថា "នៅមន្ទីរប-១ គេមានរក្សាទុកមនុស្សដែលមានប្រវត្តិរូបមិនច្បាស់លាស់ ហើយនៅពេលដែលគេស៊ើបហើយ គេនឹងបញ្ជូនចេញទៅ"។ ហើយលោកបានបន្ថែមថា "គឺ ប៉ង់ ជាអ្នកនាំទៅ"។ តើលោកនៅរក្សាចម្លើយនេះដដែល ឬក៏លោកចង់អត្ថាធិប្បាយអ្វីបន្ថែម?

[១៥:៥៨:១៥]

**លោក សាឡូត ស៖**

**ឆ៖** បាទ ខ្ញុំរក្សាដដែល។ ខ្ញុំសូមតែបញ្ជាក់បន្តិចបាទ បញ្ជាក់៖ ឧទាហរណ៍ដូចជាបងថ្លៃរបស់ខ្ញុំ ឈ្មោះ ហុង ដែរ គេយកមកធ្វើ លោក ប៉ង់ ហ៊្នឹងយកមកធ្វើ ៗសិន។ ដល់គេយកទៅ ពេលណាគេយកទៅបាន គេយកពេលនោះ។ ហើយគេយកទៅៗ យកទៅណាខ្ញុំមិនដឹងទេ។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវ ដល់ពេលសមល្មមនឹងសម្រាកហើយ អរគុណលោកតំណាងសហព្រះរាជអាជ្ញា។ អរគុណមេធាវី-- អ៎ អរគុណមេធាវី ហើយនិងសាក្សី។

កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ គឺអង្គជំនុំជម្រះសមល្មមនឹងសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការលើកបន្តទៅធ្វើនៅថ្ងៃស្អែក ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ ដោយលោកសាក្សីត្រូវការ-- អង្គជំនុំជម្រះត្រូវការស្តាប់នូវសក្ខីកម្មរបស់សាក្សីបន្តទៀត ដោយសារបញ្ហាវាធំ វាវែង ហើយនៅមានសំណួរជាច្រើន ដែលអាចសួរពាក់ព័ន្ធនឹងលោកសាក្សី។ ដូច្នេះ អង្គជំនុំជម្រះអញ្ជើញលោកមកថ្ងៃស្អែកទៀត ដើម្បីបន្តផ្តល់សក្ខីកម្មដោយមានការសួរនាំពីភាគីផ្សេងៗ របៀបថ្ងៃនេះដែរ ប៉ុន្តែបញ្ហាផ្សេង មិនច្រំដែលទេ។

[១៦:០១:១២]

ហើយលោកមេធាវីប្រឹក្សាសាក្សីដូចគ្នា គឺសូមអញ្ជើញលោកមកនៅអមជាមួយនឹងសាក្សី ក្នុងអំឡុងពេលនៃសាក្សីនេះផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។ ហេតុដូច្នេះ សូមលោកអញ្ជើញមកឲ្យបានមុនម៉ោងប្រាំបួននៅព្រឹកថ្ងៃស្អែក។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាព គាំពារសាក្សី និងអ្នកជំនាញ ដើម្បីផ្តល់មធ្យោបាយទៅមក ស្នាក់នៅ ហើយនិងឲ្យរៀបចំអញ្ជើញគាត់មកកន្លែងផ្តល់សក្ខីកម្មនេះ នៅព្រឹកថ្ងៃស្អែក នៅវេលាម៉ោងប្រាំបួន ជាមួយនឹងមេធាវីទីប្រឹក្សា-- អ៎ មេធាវីប្រឹក្សា។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូប ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយនិងឲ្យនាំខ្លួនពួកគាត់ទាំងបីរូបមកកាន់កន្លែងបន្ទប់សវនាការនេះ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០២នាទី)*